## គំនិតទូទៅខ្លីៗរបស់មុខវិជ្ជា

**១.** មួយថ្ងៃ ឬ ពីរថ្ងៃមុនពេលបើកថ្នាក់ដំបូង អ្នកត្រូវតែណែនាំមេរៀននេះទៅដល់សិស្សទាំងអស់ ហើយផ្តល់កិច្ចការត្រូវធ្វើ ដំបូងដល់ពួកគេ ។ ប្រសិនបើអាចធ្វើបានត្រូវផ្តល់សៀវភៅណែនាំការសិក្សាមួយថ្ងៃឬ ពីរ ថ្ងៃមុនពេលចាប់ផ្តើមការបង្រៀនមុខវិជ្ជានេះ ។
សៀវភៅណែនាំរបស់សិស្សអាចត្រូវផ្តល់ដល់សិស្សពេលនេះតែម្តង ។ អ្នកអាចអោយពួកគេអានទំព័រ ដែលអ្នកនឹងនាំពួកគេអោយទៅរកការសិក្សាសំរាប់មេរៀននេះ ។

**២.** នៅទំព័របន្ទាប់ពីនេះមានបញ្ជីកិច្ចការត្រូវធ្វើមួយសន្លឹក រួមជាមួយនឹងកាលបរិច្ឆេទ នៅពេលណាកិច្ចការត្រូវបានបំពេញរួច ។ ចូរអោយពួកគេបំពេញកាលបរិច្ឆេទអោយបានត្រឹមត្រូវដោយប្រើក្រដាស ស នៅទំព័រនៃបញ្ជីកិច្ចការត្រូវធ្វើនៅខាងក្រោយនៃសៀវភៅណែនាំការសិក្សា ។

**៣.** ជំរាបអោយសិស្សដឹងថា ពួកគេត្រូវបញ្ចប់ គំរោង ទី ១ នៅពេលដែលពួកគេវិលមកចូលរៀនថ្នាក់ដំបូង ។

**៤.** គំរោងមេរៀននិមួយៗផ្តល់អោយមួយ ឬ ច្រើនជាងមួយនូវ " សកម្មភាពចាប់ផ្តើមមេរៀន " ដើម្បីប្រើមុនក្នុងការចាប់ផ្តើមមេរៀននោះ ។ គោលបំណងសំខាន់នៃសកម្មភាពទាំងនេះគឺជំនួយដល់សិស្សអោយយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើចំនុចសំខាន់នៃមេរៀន ។ យើងចង់បង្កើតនូវបរិយាកាសកក់ក្តៅនិងភាពបើកចំហរគ្រប់កន្លែង ដល់សិស្សទាំងអស់អោយមានអារម្មណ៍ល្អដើម្បីចូលរួមក្នុងថ្នាក់រៀន ។

**៥.** អ្នកនឹងត្រូវការសំរេចចិត្តថាតើមានប៉ុន្មានវគ្គដែលអ្នកចង់ប្រើក្នុងការបង្រៀនក្នុងមុខវិជ្ជានេះ ។ មានគំរោងមេរៀនសំរាប់ ១០ វគ្គនៅទំព័របន្តបន្ទាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ មុខវិជ្ជានេះអាចនឹងបានពង្រីកជា ១៤ វគ្គយ៉ាងស្រួល ។ ចំណងជើងទាំង ១០ មេរៀនត្រូវបានធ្វើជាតារាងដូចខាងក្រោម ។ ហើយចំណងជើងដែលមានសញ្ញា (*) នៅខាងមុខវាអាចត្រូវបានចែកជាពីរមេរៀនបាន ។ គំនិតយោបល់ដែលបានផ្តល់អោយនៅក្នុងគំរោងមេរៀន ប្រាប់ពីរបៀបដែលអ្នកអាចបែងចែកមេរៀនជាពីរវគ្គ ។

# បញ្ជីកិច្ចការគ្រូវធ្វើនៅក្នុងថ្នាក់

ចំណងជើងមេរៀនៈ តើខ្ញុំអាចដឹងថា ខ្ញុំជាគ្រីស្ទបរិស័ទដោយរបៀបណា ?

| **សំនួរខ្លីៗ** | **ខចងចាំ** | **កាលបរិច្ឆេទ** |
|---|---|---|
| ១ | សេចក្តីពិត ៨ ចំនុចនៅទំព័រទី ៥ នៃសៀវភៅសំរាប់សិស្ស | មេរៀនទី ២ |
| ២ | រ៉ូម៨ :១៦ | មេរៀនទី ៣ |
| ៣ | យ៉ូហាន ១:១២ | មេរៀនទី ៤ |
| ៤ | យ៉ាកុប១:៥-៦ | មេរៀនទី ៧ |

| **គំរោង** | **ថ្ងៃខែផុតកំណត់** |
|---|---|
| ១ | មេរៀនទី ១ |
| ២ | មេរៀនទី ២ |
| ៣ | មេរៀនទី ៣ |
| ៤ | មេរៀនទី ៣ ឬក៏ ៤ |
| ៥ | មេរៀនទី ៨ |
| ៦ | មេរៀនទី ៤ |
| ៧ | មេរៀនទី ៤ ឬក៏ ៥ |
| ៨ | មេរៀនទី ៥ ឬក៏ ៦ |
| ៩ | មេរៀនទី ៧ ឬក៏ ៨ |
| ១០ | មេរៀនទី ៧ ឬក៏ ៨ |
| ១១ | មេរៀនទី ៧ |
| ១២ | មេរៀនទី ៩ |

**ការប្រលង :** កាលបរិច្ឆេទ មេរៀនទី ១០

# គំរោងមេរៀន ទី ១

## ការប្តេជ្ញាចិត្តខាងចិត្តគំនិត, ការប្តេជ្ញាចិត្តខាងឆន្ទះ

### ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

នៅពេលដែលខ្ញុំយល់ដឹងសេចក្តីពិតមកពីព្រះគម្ពីរអំពីរបៀបក្លាយជាគ្រីស្តបរិស័ទ ខ្ញុំត្រូវការដើរពីមួយជំហានទៅមួយជំហាន ដើម្បីអោយក្លាយទៅជាគ្រីស្តបរិស័ទ ។

### ២. ខគម្ពីរសំខាន់ : យ៉ូហាន ១:១២

*អស់អ្នកដែលបានទទួលព្រះអង្គគឺអស់អ្នកដែលជឿលើនាមព្រះអង្គព្រះអង្គប្រទានអោយគេអាចទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ។*

### ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ៤-៧ ក្នុងសៀវភៅណែនាំរបស់សិស្សស្របគ្នានឹងមេរៀននេះ ។ គំរោងទី ១ ដែលដកស្រង់ ចេញពីសៀវភៅណែនាំការសិក្សាក៏ស៊ីគ្នានឹងមេរៀននេះដែរ ។

### ៤. ការរៀបចំមុនរបស់គ្រូ

#### ក. សម្ភាសន៍ជាមួយនឹងគ្រីស្តបរិស័ទម្នាក់

សំរាប់សកម្មភាពលេខ ១៧ នៅក្នុងផែនការមេរៀននេះ អ្នកចាំបាច់ត្រូវសម្ភាសន៍ជាមួយគ្រីស្តបរិស័ទម្នាក់ ។ អ្នកអាចអោយមនុស្សនេះ អាននូវសៀវភៅណែនាំរបស់សិស្សនៅទំព័រ ទី ៥-១៤ មុនពេលរៀបចំសម្ភាសន៍ ។ ប្រសិនបើអាចធ្វើទៅបាន សូមធ្វើសម្ភាសន៍ជាមួយនឹងមនុស្សនេះផ្ទាល់នៅមុខថ្នាក់តែម្តង ។ ប្រសិនបើមិនអាចធ្វើអញ្ចឹងបានទេ នោះត្រូវ ថតទុកនៅការសម្ភាសន៍នេះ សូមធ្វើអោយប្រាកដថា ទាំងសំនួរ និង ចំលើយរបស់មិត្តភក្តិអ្នកត្រូវតែមានសំលេងច្បាស់ល្អ ។ សូមព្យាយាមកំណត់ពេល នៃការសម្ភាសន៍ពី ១០-១៥ នាទី ។ បើមិនអាចធ្វើបានទេ អ្នកអាចជ្រើសរើសផ្នែកណាមួយនៃការថតសំលេងនោះមកចាក់នៅក្នុងថ្នាក់ ។

អ្នកអាចចំលងសំនួរដែលបានផ្តល់ក្នុងសកម្មភាពលេខ ១៧ សំរាប់សិស្ស ។ ពួកគេអាចប្រៀបធៀបបទពិសោធន៍របស់របស់ពួកគេជាមួយនឹងរឿងក្នុងការសំភាសន៍នេះ ។

#### ខ. តារាងនៃសេចក្តីពិតទាំង ៨

សេចក្តីពិតទាំងប្រាំបី ដែលមនុស្សម្នាក់ៗត្រូវដឹងហើយជឿដើម្បីក្លាយខ្លួនជាគ្រីស្តបរិស័ទ គឺជាចំនុចសំខាន់មួយក្នុងចំនុចសំខាន់ជាច្រើន ដែលយើងចង់លាតត្រដាងនៅក្នុងវគ្គសិក្សាដំបូងនេះ ។

អ្នកអាចរកឃើញ ប្រយោជន៍សំរាប់ការពិភាក្សាក្នុងថ្នាក់ ដោយសរសេរអក្សរធំៗ នៃសេចក្តីពិតទាំង ៨នេះ នៅលើក្រដាស់កាតុង ដើម្បីបង្ហាញនៅក្នុងថ្នាក់រៀនរបស់អ្នក ។ ពិសេសវានឹងមានប្រយោជន៍បើអ្នកបានធ្វើការធ្វើការសម្ភាសន៍ផ្ទាល់សំរាប់សកម្មភាពលេខ ១៧ នៅក្នុងគំរោងមេរៀន ។ សេចក្តីពិតទាំង ៨ ត្រូវបានកត់នៅទំព័រទី ៥ នៃសៀវភៅណែនាំរបស់សិស្ស ។

## ៥. ការចាប់ផ្តើមមេរៀន (៥-១០នាទី)

### ក. មុនដំបូងមានគេសួរអ្នក ប្រសិនអ្នកជាគ្រីស្ទបរិស័ទឬអត់

សូមសួរដល់សិស្សមួយចំនួន ដើម្បីចែកចាយនៅក្នុងថ្នាក់ នៅពេលដំបូងដែលមាននរណាម្នាក់បានសួរពួកគេថាតើគេជាគ្រីស្ទបរិស័ទឬអត់។ តើពួកគេបានឆ្លើយយ៉ាងដូចម្តេច? បើសិនសិស្សរបស់អ្នកភាគច្រើនកើតនៅក្នុងគ្រួសារដែលជាគ្រីស្ទបរិស័ទស្រាប់អ្នកមិនចាំបាច់ហៅគេសួរសំនួរនេះឡើងវិញទេ! ។ អ្នកអាចសួរអ្នកណាម្នាក់ដែលបានធ្វើទីបន្ទាល់ច្រើនហើយដឹងរឿងច្រើនអំពីរបៀបដែលមនុស្សបានឆ្លើយសំនួរនេះ ។

### ខ. តើអ្នកគិតថាអ្វីធ្វើអោយមនុស្សម្នាក់ក្លាយជាគ្រីស្ទបរិស័ទ?

អោយសិស្សអានចំលើយរបស់ពួកគេក្នុងសំនួរលេខ ១ នៅក្នុងគំរោងទី ១ ដែលសួរថា " តើអ្នកគិតថាអ្វីធ្វើអោយមនុស្សម្នាក់ក្លាយជាគ្រីស្ទបរិស័ទ ? " អ្នកអាចពិភាក្សាចំលើយរបស់ពួកគេក្នុងរយៈពេលខ្លី ប៉ុន្តែកុំពិភាក្សាវែងពេកនៅក្នុងចំនុចនេះ ។ កុំរអ៊ូរទាំអំពីចំលើយរបស់សិស្សពេក ។ អ្នកអាចបកស្រាយអោយច្បាស់ពីគំនិតខុសរបស់ពួកគេក្នុងការពិភាក្សានៅពេលក្រោយ ។

## ៦. តើមនុស្សម្នាក់ក្លាយជាគ្រីស្ទបរិស័ទដោយរបៀបណា? ( ៣-៥ នាទី)

ការរីកចំរើនខាងព្រលឹងវិញ្ញាណ របស់សិស្សអ្នកនឹងមានឥទ្ធិពលចំបង ទៅលើរបៀបដែលអ្នកបង្រៀនមេរៀននេះ ។ប្រសិនបើសិស្សរបស់អ្នកភាគច្រើន មិនទាន់ធ្វើការសំរេចចិត្តក្លាយជាគ្រីស្ទបរិស័ទទេអ្នកត្រូវតែប្រយ័ត្នក្នុងការចំណាយពេលវេលា បកស្រាយអោយច្បាស់នូវសំនួរដែលពួកគេអាចមាន ។ កុំសន្មត់ថាមនុស្សគ្រប់គ្នានៅក្នុងថ្នាក់ជាគ្រីស្ទបរិស័ទ ។

បើអ្នកបានដឹងច្បាស់ថា សមាជិកភាគច្រើននៅក្នុងថ្នាក់អ្នកបានចុះចូលនឹងព្រះគ្រីស្ទហើយ លើកទឹកចិត្តពួកគេអោយរៀនមេរៀនផ្នែកនេះដើម្បីរៀបចំខ្លួនធ្វើទីបន្ទាល់។ នៅពេលគេរំលឹកផ្នែកនេះឡើងវិញពួកគេអាចរកផ្លូវដើម្បីយកវាមកពិភាក្សាជាមួយអ្នកមិនទាន់ជឿ ។

អ្នកអាចចាប់ផ្តើមការពិភាក្សា ដោយអោយសិស្សខ្លះ ចែកចាយចំលើយរបស់គេក្នុងសំនួរ លេខ ៣ ពីគំរោងទី ១ ដែលនិយាយថា " តើអ្នកជឿថាព្រះយេស៊ូជាអ្វី ? " សំនួរនេះអោយអ្នកដឹង អំពីការយល់លំអិតរបស់ពួកគេ ដែលអ្នកអាចយកមកពិភាក្សាពីសេចក្តីពិត នៃព្រះគម្ពីរដែលទាក់ទងនឹងផ្នែកនៃមេរៀននេះ ។ កុំពិភាក្សាវែងពេកនៅក្នុងសំនួរនេះឥឡូវនេះ ។ បើមានសិស្សម្នាក់ ឬ ពីរនាក់មានសំនួរថែមទៀតពីចំនុចនេះសូមរៀបចំពេលវេលាដើម្បីពិភាក្សាកិច្ចការនេះជាមួយពួកគេអោយពិស្តារថែមទៀតនៅក្រៅម៉ោងរៀន ។

យើងសូមផ្តល់យោបល់ថាអ្នកមិនចាំបាច់សួរទៅសិស្សអោយលើកដៃ ដើម្បីបង្ហាញចំលើយដែលមាននៅសំនួរលេខ ២ ក្នុងគំរោងទី១ ឡើយដែលសួរថា " តើអ្នកគឺជាគ្រីស្តបរិស័ទឬ ? " នេះគឺជាសំនួរផ្ទាល់ខ្លួនអាចធ្វើអោយពួកគេក្នុងស្ថានភាពពិបាកឆ្លើយ ។ យើងចង់អោយគេមានសេរីភាព ដើម្បីមើលក្នុងមេរៀននេះដោយមិនមានអារម្មណ៍គាបសង្កត់ទោះពួកគេមិនមែនជាគ្រីស្តបរិស័ទក៏ដោយ ។

បញ្ជាក់អំពីចំនុចចំបងដែលមានក្នុងវគ្គដំបូងក្នុងជំពូក ១ នៅលើទំព័រទី ៥ នៃសៀវភៅណែនាំរបស់សិស្ស។ ព្រះជាម្ចាស់មិនដែលតឹងតែងដើម្បីអោយអ្នកណាម្នាក់ក្លាយជាគ្រីស្តបរិស័ទទេ ។បង្ហាញថាមាន៣ផ្នែកទៅនឹងការប្តេជ្ញាចិត្តដែលមនុស្ស ម្នាក់ត្រូវធ្វើ នៅពេលដែលពួកគេក្លាយជាគ្រីស្តបរិស័ទ ។

## ៧. តើអ្វីទៅជាការប្តេជ្ញាចិត្ត? (៣_៥ នាទី )

នៅក្នុងមេរៀនដំបូងពីរ នៃមុខវិជ្ជានេះ យើងនឹងនិយាយអំពីការក្លាយជាគ្រីស្តបរិស័ទ គឺជាការធ្វើការប្តេជ្ញាចិត្តចំពោះ ព្រះគ្រីស្ត ខាងចិត្តគំនិត, ខាងឆន្ទះ និង ខាងអារម្មណ៍ ។ សូមចំណាយពេលវេលានិយាយអំពីការប្តេជ្ញាចិត្តនេះ។ សំរាប់មនុស្សខ្លះ នៅក្នុងចំនុចនេះរាក់មែនទែនចំពោះជីវិតរបស់ពួកគេ ។ ពួកគេមិនគិតពីការរក្សាកិច្ចសន្យាទេ បើពួកគេនៅក្នុងស្ថានភាពតានតឹងនោះ ។ ពិភាក្សាខ្លីៗនូវអ្វីដែលព្រះជាម្ចាស់ចង់បាន ពេលយើងនិយាយអំពីការប្តេជ្ញាចិត្តចំពោះទ្រង់នៅក្នុងជីវិតយើង។

សិស្សខ្លះប្រហែលជាសួរសំនួរអំពី ការអារម្មណ៍ទាក់ទងនៅក្នុងការក្លាយជាគ្រីស្តបរិស័ទដោយរបៀបណា ។ សូមពន្យល់ថា យើងនឹងនិយាយអំពីរឿងនេះនៅក្នុងមេរៀនក្រោយទៀត ។

## ៨. សេចក្តីពិត ទាំង ៨ ដែលទាក់ទងទៅនឹងការប្តេជ្ញាចិត្តខាងចិត្តគំនិតរបស់អ្នក (១០-១៥ នាទី)

សូមមើលបញ្ជីនៃសេចក្តីពិតទាំង ៨ ដែលបានផ្តល់ជូននៅទំព័រទី ៥ នៃសៀវភៅណែនាំរបស់សិស្ស ។ សូមអោយសិស្សមើលហើយអានខគម្ពីរតាមលំដាប់ ។ សូមធ្វើអោយប្រាកដថា ពួកគេយល់ច្បាស់នូវសេចក្តីពិតនៃប្រយោគនិមួយៗ ។

នេះគឺជាសំនួរបន្ថែមខ្លះៗ ដែលអ្នកអាចប្រើនៅក្នុងការពិភាក្សាក្នុងផ្នែកនៃមេរៀននេះ

**ក.** តើការប្តេជ្ញាចិត្តខាងចិត្តគំនិតរបស់អ្នកមានអត្ថន័យយ៉ាងដូចម្តេច ?

**ខ.** តើអ្នកគិតថាមានចំនុចណាមួយក្នុងសេចក្តីពិតទាំង៨ដែលមិនត្រូវការក្នុងការក្លាយខ្លួនទៅជាគ្រីស្ទបរិស័ទនោះ ? បើសិនជាមាន តើចំនុចមួយណា? ចូរពន្យល់ក្នុងចំលើយរបស់អ្នក។

**គ.** តើមានន័យយ៉ាងដូចម្តេច " ការមានជំនឿមិនច្បាស់លាស់ " ?

**ឃ.** តើគំរូនៃការក្លាយខ្លួនជាគ្រីស្ទបរិស័ទតាមព្រះគម្ពីរខុសគ្នាពី "ការមានជំនឿមិនច្បាស់លាស់លាស់យ៉ាងដូចម្តេច?

## ៩. តើព្រះគម្ពីរត្រឹមត្រូវដែរឬទេ? (៥-១០នាទី)

មានសិស្សខ្លះប្រហែលជាពិបាកនឹងយល់ព្រមជាមួយសេចក្តីពិតទាំង ៨ ព្រោះតែការជឿរបស់ពួកគេអំពីព្រះគម្ពីរ ។ សូមអោយសិស្សម្នាក់អានចំលើយរបស់គេនូវសំនួរលេខ ៤ ពីគំរោងទី ១ " តើអ្នកមានការពិបាកជឿថាព្រះគម្ពីរពិតឬទេ ? "ប្រសិនបើសិស្សខ្លះមានសំនួរសំខាន់នៅក្នុងរឿងនេះ អ្នកអាចចំណាយពេលខ្លះពិភាក្សាពីរបៀបដែលយើងដឹងថាព្រះគម្ពីរពិត ។

ប្រធានបទនេះនឹងបកស្រាយយ៉ាងល្អិតល្អន់នៅក្នុងមុខវិជ្ជា *ការមើលព្រះគម្ពីរយ៉ាងលឿន* ដែលជាមុខវិជ្ជាបន្ទាប់ដែលអ្នកនឹងបង្រៀនប្រសិនបើអ្នកធ្វើតាមការបង្រៀនតាមលំដាប់លំដោយដែលត្រូវបានលើកឡើងក្នុងមុខវិជ្ជានេះ។ ប្រសិនបើរឿងនេះជាហេតុផលសំខាន់ ដែលសិស្សរបស់អ្នកកំពុងតែស្ទាក់ស្ទើរក្នុងការក្លាយខ្លួនជាគ្រីស្ទបរិស័ទ នោះសូមយកពេលគិតពីរឿងនេះ ទោះបីជាត្រូវបន្ថែមថ្នាក់ដើម្បីគិតពីរឿងនេះក៏ដោយ។

ប្រសិនបើសិស្សជឿថា ព្រះគម្ពីរមិនពិត ចូរអោយគេពន្យល់ហេតុអ្វីពួកគេមានអារម្មណ៍យ៉ាងដូចនេះ ។ ពេលខ្លះមានបញ្ហាជាមួយការបកប្រែខុសគ្នានៃព្រះគម្ពីរ ។សូមបង្ហាញយ៉ាងលឿនថាគ្មានការបកប្រែណាមួយ " ឥតខ្ចោះ " នោះទេ ។ ការបកប្រែជាច្រើនដែលយើងមានសព្វថ្ងៃល្អណាស់ប៉ុន្តែមានចំនុចខ្សោយខ្លះៗដែរ ។

យើងមិនចាំបាច់មានការភ័យខ្លាចថា គំរោងនៃការសង្គ្រោះគឺត្រូវបានធ្វើអោយខូចដោយសារតែការបកប្រែព្រះគម្ពីរនោះទេ ។ ខ្ញុំតែងតែលើកទឹកចិត្តអោយគេគិតពីភាពធំឧត្តមរបស់ព្រះជាម្ចាស់ ។ បើសិនជាទ្រង់មិនមានលទ្ធភាពរក្សានូវព្រះបន្ទូលពីការខូចខាតទាំងស្រុងដោយការបកប្រែទេ នោះអ្នកមានបញ្ហាជាមួយនឹងព្រះដោយគិត ថាព្រះអង្គតូច ហើយទន់ខ្សោយ ។

នេះគឺជាចំនុចមួយដែលអ្នកអាចពិភាក្សាពីជំនឿ និង ការទុកចិត្តលើព្រះជាម្ចាស់ ។ យើងត្រូវតែពិនិត្យយ៉ាងប្រុងប្រយត្ន័ពីសេចក្តីពិត និង ការប្រើគំនិតរបស់យើង ។ ប៉ុន្តែមានចំនុចមួយដែលការគិតរបស់មនុស្សច្បាស់លាស់ និង សមរម្យបែរ ជាដឹកនាំគេទៅរកសេចក្តីសង្គ្រោះមិនបានសំរេច ។យើងត្រូវតែយល់ព្រមឈានក្នុងសេចក្តីជំនឿ ដោយមិនមានការយល់ដឹងអោយបានពេញលេញថាតើមានអ្វីទាក់ទង ។ នេះមិនមែនដូច " ការមានជំនឿមិនច្បាស់លាស់ " នោះទេ ប៉ុន្តែជាជំហាននៃជំនឿដែលមានមូលដ្ឋាននៅលើការបង្រៀនព្រះបន្ទូលច្បាស់លាស់។ ប្រសិនបើជាមានមនុស្សពិបាកជឿទៅលើព្រះគម្ពីរ ចូរលើកទឹកចិត្តពួកគេអោយថ្វាយការនេះទៅព្រះហើយសុំជំនួយពីទ្រង់ ។

## ១០. តើអ្នកត្រូវយល់ដឹងច្រើនប៉ុណ្ណាដើម្បីក្លាយខ្លួនជាគ្រីស្ទបរិស័ទ? (៣-៥ នាទី)

យើងត្រូវប្រយ័ត្នកុំអោយមានការតឹងតែងថាមនុស្សត្រូវតែយល់ដឹងប៉ុណ្ណេះ ឬក៏ ប៉ុណ្ណោះអំពីផែនការនៃសេចក្តីសង្គ្រោះមុនពេលគេក្លាយជាគ្រីស្ទបរិស័ទ ។ សេចក្តីពិតទាំង ៨ ដែលត្រូវបានបង្ហាញនៅទីនេះគឺជាការ ណែនាំទូទៅប៉ុណ្ណោះ ។ មនុស្សអាចមិនយល់មួយឬក៏ច្រើននៃចំនុចទាំងនេះរហូតដល់គេក្លាយជាគ្រីស្ទបរិស័ទទើបគេយល់ ។ព្រះជាម្ចាស់ជ្រើសរើសសង្គ្រោះអ្នកណាក៏បានអោយតែទ្រង់ចង់សង្គ្រោះគឺនៅពេលដែលគេមករក ព្រះអង្គដោយចិត្តស្មោះសរ ។

ទោះបីយ៉ាងណាក៏ដោយមានមនុស្សខ្លះមាន " បទពិសោធន៍ខាងសាសនា " ដែលពួកគេមានអារម្មណ៍ថាមានរឿងអ្វីមួយកើតឡើងក្នុងចិត្តរួចសន្មតថាគេក្លាយជាគ្រីស្ទបរិស័ទហើយ ។ សូមពន្យល់ថាមនុស្សក្លាយជា គ្រីស្ទបរិស័ទមិនមែនគ្រាន់តែដោយការអធិស្ឋានដែលពួកគេធ្វើនោះទេ ។ សេចក្តីសង្គ្រោះពិតប្រាកដកើតឡើងនៅពេល ព្រះជាម្ចាស់លើកលែងទោសអំពើបាបពួកគេ ហើយយាងមកគង់ក្នុងព្រលឹងវិញ្ញាណរបស់ពួកគេ ។ រឿងនេះក៏ត្រូវបានយកមកពិភាក្សាផងដែរនៅក្នុងសៀវភៅណែនាំរបស់សិស្សក្នុងទំព័រទី ៥ ។

## ១១. សេចក្តីណែនាំនៃការធ្វើការប្តេជ្ញាចិត្តខាងឆន្ទៈរបស់អ្នក (៣-៥ នាទី )

សូមធ្វើអោយប្រាកដថាសិស្សរបស់អ្នកយល់នូវអ្វីដែលយើងកំពុងនិយាយ នៅពេលដែលយើងនិយាយថា " ឆន្ទៈ " របស់អ្នក ។ នេះគឺជាផ្នែកនៃការធ្វើការសំរេចចិត្តនៃបុគ្គលិកលក្ខណៈរបស់អ្នក ។ អ្នកអាចពន្យល់បង្ហាញពីការចាប់កំណើតនៃកូនង៉ែតដើម្បីបង្ហាញភាព ខុសគ្នាពី " ការកើតជាថ្មី " ក្នុងគ្រួសារព្រះជាម្ចាស់ ។ សូមមើលខាងក្រោមទំព័រទី ៦ នៅក្នុងសៀវភៅណែនាំរបស់សិស្សដើម្បីទទួលពត៌មានថែមទៀតពីការពន្យល់បង្ហាញនេះ ។

## ១២. អ្នកត្រូវដឹងថា អ្នកកំពុងធ្វើអ្វី មុនពេលអ្នកធ្វើការសំរេចចិត្ត (៣-៥ នាទី)

សូមបង្ហាញគ្រួស១ពីឯកសារដែលមាននៅក្នុងទំព័រទី ៦ នៃសៀវភៅណែនាំរបស់សិស្ស ក្រោមចំនុចលេខ ១ "*អ្នកត្រូវតែយល់ដឹងពីអត្ថន័យក្នុងការក្លាយជាគ្រីស្ទបរិស័ទ* " ។ ការនេះស៊ីគ្នាទៅជាមួយនឹងអ្វីដែលយើងបានបកស្រាយក្នុងផ្នែកដំបូងនៃមេរៀននេះពីការធ្វើការប្តេជ្ញាចិត្តខាងចិត្តគំនិតរបស់អ្នក ។ ក្នុងចំនុចបញ្ជាក់ទីនេះ គឺព្រះជាម្ចាស់មិនផ្តល់កិត្តិយសចំពោះការសំរេចចិត្តដែលផ្អែកលើភាពល្ងង់ខ្លៅនោះទេ ។

## ១៣. តើអ្នកធ្វើការសំរេចចិត្តសំខាន់ៗដោយរបៀបណា ? (៥ នាទី)

សំនួរលេខ៥ក្នុងគំរោងទី ១ គឺជាសកម្មភាពមួយដែលជួយអោយសិស្សស្គាល់អ្វីគឺជាដំណើរការគាត់ធ្វើនៅពេលដែលធ្វើការសំរេចចិត្តសំខាន់។ សូមអោយសិស្សចែកចាយចំលើយរបស់ពួកគេទៅសកម្មភាពនោះ ។ចង្អុលបង្ហាញពីសារៈសំខាន់នៃរឿងនេះ ថាតើងាយស្រួលឬក៏ពិបាកប៉ុណ្ណាសំរាប់មនុស្សខ្លះធ្វើការសំរេចចិត្ត និង របៀបទាក់ទងនឹងការប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ។

ក្នុងនាមជាគ្រូបង្រៀន អ្នកត្រូវតែទទួលស្គាល់ថាសិស្សរបស់អ្នកភាគច្រើន មិនប្រើរបៀបដូចគ្នាទេក្នុងការធ្វើសេចក្តីសំរេចចិត្ត។ សូមគិតពីលទ្ធផលនៃការប្រើប្រភេទផ្សេងៗក្នុងការធ្វើការសំរេចចិត្តក្នុងការប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ ។ សូមគិតពីលទ្ធផលវិជ្ជមាន និង អវិជ្ជមាននៃរបៀបនិមួយៗ ។

ឧទាហរណ៍ មនុស្សដែលឆាប់ធ្វើការសំរេចចិត្ត អាចងាយស្រួលចុះចូលក្នុងការធ្វើការប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ ។ ប៉ុន្តែតើការប្តេជ្ញាចិត្តនោះនៅយូរប៉ុណ្ណា? តើពួកគេនឹងមានការសង្ស័យយ៉ាងឆាប់រហ័សអំពីប្រាជ្ញានៃការសំរេចនោះឬទេ ? តើ " មនុស្សដែលម៉ត់ចត់ " មាននូវសំនួរដែលធ្វើអោយអ្នកពិបាកនឹងឆ្លើយឬទេ? ប្រសិនបើអ្នកមានសិស្សដូចនេះ ការសំរេចចិត្តរបស់គាត់គឺវិជ្ជមានមនុស្សនេះនឹងមិនបោះបង់ចោលការសំរេចចិត្តដែលគាត់បានធ្វើនោះដោយងាយៗនោះទេ ។

ប្រសិនបើអ្នកមានពេលនៅចុងម៉ោងនៃមេរៀននេះ អ្នកអាចពិភាក្សាអោយលំអិតបាន ។ សំនួរលេខ ៧ និង លេខ ៨ នៅក្នុងគំរោងទី ១ គឺលាតត្រដាងនូវកំរិតផ្ទាល់ខ្លួនច្រើនជាង ។ សូមអ្នកសួរសំនួរទាំងនេះឡើងវិញនៅពេលអ្នកផ្តល់ពិន្ទុក្នុង គំរោងទី ១ ដើម្បីកំណត់ថាតើសិស្សណាមួយក្នុងចំណោមសិស្សទាំងអស់ដែលត្រូវការជួយបំភ្លឺថែមទៀតនៃរឿងផ្ទាល់ខ្លួននេះ ។

## ១៤. អ្នកត្រូវតែធ្វើការសំរេចចិត្ត ( ៣-៥ នាទី )

ចង្អុលបង្ហាញថា ពួកគេមិនអាចគ្រាន់តែសិក្សាពីសេចក្តីពិតនៅក្នុងព្រះគម្ពីរ ហើយសន្មតថាការយល់ដឹងពីសេចក្តីពិតគឺគ្រប់គ្រាន់ហើយនោះទេ ។ ពួកគេត្រូវតែជ្រើសរើសយកនរណាជាអ្នកដឹកនាំក្នុងជីវិតរបស់ពួកគេ ព្រះជាម្ចាស់ ឬក៏ អារក្សសាតាំង ។រឿងនេះក៏មាននិយាយនៅទំព័រទី ៧នៃសៀវភៅណែនាំរបស់សិស្សក្រោមចំនុចទី ២ " *អ្នកត្រូវតែធ្វើការសំរេចចិត្តក្នុងការក្លាយជាគ្រីស្ទបរិស័ទ* " ។

## ១៥. ធ្វើតាមការសំរេចចិត្តរបស់អ្នក ( ៣-៥ នាទី )

អ្នកអាចគូសបង្ហាញពីការងាយស្រួលក្នុងការសន្យា ហើយពេលខ្លះពិបាកក្នុងការរក្សានូវការសន្យានោះ - ធ្វើអ្វីដែលអ្នកសន្យាធ្វើ ។ ពេលមនុស្សនិយាយថា " ខ្ញុំចង់ក្លាយជាគ្រីស្ទបរិស័ទ " វាស្រួលណាស់គ្រាន់តែនិយាយពាក្យពីរបីម៉ាត់នោះ ។ ប៉ុន្តែយើងម្នាក់ៗត្រូវតែធ្វើតាមអ្វីដែលយើងបានសំរេចចិត្តធ្វើទាល់តែបានសំរេច ។

សូមពន្យល់អ្វីដែលទាក់ទងទាំងអស់ក្នុងការធ្វើតាមសំរេចចិត្តនេះទាល់តែបានសំរេច

- អ្នកត្រូវតែសារភាពអំពើបាបរបស់អ្នកដល់ព្រះជាម្ចាស់ ហើយសុំទ្រង់អត់ទោសអោយអ្នក ។
- អ្នកត្រូវតែសុំយាងព្រះយេស៊ូអោយក្លាយជាអ្នកដឹកនាំជីវិតរបស់អ្នក ។ នេះមានន័យថាប្រគល់ជីវិតទៅលើព្រះអង្គ។
- អ្នកត្រូវងាកចេញពីផ្លូវដែលពេញទៅដោយអំពើបាបរបស់អ្នក និង ចាប់ផ្តើមស្តាប់បង្គាប់វិន័យ និង ការបង្រៀនរបស់ទ្រង់ ។

សូមពិភាក្សាចំណុចនៅក្នុង គម្ពីរ យ៉ាកុប ២ : ២៤ ដែលថាសេចក្តីសង្គ្រោះជាប់ទាក់ទងច្រើនជាងការនិយាយ ប៉ុន្តែវាជាប់ទាក់ទងនឹងសកម្មភាពរបស់យើងផងដែរ។

ប្រហែលអ្នកអាចប្រើរឿងក្នុងព្រះគម្ពីរ អំពីអ្នកដឹកនាំក្មេងជាអ្នកមានដែលបានមកជួបព្រះយេស៊ូ សួរទ្រង់ថាតើគាត់អាចទទួលជីវិតអស់កល្បយ៉ាងដូចម្តេច ។ មើល លូកា ១៨ :២៣-៣០, ម៉ាថាយ ១៩:១៦-៣០ និង ម៉ាកុស ១០:៧-៣១ ។ សូមចង្អុលបង្ហាញថាព្រះយេស៊ូមិនបានអោយបុរសនោះគ្រាន់តែអធិស្ឋានប៉ុណ្ណោះទេ ។ ទ្រង់អោយគាត់មានសកម្មភាព " សូមបោះបង់ចោលទ្រព្យសម្បត្តិរបស់អ្នក និង មកដើរតាមខ្ញុំ " បុរសនោះមិនសុខចិត្តធ្វើតាមសកម្មភាពនោះទេ ការនេះសបញ្ជាក់ឱ្យឃើញថា គាត់មិនច្បាស់លាស់អំពីការថ្វាយជីវិតរបស់គាត់ដល់ព្រះយេស៊ូ ។

## ១៦. ចុះប្រសិនបើអ្នកបរាជ័យ និង ធ្វើអំពើបាប (៣~៥ នាទី )

សូមចង្អុលបង្ហាញថា ការប្តេជ្ញាចិត្តរបស់អ្នកចំពោះព្រះគ្រីស្ត មិនមែនផ្តល់អោយអ្នកមានសេរីភាពចេញទៅខាងក្រៅ និង ធ្វើខុសវិន័យរបស់ព្រះគ្រប់ពេលវេលា អ្នកចង់ធ្វើនោះទេ ។ ផ្ទុយទៅវិញ មនុស្សមិនមែនទទួលការសង្គ្រោះគ្រប់ពេលដែល គាត់ធ្វើបាបម្តងហើយម្តងទៀតនោះទេ ។ ចូរពិភាក្សាពីសារៈសំខាន់នៃការខិតខំរបស់អ្នកដើម្បីបំពេញតួនាទីទទួលខុសត្រូវក្នុងការប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ត ។ ព្រះជាម្ចាស់បានសន្យាថា នឹងផ្តល់អោយយើងមានកំលាំង ដើម្បីប្រឆាំងនឹងការល្បួង ហើយរស់នៅដើម្បីទ្រង់ ។ ទោះជាយ៉ាងណាក៏ដោយសូមចង្អុលបង្ហាញថា ការធ្វើការសំរេច ចិត្តដើម្បីក្លាយជាគ្រីស្តបរិស័ទមិននាំទៅរកភាពល្អឥតខ្ចោះរហូតទេ ។ យើងទាំងអស់គ្នាធ្វើខុសប៉ុន្តែយើងក៏មានឱកាសរៀនពីកំហុសរបស់យើង ហើយខិតចូលកាន់តែ ជិតព្រះជាម្ចាស់ថែមទៀតផង ។

## ១៧. ការសម្ភាសន៍ជាមួយគ្រីស្តបរិស័ទ ( ១០~២០ នាទី )

យើងចង់នាំយកនូវពតិមាននេះមកធ្វើការអនុវត្តន៍ក្នុងវគ្គសិក្សានេះ ។ ការសម្ភាសន៍ជាមួយគ្រីស្តបរិស័ទ គឺជាផ្លូវល្អមួយដើម្បីជួយអោយសិស្សយល់ពីរបៀបនៃការប្តេជ្ញាចិត្តខាងចិត្តគំនិត និង ខាងឆន្ទៈដែលដោះស្រាយនៅក្នុងជីវិតមនុស្ស ។ កំណត់សំគាល់នៅដើមដំបូងនៃគំរោងមេរៀនដែលបានផ្តល់យោបល់ថា អ្នកត្រូវរៀបចំមុនថាតើអ្នកណាដែលអ្នកសម្ភាសន៍ ។

បើអាចធ្វើទៅបានធ្វើការសម្ភាសន៍ផ្ទាល់នៅខាងថ្នាក់របស់អ្នក ។ ធ្វើដូច្នេះអ្នកអាចគ្រប់គ្រងពេលវេលានៃការសម្ភាសន៍ ថាតើអ្នកនៅសល់ពេលប៉ុន្មានទៀត ។ ត្រូវដឹងច្បាស់ថា អ្នកជាអ្នកគ្រប់គ្រងទៅលើការសម្ភាសន៍។ ប្រាប់អ្នកដែលត្រូវសម្ភាសន៍ថាសូមប្រាប់សិស្សត្រូវឆ្លើយនូវសំនួរខ្លីៗ កុំលើសពី២ ទៅ ៣ នាទីក្នុង ចំលើយមួយៗ ។ បើសិនអ្នកចង់បានការលំអិត អ្នកអាចសួរថា " តើអ្នកអាចពន្យល់អោយបានក្បោះក្បាយបន្តិចបានទេ ? "

## សំណួរសំរាប់ធ្វើការសម្ភាសន៍

១. តើមុនដំបូងអ្នកបានឮអំពីសេចក្តីពិតជាមូលដ្ឋានពីរបៀបក្លាយជាគ្រីស្តបរិស័ទដោយរបៀបណា?

២. តើសេចក្តីពិត ទាំង ៨ ណាមួយ ( នៅទំព័រ ៥ នៃសៀវភៅណែនាំរបស់សិស្ស ) ដែលត្រូវបានពន្យល់យ៉ាងច្បាស់ដល់អ្នក មុនពេលអ្នកក្លាយជាគ្រីស្តបរិស័ទ ?

៣. តើចំនុចណាមួយនៃសេចក្តីពិតទាំង ៨ ដែលមិនត្រូវបានពន្យល់យ៉ាងច្បាស់ដល់អ្នករហូតអ្នកក្លាយជាគ្រីស្តបរិស័ទទើបយល់ច្បាស់ ? តើការនេះធ្វើអោយអ្នកច្របូកច្របល់នៅក្នុងចិត្ត អំពីអត្ថន័យនៃការក្លាយជាគ្រីស្តបរិស័ទឬទេ ?

សំណួរខាងក្រោមអាចជួយបង្ហាញអោយច្បាស់ ពីភាពខុសគ្នារវាងការប្តេជ្ញាចិត្តខាងចិត្តគំនិត និង ការប្តេជ្ញាចិត្តខាងឆន្ទៈ ។

៤. តើវាពិបាកយ៉ាងម៉េចខ្លះសំរាប់អ្នកក្នុងការជឿថា អ្នកគឺជាមនុស្សបាបហើយត្រូវការ ជំនួយពីព្រះជាម្ចាស់ដើម្បីអោយក្លាយជាគ្រីស្តបរិស័ទ?

៥. តើវាពិបាកទេសំរាប់អ្នកក្នុងការទទួលស្គាល់ថា ព្រះគម្ពីរគឺសេចក្តីពិត ? ចូរពន្យល់ថាហេតុអ្វីអ្នកយល់យល់ដូច្នេះ ឬ ហេតុអ្វីអ្នកមិនយល់ដូច្នេះ ។

៦. នៅពេលអ្នកដឹងថា អ្នកជាមនុស្សមានបាប ហើយដឹងពីរបៀបក្លាយជាគ្រីស្តបរិស័ទ តើវាបានចំណាយពេលវេលាប៉ុន្មានទើបដល់ចំនុចដែលនិយាយថា " បាទ ឬ ចាស ខ្ញុំ ចង់ក្លាយជាគ្រីស្តបរិស័ទ ? "

៧. ពេលអ្នកនិយាយ " បាទឬ ចាស ខ្ញុំចង់ក្លាយជាគ្រីស្តបរិស័ទ " តើអ្នកអធិស្ឋានទៅព្រះភ្លាមហើយសុំទ្រង់អោយសង្គ្រោះអ្នកឬ ? បើអត់ តើអស់រយៈពេលប៉ុន្មានទើបអ្នកអធិស្ឋាន ?

៨. បន្ទាប់ពីអ្នកអធិស្ឋាន តើអ្នកមានសំនួរ ឬមានការសង្ស័យ ថាតើអ្នកពិតជាគ្រីស្តបរិស័ទឬអត់ទេ ?

៩. បន្ទាប់ពីធ្វើការអធិស្ឋានតើអ្នកមានការពិបាកនៅជាប់ជាមួយការសំរេចចិត្តរបស់អ្នកក្នុងការក្លាយជាគ្រីស្តបរិស័ទទេ ?

១០. ភ្លាមៗនោះតើអ្នកមានអារម្មណ៏ប្លែក នៅពេលអ្នកអធិស្ឋានសុំព្រះយេស៊ូដើម្បីក្លាយជាអ្នកដឹកនាំនៃជីវិតរបស់អ្នកឬ? បើអ្នកមានអារម្មណ៏កាន់តែប្រសើរឡើង តើការមានអារម្មណ៏បែបនោះនៅយូរប៉ុណ្ណា ?

អ្នកអាចឱ្យសិស្សនៅក្នុងថ្នាក់ប្រៀបធៀបបទពិសោធន៏របស់ពួកគេជាមួយមនុស្សដែលកំពុងត្រូវគេសម្ភាសន៏ ។ អ្នកអាចថតចំលងសំនួរទាំងនេះសំរាប់សិស្សរបស់អ្នកបើអ្នកចង់ធ្វើ ។

ប្រសិនបើអ្នកមានពេលវេលា សូមអនុញ្ញាតអោយសិស្សសួរសំនួរដល់មនុស្សដែលអ្នកកំពុងសម្ភាសន៏ ។ សូមធ្វើឱ្យប្រាកដថាអ្នកបញ្ចប់នូវការសម្ភាសន៏តាមពេលកំណត់ដោយភ្ជាប់ជាមួយនៅសកម្មភាពអនុវត្តន៏ផ្ទាល់ខ្លួនរបស់អ្នក ។

ការពិភាក្សាគួរតែធ្វើឡើងអោយច្បាស់ថា យើងទាំងអស់គ្នាមានបទពិសោធន៍ ខុសគ្នាក្នុងការក្លាយខ្លួនជាគ្រីស្តបរិស័ទ ។យើងម្នាក់ៗបានរៀនយល់ដឹងពីសេចក្តីពិតក្នុងការក្លាយខ្លួនជាគ្រីស្តបរិស័ទ ។ យើងម្នាក់ៗជួបប្រទះនូវការសំរេចចិត្ត " ឥឡូវនេះ តើខ្ញុំនឹងធ្វើអ្វីជាមួយផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់? " ចិត្តគំនិត និង ឆន្ទៈរបស់យើងនឹងទាក់ទងយ៉ាងច្បាស់ក្នុងការក្លាយខ្លួនជាគ្រីស្តបរិស័ទ ។

## ១៨. ការអនុវត្តន៍ផ្ទាល់ខ្លួន ( ៥-១០ នាទី )

អោយសិស្សចំលងសេចក្តីពិតទាំង ៨ ពីទំព័រទី ៥ ពីសៀវភៅណែនាំរបស់សិស្ស ហើយឆ្លើយទៅសំនួរនិមួយៗវិញដោយសរសេរពីក្រោយសំនួរនូវប្រយោគទាំងបីខាងក្រោមនេះដោយរើសយកមួយសំរាប់សំនួរនិមួយៗ :

- ខ្ញុំជឿការនេះ
- ខ្ញុំមិនជឿការនេះ
- ខ្ញុំមិនច្បាស់ទេ

សកម្មភាពនេះនឹងជួយសិស្សធ្វើការវាយតំលៃ ថាតើពួកគេបានធ្វើការប្តេជ្ញាចិត្តខាងចិត្តគំនិតរបស់គេទៅនឹងសេចក្តីជំនឿខាង គ្រីស្តបរិស័ទនេះ ឬក៏អត់ ។

## ១៩. កិច្ចការត្រូវធ្វើ

១. ដាក់ពិន្ទុ គំរោង ទី ១

២. ប្រាប់ពួកគេអោយទន្ទេញសេចក្តីពិតទាំង ៨ សំរាប់សំនួរខ្លី នៅមេរៀនបន្ទាប់ ។

## ២០. ការវាយតំលៃរបស់គ្រូបន្ទាប់ពីការបង្រៀន

សូមធ្វើការកត់ចំណាំខ្លីៗ ក្នុងផ្នែកណានៃមេរៀនដែលមានប្រយោជន៍បំផុត ។ តើអ្នករក្សានូវពេលកំណត់ដែលអ្នកបានរៀបចំសំរាប់សកម្មភាពនិមួយៗដោយរបៀបណា ?

តើការផ្លាស់ប្តូរអ្វីខ្លះដែលអ្នកត្រូវធ្វើក្នុងសកម្មភាពសម្ភាសន៍ (លេខ១៧ ក្នុងគំរោងមេរៀន)? តើសំនួរណាដែលអ្នកត្រូវបោះបង់ចោល ឬក៏ បន្ថែមដើម្បីធ្វើអោយវាមានជ័យជំនះថែមទៀតនៅពេលអ្នកបង្រៀនលើកក្រោយ ?

# មេរៀន ទី ២

## ការប្តេជ្ញាចិត្តខាងអារម្មណ៍

### ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំត្រូវមានការយល់ដឹងច្បាស់លាស់ពីរបៀបនៃអារម្មណ៍របស់ខ្ញុំនៅពេលដែលខ្ញុំក្លាយជាគ្រីស្តបរិស័ទ ។

### ២. ខ គម្ពីរសំខាន់

**យ៉ាកុប ១:៩**

*សូមអោយបងប្អូនដែលក្រីក្របានខ្ពស់មុខឡើង ដោយព្រះជាម្ចាស់លើកតម្កើងគេហើយ ។*

### ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រទី ៨ ដល់ ទី១៦ នៃសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោង ទី ២ "អារម្មណ៍របស់ខ្ញុំ " មកពីសៀវភៅណែនាំសិក្សាក៏នឹងត្រូវប្រើជាមួយមេរៀននេះដែរ ។

### ៤. ការរៀបចំទុកជាមុនរបស់គ្រូ

**ក. ជំរើសពីរវគ្គក្នុងការបង្រៀន**

មេរៀននេះអាចនាំអោយមានការពិភាក្សា មួយនៃរឿងរ៉ាវជាច្រើនដែលទាក់ទងទៅនឹង តួនាទីនៃអារម្មណ៍ដែលមានក្នុងជីវិតជាគ្រីស្តបរិស័ទ ។ អ្នកអាចដាក់ការបង្រៀនជាពីរវគ្គ ដើម្បីបញ្ចប់ឯកសារក្នុងមេរៀននេះ ប្រសិនបើអ្នកមានពេល ។ ភ្លាមៗនោះដោយធ្វើតាមផែនការមេរៀននេះ អ្នកនឹងឃើញពត៌មានបន្ថែមនៅក្នុង សៀវភៅកំនត់ហេតុរបស់គ្រូដែលបានលាតត្រដាងនៅពេលនេះតែម្តង ។ សូមមើល ទំព័រ ទី ២៨-៣០ ។

**ខ. បញ្ជាំងស្លាដឬបង្ហាញរូបភាពសំរាប់សកម្មភាពផែនការមេរៀន លេខ ១០**

សកម្មភាពលេខ ១០ នៅក្នុងផែនការមេរៀននេះ ស្នើសុំអោយអ្នកយករូបភាព ឬ ស្លាដបញ្ចាំងជារូបភាពនៃផ្ទះមួយដែលបង្ហាញជាដំណាក់កាលផ្សេងៗគ្នានៃការសាងសង់ ។ រូបភាពដែលមានតំលៃពិសេសគួរតែរូបភាពនៃគ្រឹះអាគារ ជាន់នៅក្រោមដី ជញ្ជាំង ដំបូល ផ្ទះដែលបានសាងសង់រួច និងចុងបញ្ចប់អាចបង្ហាញរូបភាពពិតនៃចង្ក្រានមួយ ។ ប្រសិនបើអ្នកមិនអាចយករូបភាពផ្ទះ ដែលទើបតែបានសាងសង់រួចរាល់ហើយនោះទេ អ្នកអាចរកមើលនៅក្នុងបណ្ណាគារសាធារណៈប្រហែលជាមាន សៀវភៅជាច្រើនអំពីរូបភាព នៃការសាងសង់ផ្ទះ ។

# ៥. ការចាប់ផ្តើមមេរៀន

## ក. សំនួរខ្លីៗអំពីអារម្មណ៍

ផ្តល់សំនួរខ្លីៗខាងក្រោមមុនពេលចាប់ផ្តើមបើកការបង្រៀន ។ ប្រាប់ដល់សិស្សរបស់អ្នកថា នេះជាសំនួរចំលើយផ្ទាល់ខ្លួន ។ ពួកគេនឹងមិនបានទទួលការដាក់ពិន្ទុលើចំណោទសួរនេះទេ ។ គោលបំណងគឺអោយពួកគេមានឱកាសគិតអំពីអារម្មណ៍របស់ពួកគេ និង ចំនុចណាខ្លះដែលពួកគេមានក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។

អ្នកអាចថតចំលងនូវសំនួរខ្លីៗទាំងនេះ រួចផ្តល់ជូនដល់សិស្សចំនួនមួយសន្លឹកក្នុង ១ ម្នាក់ៗ ។ ឬអ្នកអាចបញ្ចាំងវាលើម៉ាស៊ីនបញ្ចាំងស្លាយ ។

សំនួរខ្លីអំពីអារម្មណ៍

ត្រូវ ខុស ១. គ្រីស្តបរិស័ទដែលមានការស្និទ្ធស្នាលជាមួយព្រះជាម្ចាស់នឹងទទួលអារម្មណ៍សប្បាយគ្រប់ពេល ។

ត្រូវ ខុស ២. ការទប់កំហឹងរបស់អ្នកទុកក្នុងចិត្តប្រសើរជាងអោយវាផ្ទុះចេញជាសកម្មភាព ។

ត្រូវ ខុស ៣. ពេលដែលគ្រីស្តបរិស័ទមានការគ្រៀមក្រំច្បាស់ជាមាន អ្វីខុសជាមួយនឹងជីវិតព្រលឹងវិញ្ញាណរបស់គាត់ហើយ ។ (ទំនាក់ទំនងរបស់គាត់ជាមួយព្រះជាម្ចាស់)

ត្រូវ ខុស ៤. គ្រីស្តបរិស័ទថ្មីអាចរក្សាវិញ្ញាណក៏រិតខ្ពស់ដែលធម្មតាតាមការសន្ទនារបស់ពួកគេ ប្រសិនបើពួកគេស្តាប់បង្គាប់វិន័យរបស់ព្រះជាម្ចាស់យ៉ាងប្រុងប្រយត្ន័នោះ ។

នៅសំនួរ ៤ បន្ទាប់មកទៀតនេះ សូមគូសរង្វង់ជុំវិញចំលើយណាដែលជាការពិពណ៌នាអំពីអ្នកល្អបំផុត និង អារម្មណ៍របស់អ្នក ។ សំនួរជាច្រើនមានចំលើយដែលត្រឹមត្រូវច្រើនជាងមួយ ។

៥. នៅពេលដែលអ្នកណាម្នាក់ធ្វើឱ្យខ្ញុំឈឺចាប់ ឬខឹង ខ្ញុំមានការពិបាកប្រាប់គាត់អំពីអារម្មណ៍របស់ខ្ញុំណាស់ ។

**ត្រូវ មិនសូវត្រូវ មិនត្រូវ**

៦. ខ្ញុំតែងតែបង្ហាញនូវអារម្មណ៍របស់ខ្ញុំយ៉ាងឆាប់ (សំដែងចេញជាអំពើ) ។

**ត្រូវ មិនសូវត្រូវ មិនត្រូវ**

៧. ខ្ញុំតែងតែលាក់ទុកអារម្មណ៍របស់ខ្ញុំក្នុងចិត្ត ហើយមិនបង្ហាញវាចេញមកក្រៅទេ ។

**ត្រូវ មិនសូវត្រូវ មិនត្រូវ**

៨. វាជាការពិបាកសំរាប់ខ្ញុំក្នុងការប្រាប់ដល់ព្រះជាម្ចាស់នៅពេលដែលខ្ញុំមានអារម្មណ៍ពិបាកចិត ឬក៏ក្រៀមក្រំចិត្ត ។

**ត្រូវ មិនសូវត្រូវ មិនត្រូវ**

បន្ទាប់ពីសិស្សបានបំពេញសំនួរខ្លីៗហើយ សូមពិភាក្សានូវចំលើយរបស់ពួកគេដោយសង្ខេប ។ បើសិនជា សិស្សមានចំលើយខុស ក្តាប្រាប់គេថាវាមិនអីទេ ។ សូមសួរពួកគេអោយពន្យល់ដោយសង្ខេបថាតើហេតុអ្វីបានជាជ្រើសរើសយកចំលើយនោះ ។ ចំនុចមួយដែលយើងចង់ទាក់ទងតាមរយៈសកម្មភាពនេះ គឺត្រូវគិតពិចារណា អំពីអារម្មណ៍របស់យើង ហើយមើលថាវាស្ថិតនៅចំនុចណា នៃជីវិតគ្រីស្ទបរិសទ័ថ្មីរបស់យើង ។ នៅក្នុងពេលជាមួយគ្នានេះដែរ យើងចង់បញ្ជាក់ថាមនុស្សត្រូវបានបង្កើតយ៉ាងពិសេស ដែលយើងមិនទទួលអារម្មណ៍ដូចគ្នានៅក្នុងជីវិតឡើយ ។

## ខ. ការបង្ហាញពីកូនង៉ែតទើបកើត

មនុស្សពេញវ័យ និង កូនក្មេងភាគច្រើនតែងតែសំដែងចេញនូវអារម្មណ៍ ពេលដែលពួកគេនៅជិតកូនង៉ែតទើបកើត ។ សូមសួរសិស្សអោយគិតអំពីកំណើតរបស់កូនង៉ែត ។ សូមអោយគេចាត់ទុកខ្លួនគេថាជាម្តាយជាឪពុកជាវេជ្ជបណ្ឌិត ជាគិលានុបដ្ឋាយិកា ជាជីដូនជីតា ជាបងប្អូនប្រុសស្រីរបស់កូនង៉ែតដែលទើបកើត ។ តើអ្នកមានអារម្មណ៍ដូចម្តេចដែរពេលដែលអ្នកឃើញកូនង៉ែតដំបូង? សូមអោយសិស្សចែកចាយចំលើយរបស់គេនៅក្នុងថ្នាក់ ។

បង្ហាញថាមនុស្សដែលទាក់ទងជាមួយកូនង៉ែតនោះ អាចមានអារម្មណ៍ផ្សេងៗពីគ្នា ទោះបីវាជាព្រឹត្តិការណ៍ដូចគ្នាក៏ដោយ ។

កំណើតខាងរាងកាយរបស់កូនង៉ែត វាស្រដៀងគ្នាខ្លះ ទៅនឹងការកើតខាងព្រលឹងវិញ្ញាណរបស់គ្រីស្ទបរិស័ទថ្មីផងដែរ ។ កូនង៉ែត ភាគច្រើនចាប់យំភ្លាមបន្ទាប់ពីកើតមក ។ ក្នុងសប្តាហ៍ និង ខែដំបូងពោរពេញទៅដោយបទពិសោធន៍ថ្មីៗ ភាគច្រើននៃបទពិសោធន៍ទាំងអស់មិនមានអំណរប៉ុន្មានទេ ។ ជីវិតកូនង៉ែតគឺពោរពេញដោយការយំយ៉ាងឈឺចាប់ ការខកចិត្ត មានអារម្មណ៍ថាខុសកន្លែង ត្រជាក់ខ្លាំង ក្តៅខ្លាំង មានអារម្មណ៍វេទនាយ៉ាងច្បាស់ ។ កូនង៉ែតមានពេលលំបាកជាមួយការសំរបខ្លួនក្នុងការផ្លាស់ប្តូរជីវិតថ្មី ។ មនុស្សចាស់ទាំងអស់ដែលនៅជុំវិញវាហៅការនេះថា " ភាពរីកធំធាត់ឡើង " ។

ជាច្រើនដងគ្រីស្ទបរិស័ទថ្មីឆ្លងកាត់ការឈឺចាប់ស្រដៀងគ្នានេះដែរ គឺដកពិសោធន៍ខាងការខកចិត្ត ព្យាយាមសំរបជីវិតថ្មីជាគ្រីស្ទបរិស័ទ ។ ច្បាស់ណាស់ថា វាមិនពេញដោយអំណររហូតនោះទេ ។ ថ្ងៃនេះ នៅក្នុងមេរៀនយើង យើងនឹងធ្វើការពិនិត្យអោយច្បាស់ថែមទៀតពីអារម្មណ៍របស់យើងយ៉ាងណា ក្នុងការក្លាយខ្លួនជាគ្រីស្ទបរិស័ទ ហើយកន្លែងណាវាគួរតែមាននៅក្នុងជីវិតថ្មីរបស់យើង ។

## ៦. រំលឹកឡើងវិញពីការប្តេជ្ញាចិត្តខាងចិត្តគំនិត និង ឆន្ទៈ (៣~៥នាទី)

សិស្សភាគច្រើនមានការលំបាកក្នុងការចងចាំនូវចំនុចចំបងដែលអ្នកបានបង្ហាញក្នុងការប្តេជ្ញាចិត្តទាំងបីនេះ ។ សំរាប់វគ្គ សិក្សាពីរ ឬ បីបន្ទាប់ពីនេះទៀត សូមរំលឹកពីរបីនាទីអំពីការប្តេជ្ញាចិត្តពីរចំនុចដែលបានបង្ហាញក្នុងវគ្គសិក្សាដំបូង គឺការប្តេជ្ញាចិត្តខាងចិត្តគំនិត និង ខាងឆន្ទៈ ។ សូមអោយសិស្សពន្យល់នូវអ្វីដែលទាក់ទងនឹងចំនុចនិមួយៗ ។ ប្រើវិធីនេះដើម្បីចូលទៅក្នុងការ ប្តេជ្ញាចិត្តចំនុចទីបី ដែលយើងនឹងរៀននៅថ្ងៃនេះ គឺការប្តេជ្ញាចិត្តខាងអារម្មណ៍ ។

## ៧. ការណែនាំពីការប្តេជ្ញាចិត្តខាងអារម្មណ៍ (៣~៥នាទី)

ការចាប់ផ្តើមសកម្មភាពមេរៀនគួរតែនាំការយកចិត្តទុកដាក់របស់ពួកគេទៅនឹងអារម្មណ៍ ។នេះគឺជាសំនួរខ្លះៗ ដែលយើងសង្ឃឹមថានឹងឆ្លើយក្នុងវគ្គសិក្សាថ្ងៃនេះ ។ (កុំព្យាយាមឆ្លើយវានៅពេលនេះ ។ ចែកចាយវានៅក្នុងថ្នាក់ ដើម្បីផ្តល់នូវគំនិត ដល់ពួកគេ នៃរឿងរ៉ាវដែលយើងសង្ឃឹមថាត្រូវដោះស្រាយនៅថ្ងៃនេះ ) ។

. តើកន្លែងណាដែលអារម្មណ៍របស់យើងមាននៅក្នុងបទពិសោធន៍នៃការក្លាយខ្លួនជាគ្រីស្ទបរិស័ទ?

. តើអារម្មណ៍របស់យើងសំខាន់យ៉ាងណា?

. តើខ្ញុំគួរតែមានអារម្មណ៍ខុសប្លែកទេ បន្ទាប់ពីក្លាយខ្លួនជាគ្រីស្ទបរិស័ទ?

. តើខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់គង់ក្នុងជីវិតរបស់ខ្ញុំទេ បន្ទាប់ពីក្លាយខ្លួនជាគ្រីស្ទបរិស័ទ?

## ៨. តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចពេលអ្នកក្លាយជាគ្រីស្ទបរិស័ទ? (៥~១០នាទី)

យោងទៅតាមការពន្យល់បកស្រាយ ដែលបានប្រើនៅក្នុងសកម្មភាពចាប់ផ្តើមមេរៀន ដែលធ្វើអោយមានការរីកញែក ស្តីអំពីរបៀបដែលមនុស្សមានអារម្មណ៍ខុសផ្លែកគ្នានៅក្នុងស្ថានភាពដូចគ្នា ។ នេះពិតជាត្រឹមត្រូវដូចដែលមនុស្សធ្វើការសំរេចចិត្តក្លាយជាគ្រីស្ទបរិស័ទ ។

សូមប្រើការពន្យល់បង្ហាញរបស់ស្ត្រីឈ្មោះ ស៊ូ ដែលផ្តល់ជូនក្នុងសៀវភៅណែនាំរបស់សិស្សនៅទំព័រ ទី ៨-៩ ។ សូមធ្វើអោយប្រាកដថា អ្នកពិភាក្សានូវសេចក្តីសន្យាខុស ដែលត្រូវបានផ្តល់ដោយគ្រីស្តបរិស័ទខ្លះដូចជា"អ្នកនឹងមានអារម្មណ៍ ពេញដោយសេចក្តីស្រលាញ់ អំណរនិង សន្តិភាពមកពីព្រះជាម្ចាស់ពេលដែលអ្នកក្លាយជាគ្រីស្តបរិស័ទភ្លាមៗនោះ ។" ចំនុចនេះវាមិន ស្របតាមព្រះគម្ពីរនោះទេ។ គ្រីស្តបរិស័ទភាគច្រើនពិសោធអារម្មណ៍វិជ្ជមានដូចនេះ ពេលដែលគេបានថ្វាយជីវិតទៅព្រះគ្រីស្ត ការពិសោធន៍បែបនោះគឺជាការល្អ។ប៉ុន្តែគ្មានការអះអាងពីព្រះបន្ទូលដែលថាយើងនឹង "មានអារម្មណ៍សុខសាន្ត" ភ្លាមៗ ពេលដែលយើងបញ្ចប់ការអធិស្ឋានថ្វាយជីវិតទៅព្រះគ្រីស្តនោះទេ ។

គួសបញ្ជាក់អោយសិស្សដឹងថាដូចកូនង៉ែតទើបនឹងកើតមកត្រូវ ឆ្លងកាត់ទុក្ខលំបាកជាច្រើនយ៉ាងណា គ្រីស្តបរិស័ទថ្មីក៏ត្រូវឆ្លងកាត់ដូចគ្នាអញ្ចឹងដែរ ។ គេត្រូវដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធនឹងបំភ្លឺគេអោយគេដឹងថាគេមានអំពើបាប ដែលជារឿយៗផ្តល់លទ្ធផលជាអារម្មណ៍ថាមានកំហុស ។

## ៩. សង្ឃឹមទុកជាមុនថាអារម្មណ៍របស់អ្នកនឹងផ្លាស់ប្តូរ (៣-៥នាទី)

ក្នុងចំនុចនេះមាននិយាយនៅទំព័រទី ៨-៩ នៃសៀវភៅណែនាំរបស់សិស្ស ។ សូមពន្យល់ថា វាជាការធម្មតាទេដែលមានអារម្មណ៍ចុះឡើងបែបនោះ។ វានឹងបន្តដូច្នេះពេលដែលមនុស្សក្លាយជាគ្រីស្តបរិស័ទ ។ ប្រសិនបើពួកគេពិសោធន៍នៅអារម្មណ៍ ដ៏អស្ចារ្យពេលដែលក្លាយខ្លួនជាគ្រីស្តបរិស័ទ ពួកគេគួរតែអរព្រះគុណព្រះជាម្ចាស់ចំពោះអារម្មណ៍បែបនោះ ប៉ុន្តែកុំបាត់ជំនឿទៅវិញ ពេលអារម្មណ៍ទាំងនោះចាកចេញបាត់ទៅ ។

ប្រសិនបើមនុស្សទទួលបានបទពិសោធន៍ថាគ្មានការផ្លាស់ប្តូរខាងអារម្មណ៍ពេលក្លាយជាគ្រីស្តបរិស័ទនោះ គេគួរតែសុំវត្តមានរបស់ព្រះជាម្ចាស់មកក្នុងជីវិតគាត់ ដើម្បីនាំទៅរកការផ្លាស់ប្តូរជាវិជ្ជមាន ។

ពេលដែលគេអធិស្ឋានដើម្បីក្លាយខ្លួនជាគ្រីស្តបរិស័ទ ទោះបីជាគេមានអារម្មណ៍យ៉ាងណាក៏ដោយ ពួកគេគួរ ដឹងថាព្រះជាម្ចាស់ចង់ផ្តល់នូវសេចក្តីស្រលាញ់ សន្តិភាព និង សេចក្តីអំណរក្នុងជីវិតគេ ។ អារម្មណ៍ដែលមានទាំងនេះមិនមែនជាកិច្ចការសំខាន់ ក្នុងការស្វែងរកទំនាក់ទំនងជាមួយព្រះជាម្ចាស់ទេ ។ វាគឺជាប្រយោជន៍មួយផ្នែកក្នុងការអភិវឌ្ឍន៍ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូ ។ យើងនឹងបកស្រាយរឿងនេះនៅក្នុងជំពូក ទី ៣ " ទំនាក់ទំនងផ្ទាល់ខ្លួនរបស់ខ្ញុំជាមួយព្រះយេស៊ូគ្រីស្ត " ។

## ១០. អារម្មណ៍របស់អ្នកគួរតែមានកន្លែង ទី ៣ នៅពេលអ្នកក្លាយខ្លួនជាគ្រីស្ទបរិស័ទ (៣-៥នាទី)

ដើម្បីបង្ហាញកន្លែងអំពីអារម្មណ៍ដែលយើងមាននៅក្នុងការក្លាយខ្លួនជាគ្រីស្ទបរិស័ទ ចូរយើងត្រឡប់ទៅមើលរឿងរ៉ាវ ពីរក្នុងមេរៀនចុងក្រោយ ។ ចំនុចសំខាន់បំផុតទីមួយ គឺការយល់យ៉ាងច្បាស់ពីអ្វីដែលព្រះគម្ពីរមានបន្ទូលអំពីការក្លាយខ្លួនជាគ្រីស្ទបរិស័ទ ។ ទីពីរគឺអ្នកត្រូវតែធ្វើការសំរេចចិត្តអោយច្បាស់លាស់ គឺការប្តេជ្ញាចិត្តខាងឆន្ទៈរបស់អ្នក ។ ត្រង់នេះហើយដែលព្រះជាម្ចាស់ផ្តល់អោយអ្នកនៅសេចក្តីជំនឿ និងមានអំណាចដើម្បីជួយអោយការសំរេចចិត្តរបស់អ្នកសំរេចជាស្ថាបពរ ។ យើងក៏ ត្រូវថ្វាយអារម្មណ៍របស់យើងទៅដល់ព្រះគ្រីស្ទផងដែរ ដើម្បីបង្ហាញថា ទ្រង់ជាអ្នកដឹកនាំយ៉ាងពិតប្រាកដនៅក្នុងជីវិតរបស់យើង ។

នៅទំព័រទី ១០ ក្នុងសៀវភៅណែនាំរបស់សិស្ស អ្នកមានរូបភាពផ្ទះ ដែលបង្ហាញពីទំនាក់ទំនងរវាងចំនុចទាំង បីនេះ ។ នេះគឺជាការពន្យល់លំអិតបន្ថែមទៀតអំពីរូបភាពនោះ ។

អារម្មណ៍ដែលអ្នកមានពេលអ្នកក្លាយខ្លួនជាគ្រីស្ទបរិស័ទនោះ មិនសំខាន់ដូចការដែលយល់ដឹង និងការស្តាប់បង្គាប់សេចក្តី ពិតនៅក្នុងព្រះគម្ពីរ ដែលប្រាប់អ្នកពីរបៀបដែលអ្នកក្លាយជាគ្រីស្ទបរិស័ទនោះទេ ។

## ការសាងសង់ផ្ទះរបស់អ្នក

(បើសិនអាចធ្វើទៅបាន សូមពន្យល់ចំនុចនេះជារូបភាពផ្ទះ ។ ចូរបង្ហាញគ្រប់ជំហានទាំងអស់ដែលមាននៅក្នុង រូបភាពអំពីការសាងសង់) ។

**គំរោង :** ប្រសិនបើអ្នកចង់សាងសង់ផ្ទះថ្មីមួយ អ្នកត្រូវតែមានគំរោងគូរឡើងមុនជាស្រេចពេលដែលអ្នកចាប់ផ្តើមសាងសង់ផ្ទះនោះ ។ ហើយវាសំខាន់ណាស់ក្នុងការសាងសង់តាមគំរោងនោះ ។ បើសិនជាអ្នកមិនដែលសាងសង់ផ្ទះទេ អ្នកត្រូវតែរកអ្នកណាម្នាក់ដែលដឹងពីរបៀបសាងសង់ផ្ទះ ។

**គ្រឹះ :** នៅពេលចាប់ផ្តើមសាងសង់ អ្វីដែលអ្នកចាប់ផ្តើមមុនដំបូងគឺជីកទៅក្នុងដី ហើយរៀបគ្រឹះយ៉ាងរឹងមាំ ។ គ្រឹះនេះត្រូវតែរឹងមាំគ្រប់គ្រាន់ ដើម្បីទ្រទ្រង់សំណង់អោយបានច្រើនឆ្នាំ ។

**ផ្ទះ :** នៅពេលដែលគ្រឹះបានចាក់សមរម្យហើយ បន្ទាប់មកអ្នកចាប់ផ្តើមសាងសង់ផ្ទះ ។ អ្នកមិនប្រើតែរបស់ចាស់ៗក្នុងការសង់នោះទេ ។ អ្នកនឹងរករបស់ល្អដែលអ្នកអាចរកបានហើយរបស់ត្រឹមត្រូវបំផុត ។ អ្នកប្រើរបស់របរដែលគំរោងត្រូវការ ។ វាត្រូវស៊ីពេលក្នុងការសាងសង់ផ្ទះ ។ ត្រូវដាក់ជញ្ជាំង ដាក់ដំបូលហើយដាក់ទ្វារ និង បង្អួច ។

**កំដៅ :** បន្ទាប់ពីផ្ទះបានសង់រួចហើយ នោះត្រូវដុតឡកំដៅ ហើយកំដៅត្រូវបំពេញពាសពេញក្នុងផ្ទះ ។ វាជាការល្ងីល្ងើ បើដុតឡកំដៅមុនការសាងសង់ផ្ទះរួចរាល់នោះ ។ ពេលដែលកំដៅមានដំណើរការល្អ កំដៅនឹងបំពេញក្នុងផ្ទះហើយធ្វើ អោយក្លាយជាកន្លែងមួយគួរអោយចង់រស់នៅ ។ កំដៅមិនធ្វើអោយសំណង់រឹងមាំទេ ។ បើសិនជាផ្ទះធ្វើបានល្អ វានឹងឈររឹងមាំ ហើយមានសុវត្ថិភាពទោះបីដុតកំដៅឬក៏មិនអុតក៏ដោយ ។

# ការអនុវត្តន៍ទៅនឹងការពន្យល់បង្ហាញ

ការក្លាយជាគ្រីស្ទបរិស័ទអាចប្រៀបធៀបទៅនឹងការសាងសង់ផ្ទះ ។ បើសិនជាអ្នកចង់ក្លាយជាគ្រីស្ទបរិស័ទដែលមានជ័យជំនះអ្នកត្រូវតែធ្វើតាមគំរោងការរបស់ព្រះជាម្ចាស់ ។ អ្នកត្រូវការជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធក្នុងការក្លាយខ្លួនជាគ្រីស្ទបរិស័ទ ។ ទ្រង់មានបទពិសោធន៏ច្រើនក្នុងការជួយមនុស្ស " សាងសង់ផ្ទះរបស់ពួកគេ " ( ជីវិតគ្រីស្ទបរិស័ទរបស់ពួកគេ) ។

**គ្រឹះ :** បើសិនជាអ្នកចង់ក្លាយខ្លួនជាគ្រីស្ទបរិស័ទ មុនដំបូងត្រូវតែចាក់គ្រឹះអោយរឹងមាំសិន ។ ក្នុងចំនុចនេះអាចប្រៀបធៀបនឹងការយល់ដឹង និង ការស្ដាប់បង្គាប់សេចក្ដីពិតនៅក្នុងព្រះគម្ពីរ ដែលប្រាប់អ្នកពីរបៀបក្លាយជាគ្រីស្ទបរិស័ទ ។ សេចក្ដីពិតទាំងនេះផ្ដល់នូវគ្រឹះរឹងមាំដែលអ្នកត្រូវការសំរាប់សង់ជីវិតជាគ្រីស្ទបរិស័ទរបស់អ្នក ។ ព្រះយេស៊ូបានសន្យាថាសេចក្ដីពិតទាំងនេះនឹងមិនផ្លាស់ប្ដូរទេ ។ សូមមើលម៉ាថាយ ៥:១៨ ។

មនុស្សខ្លះគិតថាគ្រឹះនៃជីវិតគ្រីស្ទបរិស័ទរបស់ពួកគេអាចជាអារម្មណ៏របស់ពួកគេ ។ អារម្មណ៏របស់អ្នកគឺជាគ្រឹះយ៉ាងទន់ខ្សោយសំរាប់ការក្លាយជាគ្រីស្ទបរិស័ទ ។ ប្រសិនបើអ្នកសង់ជីវិតគ្រីស្ទបរិស័ទនៅលើគ្រឹះនៃអារម្មណ៏នោះកំលាំង និង សេរីភាព ខាងព្រលឹងវិញ្ញាណរបស់អ្នកនឹងផ្លាស់ប្ដូរពីមួយថ្ងៃទៅមួយថ្ងៃ ។ នៅក្នុងថ្ងៃដែលអ្នកមានអារម្មណ៏ល្អ អ្នកមានអារម្មណ៏ដូចជាគ្រីស្ទបរិស័ទរឹងមាំ ។ ប៉ុន្ដែនៅពេលដែលអារម្មណ៏ល្អបានរសាយទៅ " ផ្ទះ " របស់អ្នកនឹងរង្គើរ វានឹងដួលរលំខ្ទេចខ្ទី ។

គ្រឹះដ៏រឹងមាំតែមួយគត់ដែលផ្ដល់មកពីព្រះជាម្ចាស់ដល់យើង គឺព្រះបន្ទូល និង ព្រះគម្ពីររបស់ទ្រង់ ។

**អាគារ ៖** អ្នកត្រូវសង់ជីវិតគ្រីស្ទបរិស័ទនៅលើសេចក្តីជំនឿ ។ សេចក្តីជំនឿគឺជាអំណាចរបស់ព្រះជាម្ចាស់ ដែលផ្តល់អោយអ្នក ដើម្បីសង់នូវគ្រឹះរឹងមាំនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ អ្នកមិនអាចក្លាយជាគ្រីស្ទបរិស័ទ ជោគជ័យដោយពឹងពាក់លើខ្លួនឯងទេ ។ អ្នកត្រូវការជំនួយពីព្រះវិញ្ញាណដ៏វិសុទ្ធ ជាអ្នកដឹកនាំ និង ជាគ្រូរបស់អ្នក ។ ទ្រង់ផ្តល់សំភារៈដែលអ្នកត្រូវការ ហើយទ្រង់បង្រៀនអ្នកពីរបៀបសង់ជីវិតគ្រីស្ទបរិស័ទ ។

អ្នកខ្លះក្លាយជាគ្រីស្ទបរិស័ទហើយបាន " ចាក់គ្រឹះរឹងមាំត្រឹមត្រូវ " ។ គេធ្វើតាមសេចក្តីពិតនៅក្នុងព្រះគម្ពីរ ហើយក្លាយជាគ្រីស្ទបរិស័ទ ។ ទោះយ៉ាងណាក៏ដោយ ពួកគេធ្វើកំហុស ដោយព្យាយាមសង់ ហើយទ្រទ្រង់ជីវិតគ្រីស្ទបរិស័ទរបស់ពួកគេនៅលើអារម្មណ៍ ។ អារម្មណ៍របស់អ្នកមិនធ្វើអោយ " ជញ្ជាំងរឹងមាំ " ឬ " ដំបូលរឹងមាំ " ឬក៏ "ធ្វើអោយទ្វារបង្អួចរឹងមាំ "នោះទេ ។អារម្មណ៍មិនមែនជា " សំភារៈ" ដែលគំរោងនៅក្នុងព្រះគម្ពីរសំដៅលើនោះទេ ។

ប្រសិនបើអ្នកចង់សង់ជីវិតគ្រីស្ទបរិស័ទរឹងមាំ អ្នកត្រូវតែធ្វើតាមគំរោងផែនការរបស់ព្រះជាម្ចាស់ដែលអាចរកបាន នៅក្នុងព្រះគម្ពីរ ។ អ្នកត្រូវតែប្រើសំភារៈដែលទ្រង់ប្រាប់អោយប្រើ ហើយអ្នកត្រូវតែសង់ " ផ្ទះ " របស់អ្នកតាមរបៀបទ្រង់មានព្រះបន្ទូល ។ ព្រះអង្គគឺជាមេកា ។

បើសិនជាអ្នកប្រើអារម្មណ៍ជា "សំភារៈ" ដែលប្រើសំរាប់សង់ផ្ទះ វាអាចជាកន្លែងរស់នៅដែលមានគ្រោះថ្នាក់ ។ថ្ងៃខ្លះជញ្ជាំងរឹងមាំ ថ្ងៃខ្លះទៀតវារលំបាត់ទៅ ។ ការរីកចំរើនរាល់ថ្ងៃនៃជីវិតគ្រីស្ទបរិស័ទរបស់អ្នកមិនត្រូវសងនៅលើការងារ ហើយនឹងអំណាចរបស់អ្នកទេ តែត្រូវសង់លើអំណាច និង ជំនួយរបស់ព្រះវិញ្ញាណដ៏វិសុទ្ធវិញ ។

**កំដៅ ៖** អារម្មណ៍របស់អ្នកនៅចំណាត់ថ្នាក់ទី ៣ ។ អារម្មណ៍របស់អ្នកអាចប្រៀបធៀបជាកំដៅដែលបំពេញផ្ទះ ។ អារម្មណ៍ របស់អ្នកធ្វើអោយជីវិតគ្រីស្ទបរិស័ទរបស់អ្នកមានការពេញចិត្តខ្លួនឯង ។ បើសិនជាអ្នកយល់ដឹងកន្លែងសមរម្យសំរាប់អារម្មណ៍របស់អ្នក ក្នុងជីវិតគ្រីស្ទបរិស័ទប្រចាំថ្ងៃ អ្នកអាចមានសុវត្ថិភាពជាគ្រីស្ទបរិស័ទដដែល ទោះបីជាអារម្មណ៍របស់អ្នកផ្លាស់ប្តូរយ៉ាងណាក៏ដោយ ។

ផ្ទះនៅតែជាផ្ទះដដែលទោះបីមានកំដៅឬអត់ក៏ដោយ ។ វាដូចជាការក្លាយជាគ្រីស្ទបរិស័ទដែរ ។ អ្នកជាគ្រីស្ទបរិស័ទ ពីព្រោះអ្នកបានចាក់គ្រឹះសមរម្យ ហើយសង់ផ្ទះជាមួយនឹងជំនួយ និង សំភារៈដែលព្រះជាម្ចាស់បានផ្តល់អោយអ្នក ។ ការមានអារម្មណ៍ល្អមិនធ្វើអោយអ្នកក្លាយជាគ្រីស្ទបរិស័ទនោះទេ ។ បើសិនជាអារម្មណ៍បានចាក់ចេញទៅ បើអ្នកមិនមានអារម្មណ៍ជាគ្រីស្ទបរិស័ទ មិនអីទេ ទោះបើអ្នកមិនមានអារម្មណ៍ពីវត្តមានរបស់ព្រះគ្រប់ពេលក៏វាមិនជាអ្វីដែរ ។ " ផ្ទះ " គឺនៅតែជាផ្ទះឈរដ៏រឹងមាំដដែល ។

## ១១. តើអារម្មណ៍អ្វីខ្លះដែលជាប់ទាក់ទងជាមួយ ពេលអ្នកក្លាយជាគ្រីស្តបរិស័ទ? (៥-១០នាទី)

សូមអោយសិស្សប្រើចំលើយរបស់គេពី គំរោង ទី ២ ផ្នែកទី ១ ក្នុងការពិភាក្សារឿងនេះ ។ ចំនុចចំបងដែលយើង ចង់បង្ហាញនៅទីនេះ គឺមានអារម្មណ៍ជាច្រើនប្រភេទដែលសមរម្យនៅក្នុងបទពិសោធន៍នៃការក្លាយខ្លួនជាគ្រីស្តបរិស័ទ ។ អ្នកអាចអានអត្ថបទគម្ពីរដែលត្រូវបានបង្ហាញនៅក្នុងគំរោង ទី ២ ។

## ១២. បទពិសោធន៍ផ្ទាល់ខ្លួននៃការឆ្លើយតបខាងអារម្មណ៍ពេលទទួលការសង្រ្គោះ (២-៥នាទី)

អោយសិស្សជាច្រើនចែកចាយបទពិសោធន៍របស់ពួកគេ ពេលដែលគេក្លាយជាគ្រីស្តបរិស័ទ ។ សូមអោយគេកំណត់ការរៀបរាប់តែអារម្មណ៍ដែលគេមាននៅពេលនោះ ។ ពួកគេអាចប្រើចំលើយរបស់ពួកគេនៅផ្នែកទី២ នៃ គំរោងទី២ក្នុងពេលនេះ ។

## ១៣. សេចក្តីណែនាំអោយស្គាល់អំពីរឿង " រៀនយល់ថាតើព្រះគ្រីស្តចង់អោយអ្នកបង្ហាញពីអារម្មណ៍របស់អ្នកក្នុងថ្ងៃនិមួយៗដោយរបៀបណា " (៣-៥នាទី)

ពេលដែលមនុស្សក្លាយជាគ្រីស្តបរិស័ទ គាត់ជួបប្រទះឱកាសជាច្រើនដើម្បីបង្ហាញអារម្មណ៍របស់គាត់ ។ គាត់អាចរៀនក្នុងការថ្វាយកន្លែងនេះនៃជីវិតរបស់គាត់ដល់ព្រះគ្រីស្ត ឬមួយគាត់អាចបន្តឆ្លើយតបខាងអារម្មណ៍តាមគាត់ចង់ ហើយបដិសេធន៍នូវអ្វីដែលព្រះគ្រីស្តមានព្រះបន្ទូល ។ ពេលដែលយើងនិយាយអំពីការប្តេជ្ញាចិត្តខាងអារម្មណ៍របស់អ្នកជាផ្នែកមួយក្នុងការ ក្លាយខ្លួនជាគ្រីស្តបរិស័ទ យើងមិនសំដៅគ្រាន់តែទៅលើរបៀបដែលអ្នកមានអារម្មណ៍ ពេលអ្នកក្លាយខ្លួនជាគ្រីស្តបរិស័ទនោះទេ ។ វាទាក់ទងទៅនឹងការចុះចូលកន្លែងនេះនៃជីវិតរបស់អ្នកដល់ព្រះគ្រីស្តក្នុងថ្ងៃនិមួយៗ ។ ការប្តេជ្ញាចិត្តរបស់អ្នកនៅពេល ទទួលបាននូវការសង្គ្រោះគឺជាការចាប់ផ្តើមជំហានដំបូង ។

នៅក្នុងការពិភាក្សាចំនុចផ្សេងទៀតក្នុងផ្នែកនៃមេរៀននេះ យើងចង់រក្សាការពិភាក្សាផ្តោតទៅលើការផ្លាស់ប្តូរខាងអារម្មណ៍ទាំងអស់នោះ ដែលទាក់ទងទៅនឹងការក្លាយជាគ្រីស្តបរិស័ទ ហើយនៅតែរក្សាអោយមានទំនាក់ទំនងយ៉ាងរឹងមាំជាមួយនឹងព្រះគ្រីស្ត ។ ប្រសិនបើអ្នកមានពេល អ្នកអាចធ្វើអោយការពិភាក្សានោះកាន់តែពិស្តារថែមទៀត ។

សិស្សខ្លះអាចមានការឈឺចាប់ខាងអារម្មណ៍ពីបទពិសោធន៍អតីតកាល ។ ជាពិសេសចំពោះអ្នកដែលទទួលរងនូវការឈឺចាប់ខាងរាងកាយ ឬ ខាងផ្លូវភេទ និង អ្នកដែលចេញមកពីគ្រួសារដែលមានការបែកបាក់ ។ យើងត្រូវតែប្រយត្ន័នៅត្រង់នេះ យើងមិនអាចធ្វើការពិភាក្សា១៥នាទី នៅត្រង់នេះ ហើយវានឹងផ្តល់ចំលើយទាំងអស់ ដែលពួកគេត្រូវការដោះស្រាយបញ្ហារបស់ពួកគេនោះទេ ។ ចូរលើកទឹកចិត្តគេអោយពិភាក្សាជាមួយអ្នកដោយផ្ទាល់ពីផលពិបាកធំៗដែលពួកគេមាន ក្នុងផ្នែកនេះនៃជីវិតរបស់ពួកគេ ។

## ១៤. ថ្វាយអារម្មណ៍របស់អ្នកនៅក្នុងការដឹកនាំរបស់ព្រះយេស៊ូគ្រីស្ទ (៣-៥នាទី)

ពួកយើងភាគច្រើនគិតថា ការឆ្លើយតបខាងអារម្មណ៍របស់យើងជាផ្នែកមួយផ្ទាល់ខ្លួនរបស់ជីវិតយើង ។ " តើអ្នកជានរណាដែលប្រាប់ខ្ញុំ អោយខ្ញុំមានអារម្មណ៍យ៉ាងណានោះ ? ពេលដែលយើងថ្វាយអារម្មណ៍របស់យើងទៅព្រះគ្រីស្ទយើងនិយាយថា "ព្រះអម្ចាស់អើយ ទូលបង្គំថ្វាយសេរីភាពដល់ទ្រង់ឱ្យប្រាប់ទូលបង្គំពីរបៀបដែលទូលបង្គំត្រូវមានអារម្មណ៍ ។ ទូលបង្គំជាមនុស្សដែលចង់ឱ្យទ្រង់ពេញចិត្តរាល់អារម្មណ៍នៃជីវិតប្រចាំថ្ងៃរបស់ទូលបង្គំ " ។

នេះមិនមែនមានន័យថាព្រះគ្រីស្ទផ្តល់អោយយើងមានអារម្មណ៍យ៉ាងណាមួយនោះទេ ។ យើងមិនក្លាយជាតុកត្តាទេ ។ វានៅតែជាអារម្មណ៍របស់យើង ហើយយើងទទួលខុសត្រូវចំពោះវាដដែល ។ យើងមិនអាចនិយាយថា " ខ្ញុំបានថ្វាយអារម្មណ៍របស់ខ្ញុំទៅព្រះគ្រីស្ទហើយ ដូច្នេះពេលដែលខ្ញុំខឹងជាមួយអ្នកគឺដោយសារព្រះជាម្ចាស់ចង់អោយខ្ញុំធ្វើយ៉ាងដូចនេះទៅអ្នក " ។

ចូរគូសបញ្ជាក់ពីសារៈសំខាន់ក្នុងការរៀនចេះដោះស្រាយចំពោះអារម្មណ៍ របស់ពួកគេទៅតាមផ្លូវដែលចាស់ទុំ ។ អារម្មណ៍របស់យើងមិនអាចគ្រប់គ្រងជីវិតរបស់យើងបានទេ ។ ព្រះគ្រីស្ទត្រូវតែជាម្ចាស់នៅក្នុងចំនុចនេះនៃជីវិតយើង ។ ការថ្វាយអារម្មណ៍របស់អ្នកទៅព្រះជាម្ចាស់ មិនមែនមានន័យថាអ្នកឈប់ធ្វើជាខ្លួនឯងនោះទេ ។ វាមានន័យថា អ្នកមានការផ្លាស់ប្តូរនូវអត្តចរិក និង អាកប្បកិរិយាក្នុងការបង្ហាញ ពីអារម្មណ៍របស់អ្នក ។ សូមបង្ហាញថា នេះជាដំណើរនៃការរីកចំរើន ដែលត្រូវចំណាយពេលជាច្រើនសប្តាហ៍ច្រើនខែ ឬក៏ច្រើនឆ្នាំ ។

## ១៥. រៀនសំគាល់ពីអារម្មណ៍របស់អ្នកអោយបានត្រឹមត្រូវ (៣-៥នាទី)

មនុស្សជាច្រើនមានការពិបាកក្នុងការទប់អារម្មណ៏របស់ពួកគេ ។ ប្រសិនបើអ្នកសួរមនុស្សនោះនូវអ្វីដែលគេ កំពុងតែមានអារម្មណ៏នៅនាទីពិសេសណាមួយនោះ នោះប្រហែលជាគាត់មិនអាចបកស្រាយពីអារម្មណ៏ដែលគាត់មាននោះទេ ។ ការរៀនសំគាល់អារម្មណ៏របស់អ្នកអោយបានត្រឹមត្រូវគឺជាជំហានដ៏សំខាន់។ សូមមើលទំព័រ ទី ១១-១២ នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ពតិមានបន្ថែមទៀតនៅត្រង់ចំនុចនេះ ។

សុំអោយសិស្សកត់ត្រានូវអារម្មណ៏ផ្សេងៗរបស់ពួកគេ ។ បន្ទាប់មក សូមអោយពួកគេរៀបរាប់ពីស្ថានភាពដែលពួកគេមានអារម្មណ៏យ៉ាងដូចនោះ ។

ក្នុងសៀវភៅរបស់ លោក ចន ភូវែល *ហេតុអ្វីបានជាខ្ញុំខ្លាចប្រាប់អ្នកថាខ្ញុំជានរណា?* ជំពូក ទី ៣ និង ៤ មានពតិមានល្អណាស់ពីអារម្មណ៏ ។ អ្នកអាចបញ្ចូលចំនុចខ្លះទៅមេរៀននេះពីសៀវភៅរបស់គាត់ ។ អ្នកអាចអោយសិស្សរបស់អ្នកអាននូវជំពូកទាំងនេះ។

## ១៦. រៀនស្វែងរកការបន្ធូរខាងអារម្មណ៍តាមរយៈការអធិស្ឋាន (៥-១០នាទី)

មើលក្នុងទំព័រទី ១២ នៅក្នុងសៀវភៅណែនាំសំរាប់សិស្ស ដើម្បីពតិមានបន្ថែមទៀតនៅអត្ថបទនេះ ។នេះជាជំហាន សំខាន់បំផុតនៅក្នុងជីវិតគ្រីស្ទបរិស័ទថ្មីគ្រប់រូប ។ បើសិនជាគេចាប់ផ្តើមនិយាយទៅព្រះជាម្ចាស់នូវអារម្មណ៏របស់គេ គេស្ថិតនៅក្នុងផ្លូវដែលត្រឹមត្រូវ ។ ចូរលើកទឹកចិត្តគេអោយអាននូវទំនុកតំកើង ហើយមើលទៅរបៀបដែលព្រះបាទដាវីឌ រៀបរាប់ពីអារម្មណ៏របស់គាត់ដល់ព្រះជាម្ចាស់។ បើសិនជាគេខកចិត្ត លើកទឹកចិត្តគេអោយប្រាប់ ដល់ព្រះជាម្ចាស់នូវអ្វីដែលជាអារម្មណ៏ពិតដែលគេមាន។

សូមលើកទឹកចិត្តគេ អោយសុំព្រះជាម្ចាស់ ដើម្បីបំពេញជីវិតពួកគេជាមួយនឹងការឆ្លើយតបខាងអារម្មណ៏ដែលទ្រង់ចង់អោយពួកគេមាន ។ ឧទាហរណ៏ពួកគេគួរសុំព្រះជាម្ចាស់អោយជួយគេមានអារម្មណ៏ស្រលាញ់មនុស្សណាម្នាក់ ដែលពួកគេមានការពិបាកនឹងស្រលាញ់ ។ សុំព្រះជាម្ចាស់នូវគំនិតសន្តិភាពដើម្បីជំនួសនូវការព្រួយចិត្ត និង ការភ័យព្រួយ ដែលតែងតែមាននោះ ។ សុំការអាណិតជំនួសអោយការខឹងដែលគេមានចំពោះអ្នកដទៃដែលបានធ្វើខុសចំពោះពួកគេ ។

## ១៧. រៀនពីរបៀបនិយាយពីអារម្មណ៍របស់ខ្លួនប្រាប់អ្នកដទៃ (៥-១០នាទី)

យើងភាគច្រើនមានទំនាក់ទំនង ខាងអារម្មណ៍របស់យើង ទៅលើអ្នកដទៃតាមរយៈអំពើរបស់យើងទៅគេ ។ អ្វីដែលយើងចង់អោយគេរៀន គឺនិយាយដោយផ្ទាល់មាត់តាមសំលេងសំដី ដែលជាសំលេងអព្យាក្រឹតនូវអ្វីដែលខ្លួនមានអារម្មណ៍ ។ អ្នកអាចអោយពួកគេអនុវត្តដូចនេះ គឺមើលសៀវភៅណែនាំសំរាប់សិស្ស នៅទំព័រទី ១៣ សំរាប់ពត៌មានបន្ថែមទៀតអំពីរឿងនេះ ។ សៀវភៅលោក ចន ភូវែល ផ្តល់នូវគំនិតដ៏ល្អក្នុងចំនុចនេះ ។

ចូរពិភាក្សាជាមួយសិស្សរបស់អ្នក ថាតើហេតុអ្វីបានជាវាសំខាន់ក្នុងការនិយាយអំពីអារម្មណ៍របស់អ្នកជាមួយអ្នកដទៃ ។ ហេតុផលមួយគឺដើម្បីបង្ការកុំអោយមានជំលោះ ។ ហេតុផលផ្សេងទៀតគឺដើម្បីធ្វើអោយមានទំនាក់ទំនងកាន់តែជ្រៅជាមួយមិត្តភក្តិ ឬក៏ សមាជិកគ្រួសារ ។ ចូរគូសបញ្ជាក់ពីសារៈសំខាននៃការរៀនធ្វើកិច្ចការនេះ ជាមួយសមាជិកគ្រួសាររបស់អ្នក ជាពិសេសជាមួយកូនរបស់អ្នក ។

ចាំបាច់ត្រូវមានតុល្យភាពនៅទីនេះ ។ យើងមិនគួរឱ្យអារម្មណ៍របស់យើងចេញមកក្រៅទាំងអស់នោះទេ ។ គឺមានពេលខ្លះយើងត្រូវស្ងាត់ស្ងៀមនូវអ្វីដែលយើងមានអារម្មណ៍ ។ ប្រសិនបើអ្នកមានអារម្មណ៍ធ្លាក់ទឹកចិត្ត ឬក៏ ទុក្ខព្រួយបន្តិចបន្តួច អ្នកមិនត្រូវទៅប្រាប់គេរាល់គ្នាអំពីបញ្ហារបស់អ្នកទេ ។ ទោះជាយ៉ាងណាក៏ដោយ បើសិនជាអ្នកមិនអាចយកជ័យជំនះដោយខ្លួនអ្នកផ្ទាល់បានទេនោះ វាល្អជាងក្នុងការពិភាក្សាដោយផ្ទាល់ជាមួយមិត្តភក្តិ ឬក៏ សមាជិកគ្រួសាររបស់អ្នក ។

## ១៨. រៀនបញ្ចេញនូវអារម្មណ៍របស់ខ្លួនថែមទៀត (៣-៥នាទី)

ចំនុចសំខាន់ដែលយើងចង់និយាយនៅទីនេះ គឺព្រះជាម្ចាស់ចង់អោយអ្នកមានអំណរនូវគ្រប់អារម្មណ៍ទាំងអស់ ដែលទ្រង់បានបង្កើតនៅក្នុងអ្នក ។ ក្នុងនាមជាគ្រីស្ទបរិស័ទ អ្នកមានសក្តានុពល ដើម្បីដកពិសោធន៍យ៉ាងជ្រៅនៃសន្តិភាព អំណរ និង សេចក្តីស្រលាញ់ដោយសារជំនួយពីព្រះយេស៊ូគ្រីស្ទ ។ មើលទំព័រទី ១៣ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីជាពត៌មានថែមទៀតចំពោះរឿងនេះ ។

## ១៩. សូមប្រយ័ត្ននឹងគ្រីស្ទបរិស័ទ " ជាប់ញៀននឹងអារម្មណ៍ " (៣-៥នាទី)

មានបញ្ហាពិតប្រាកដដែលគ្រីស្ទបរិស័ទខ្លះទទួលការបង្រៀនមិនពិតសព្វថ្ងៃនេះ ។ គេសង្កត់ធ្ងន់ពេកទៅលើ " ព្រះជាម្ចាស់នឹងផ្តល់អារម្មណ៍ល្អដល់អ្នក " ។

ពួកគេសន្យាថានឹងមានសេចក្តីស្រលាញ់ អំណរ និងសន្តិភាពយ៉ាងពេញបរិបូរ ។ គេនិយាយថាបើអ្នកមិនមានអារម្មណ៍ដូចនេះនៅក្នុងជីវិតទេនោះអ្នកកំពុងតែអនុញ្ញាតអោយសាតាំងលួចនៅកិច្ចការទាំងអស់នេះហើយ ។ សូម លើកទឹកចិត្តសិស្សរបស់អ្នក អោយពិនិត្យអោយម៉ត់ចត់ក្នុងព្រះបន្ទូល មិនគ្រាន់តែពីរ ឬបីខ នៅទីនេះឬទីនោះទេ ។ សូមមើលទំព័រ ១៤ នៅក្នុងសៀវភៅណែនាំសំរាប់សិស្សដើម្បីពត៌មានបន្ថែមទៀត ។

ព្រះជាម្ចាស់មិនបានសន្យាថា " មានអារម្មណ៍ខ្ពង់ខ្ពស់ជារៀងរាល់ថ្ងៃសំរាប់គ្រីស្ទបរិស័ទនោះទេ។ តែទ្រង់បានសន្យាថា គង់នៅជាមួយអ្នកគ្រប់ពេល ។ ទ្រង់នឹងជួយអ្នកអោយឆ្លងកាត់គ្រប់ទុក្ខលំបាក ។ ចូរលើកទឹកចិត្តពួកគេថា អារម្មណ៍ខ្ពង់ខ្ពស់អាចចេញទៅហើយអាចមកវិញ នោះគឺរឿងធម្មតានៃជីវិតរស់នៅទេ ។

## ២០. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥នាទី)

សូមយកចិត្តទុកដាក់លើការអនុវត្តន៍ផ្ទាល់ខ្លួនក្នុងការទទួលស្គាល់នូវការផ្លាស់ប្តូរអារម្មណ៍របស់អ្នកដោយមិនពឹងផ្អែកលើវាដើម្បីបង្ហាញថា អ្នកជាគ្រីស្ទបរិស័ទ ។ មានគំរោងជាច្រើនដែលអាចជួយអោយអ្នកមានការរីកចំរើនក្នុងផ្នែកនេះនៅក្នុងជីវិត ។

### ក. អធិស្ឋានអំពីអារម្មណ៍របស់អ្នក

សារភាពនូវអារម្មណ៍របស់អ្នកទៅព្រះជាម្ចាស់ក្នុងសេចក្តីអធិស្ឋាន ។ សូមប្រាប់ដល់ព្រះជាម្ចាស់នូវ ចំនុចពិសេសចំៗពីអ្វីដែលអ្នកមានអារម្មណ៍អំពីស្ថានភាពដ៏ពិបាកដែលអ្នកកំពុងជួបប្រទះ ។ ហើយសូមប្រាប់ដល់ទ្រង់ផងដែរនូវបទពិសោធន៍ល្អនៃអារម្មណ៍ដែលអ្នកមានថ្ងៃនេះ ។ តាមពិតអ្នកអាចប្រាប់ពីស្ថានភាពលំបាកដល់ទ្រង់តែម្តងនៅពេលលំបាកនោះ ។ ប្រាប់ទ្រង់នូវអ្វីដែលអ្នកមានអារម្មណ៍ ដើម្បីអាចបន្ធូរភាពតានតឹងដែលមាននៅក្នុងចិត្តអ្នក ។

### ខ. ការកត់ត្រាប្រចាំថ្ងៃអំពីសតិអារម្មណ៍របស់អ្នក

ធ្វើការកត់ត្រាប្រចាំថ្ងៃនូវអារម្មណ៍របស់អ្នកយ៉ាងហោចណាស់មួយសប្តាហ៍ ។ ព្យាយាមតក់ត្រាអោយត្រឹមត្រូវនូវអារម្មណ៍របស់អ្នកនៅក្នុងស្ថានភាពខុសគ្នាខ្លះដែលអ្នកជួបប្រទះនៅថ្ងៃនិមួយៗ ។ អ្នកអាចវាយតំលៃខ្លួនឯងដោយឆ្លើយនូវសំនួរនេះ " តើខ្ញុំឆ្លើយតបទៅនឹងអារម្មណ៍របស់ខ្ញុំតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ? តើផ្លូវណាដែលខ្ញុំបង្ហាញនូវអារម្មណ៍របស់ខ្ញុំ? តើធ្វើអោយព្រះជាម្ចាស់គាប់ព្រះហឫទ័យឬទេ?

### គ. ការសិក្សាព្រះគម្ពីរអំពីអារម្មណ៍

សិក្សាព្រះគម្ពីរដើម្បីស្វែងរកផ្លូវល្អបំផុតក្នុងការបញ្ចេញអារម្មណ៍ទៅតាមអ្វីដែលព្រះគម្ពីរមានព្រះបន្ទូល ។ រកមើលគំនិតដែលមានប្រយោជន៍អំពីរបៀបដែលអ្នកអាចប្រើអារម្មណ៍អ្នកតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។

### ឃ. ធ្វើការយល់ព្រមគ្នាជាមួយមិត្តភក្តិ ឬក៏ សាច់ញាតិ

ធ្វើការយល់ព្រមគ្នាជាមួយប្តី/ប្រពន្ធរបស់អ្នក ឬមិត្តភក្តិរបស់អ្នក ដើម្បីជួយមើលគ្នាអំពីការដែលយើងបញ្ចេញអារម្មណ៍ទៅវិញទៅមក ។ ការជួយអោយយោបល់គ្នាយ៉ាងដូចនេះអាចអោយឱកាស កត់ត្រានូវអារម្មណ៍ពីគ្នាទៅវិញទៅមក ។ វាក៏ផ្តល់ឱកាសអោយមានភាពស្មោះត្រង់ចំពោះអារម្មណ៍របស់ខ្លួនជាមួយនឹងអ្នកដែលអ្នកទុកចិត្តផងដែរ ។ បើសិនវាពិបាកនឹងនិយាយតទល់មុខគ្នា អ្នកអាចកត់ត្រាជាការវាយតំលៃហើយហុចអោយគ្នាទៅវិញទៅមក។

### ង. ករណីសិក្សា

វាយតំលៃករណីសិក្សាខាងក្រោម និង កំណត់អ្វីដែលអ្នកគិតថាជាវិធីល្អបំផុតដើម្បីជួយមនុស្សម្នាក់នេះឱ្យអោយយល់ច្បាស់ពីរបៀបដែលព្រះជាម្ចាស់ ចង់អោយគាត់សំដែងនូវអារម្មណ៍របស់គាត់ ហើយអាចពឹងពាក់លើអារម្មណ៍ច្រើនប៉ុណ្ណា ។

ឧទាហរណ៍ : លោក អែឌ កាលពី៦ ថ្ងៃមុនឈរថ្វាយខ្លួន ហើយសុំព្រះយេស៊ូដើម្បីធ្វើជាអ្នកដឹកនាំនៅក្នុងជីវិតរបស់គាត់ ។ សំរាប់រយៈពេលពីរថ្ងៃដំបូង គឺល្អអស្ចារ្យណាស់សំរាប់ លោក អែឌ ។ អំណរហើយនិងសន្តិភាពបានពេញហូរហៀរចំពោះជីវិតគាត់ ហើយទៅគ្រប់អស់អ្នកណាដែលមានទំនាក់ទំនងជាមួយគាត់ជាក់ស្តែង ។

ប៉ុន្តែកាលពីថ្ងៃម្សិលមិញជាអកុសលខ្លាំងណាស់ចំពោះលោក អែឌ ។ គាត់ដឹងថាប្រពន្ធរបស់គាត់មានគំរោងនឹងចាកចោលគាត់ ។ នាងនិយាយថានាងឈប់ស្រលាញ់គាត់ទៀតហើយ ។ អំណរ និង ភាពសុខសាន្តកាលពីប៉ុន្មានថ្ងៃមុន បានចាកចេញពីគាត់អស់ ។ ភាពស្រអាប់ និង ការអស់សង្ឃឹមរបស់ អែឌ កំពុងឃុំគ្រងគាត់ ។ អែឌប្រាប់អ្នកថា " ប្រសិនបើព្រះជាម្ចាស់ប្រាកដជាស្រលាញ់ខ្ញុំមែន ទ្រង់មិនធ្វើអោយរឿងនេះកើតឡើងចំពោះខ្ញុំទេ ។ ប្រសិនបើខ្ញុំដឹងថា ការក្លាយជាគ្រីស្ទបរិស័ទយ៉ាងនេះ ខ្ញុំមិនចង់ធ្វើទេ " ។

តើអ្នកនឹងនិយាយយ៉ាងដូចម្តេចទៅកាន់លោក អែឌ? តើព្រះបន្ទូលកន្លែងណាដែលអ្នកប្រើដើម្បីជួយលោកអែឌអោយឃើញពីអ្វីដែលព្រះជាម្ចាស់កំពុងតែធ្វើការក្នុងជីវិតគាត់? តើអ្នកធ្វើដូចម្តេចអាចព្យាយាមបញ្ចុះបញ្ចូលលោកអែឌយល់ថា គាត់នៅតែជាគ្រីស្ទបរិស័ទ ហើយព្រះជាម្ចាស់នៅតែស្រលាញ់គាត់? តើដំបូន្មានយ៉ាងដូចម្តេចដែលអ្នកនឹងប្រាប់ទៅគាត់អំពីអារម្មណ៍របស់គាត់គួរតែមានក្នុងជីវិតគ្រីស្ទបរិស័ទ?

## ២១. កិច្ចការត្រូវធ្វើ

ក. នៅចុងម៉ោង ដាក់សំនួរអោយធ្វើ អំពីសេចក្តីពិតទាំង ៨ ដែលអ្នកត្រូវការយល់ដឹង និង ជឿ ដើម្បីក្លាយខ្លួនជាគ្រីស្ទបរិស័ទ ។ សូមមើលទំព័រទី ៥ នៃសៀវភៅណែនាំរបស់សិស្ស ។

ខ. ដាក់ពិន្ទុគំរោង ទី ២ " អារម្មណ៍របស់ខ្ញុំ "

គ. សូមរកពេលដើម្បីពន្យល់សង្ខេបគំរោង ទី ៥ " សរសេររឿងរបស់អ្នក " ។

ពួកគេមានពេលវេលាតិចតួចណាស់ដើម្បីធ្វើគំរោងនេះ ត្រូវតែចាប់ផ្តើមភ្លាម១ ។ សូមអោយគេសរសេររឿង មិនមែនគ្រាន់តែជារបាយការណ៏ដែលផ្តល់ពតិមានប៉ុណ្ណោះទេ ។

## ២២. ប្រភពឯកសារបន្ថែម

នៅពីរទំព័របន្ទាប់ទៀតគឺជារឿងពីរដែលទាក់ទងនឹងអារម្មណ៍ :

" តើមនុស្សអាចដឹងពិតប្រាកដពីវត្តមានរបស់ព្រះជាម្ចាស់ទេ ? "

" របៀបដោះស្រាយជាមួយអារម្មណ៏របស់អ្នកពីអំពើបាបនៃជីវិតអតីតកាល " ។

បើសិនជាអ្នកមានពេល អ្នកអាចយករឿងនេះមកបកស្រាយពេញមួយវគ្គរៀន ។

## ២៣. ការវាយតំលៃនិងគំនិតរបស់ខ្ញុំសំរាប់ការបង្រៀនមេរៀននេះពេលក្រោយ

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៏ដល់សិស្សរបស់អ្នក ។

# កំណត់ចំណាំរបស់គ្រូ

## តើមនុស្សអាចដឹងពិតប្រាកដពីវត្តមានរបស់ព្រះជាម្ចាស់ ឬទេ?

ច្រើនដងគ្រីស្ទបរិស័ទថ្មីច្រឡំពីការនិយាយរបស់គ្រីស្ទបរិស័ទចាស់ទុំ អំពីទំនាក់ទំនងរបស់ពួកគេជាមួយព្រះជាម្ចាស់ ។ ពួកគេទៅព្រះវិហារហើយឮគ្រូគង្វាលនិយាយថា " តើអ្នកមិនមានអារម្មណ៍ពីវត្តមានរបស់ព្រះជាម្ចាស់នៅព្រឹកនេះទេឬ? " គ្រីស្ទបរិស័ទថ្មីមើលជុំវិញ ឆ្ងល់ថា តើខ្លួនគួរតែមានអារម្មណ៍យ៉ាងដូចម្ដេច ។

សូមលើកទឹកចិត្តគេអោយគេប្រុងប្រយ័ត្នអំពីរឿងនេះ ។ បង្រៀនគេអោយគេឈរលើសេចក្ដីសន្យារបស់ព្រះជាម្ចាស់ពីព្រះគម្ពីរ ។ព្រះជាម្ចាស់បានសន្យាថានឹងគង់ក្នុងចំណោមយើងពេលដែលយើងជួបជុំគ្នាថ្វាយបង្គំព្រះអង្គ។ ទ្រង់មានវត្តមានទោះបីយើងមានអារម្មណ៍ពីវត្តមាន របស់ទ្រង់ឬក៏អត់ក៏ដោយ ។ អារម្មណ៍មិនសំខាន់ទាល់តែសោះអ្វីដែលសំខាន់ នោះគឺជាសេចក្ដីពិតដែលថាព្រះជាម្ចាស់មានវត្តមាន ។

បង្ហាញអោយសិស្សដឹងថា មនុស្សខ្លះមានអារម្មណ៍ងាយចុះចូលក្នុងចំណោមមនុស្សច្រើន ។ ពាក្យបច្ចេកទេសគឺ " ចិត្តវិទ្យាខាងហ្វូងមនុស្ស " ឬ " ការរំជួលចិត្តជាហ្វូង " ។ អ្នកធ្វើសេចក្ដីថ្លែងការណ៍ខ្លះ មានភាពប៉ិនប្រសព្វខាងធ្វើអោយអារម្មណ៍របស់ហ្វូងមនុស្សរំជើបរំជួល ។

ការពន្យល់បង្ហាញមួយទៀត អាចជួយអោយយល់ច្បាស់ពីរឿងនេះ ។ នៅពេលដែលអ្នកនៅផ្ទះជាមួយក្រុមគ្រួសាររបស់អ្នកតើមាន " អារម្មណ៍ " ពីវត្តមាននៃសមាជិកដទៃក្នុងគ្រួសារអ្នកទេ ? ឧទាហរណ៍ អ្នកកំពុងតែអង្គុយនៅក្នុងបន្ទប់ទទួលភ្ញៀវហើយមានមនុស្សម្នាក់ចូលមក ។ អ្នកអាចដឹងថាគេមាន " វត្តមាន " ពីព្រោះអ្នកឃើញគេ ឬឮសំលេងគេ ។តើអ្នកមានអារម្មណ៍ចំឡែកទេគ្រាន់តែគេចូលមកក្នុងបន្ទប់?ជួនកាលអ្នកអាចមានអារម្មណ៍បែបនោះ ។ បើអ្នកកំពុងតែព្យាយាមសំរាក ហើយពួកគេមកធ្វើមាត់ឡូឡា អ្នកអាចនឹងមានអារម្មណ៍ខឹងនៅក្នុងចិត្តភ្លាម ។ បើសិនជាអ្នកជាយុវជន ហើយមានមិត្តប្រុស ឬ មិត្តស្រីរបស់អ្នកចូលមក អ្នកអាចនឹងមានអារម្មណ៍ពីសេចក្ដីស្នេហាដែលកើតចេញពីក្នុងចិត្តភ្លាម ។

ប៉ុន្តែសុំឈប់ហើយគិតអំពីព្រឹត្តិការណ៍ខុសៗគ្នាដែលបានកើតឡើងនៅថ្ងៃនេះ ព្រឹត្តិការណ៍ភាគច្រើនវាជារឿងធម្មតាទៅហើយ ។ តើអ្នកមានអារម្មណ៍ផ្លាស់ប្ដូរខ្លាំងនៅក្នុងចិត្តរាល់ពេលដែលមានមនុស្សចូល ឬ ចេញពីបន្ទប់អ្នកទេ?ប្រហែលជាអត់មានទេ ។ នោះគឺជារឿងធម្មតាទេ ។

ដូច្នេះកុំចំឡែកចិត្តអី បើសិនអ្នកមិនមានអារម្មណ៍ពីវត្តមានរបស់ព្រះជាម្ចាស់រាល់ពេលដែលអ្នកមកព្រះវិហារ ។ជាច្រើនដងអ្នកក៏អាចធ្វើអ្វីៗ ដែលងាយស្រួលក្នុងការមានអារម្មណ៍ពីវត្តមានរបស់ព្រះជាម្ចាស់ដែរ ។ ចូរអធិស្ឋានទៅព្រះជាម្ចាស់ គិតអំពីព្រះអង្គ អានព្រះគម្ពីរ ចំនុចទាំងអស់នេះអាចជួយអ្នកអោយមានការផ្តោតអារម្មណ៍ពេញលេញទៅទ្រង់ ហើយដឹងពីវត្តមានរបស់ព្រះអង្គ ។

## របៀបដោះស្រាយជាមួយអារម្មណ៍អំពីជីវិតនៃអំពើបាបពីអតីតកាលរបស់អ្នក

សាតាំងតែងតែព្យាយាមធ្វើអោយគ្រីស្ទបរិស័ទថ្មីបាក់ទឹកចិត្តដោយការចាប់កំហុសលើពួកគេ ។ វាជួយអ្នកអោយនឹកឃើញពីកំហុសចាស់ៗ ហើយនិយាយថា " អ្នកមានបាបធ្ងន់ណាស់ ។ អ្នកគួរតែមានអារម្មណ៍ថាមានទោសសំរាប់រឿងអាក្រក់ដែលអ្នកបានធ្វើ " ។ អ្នកដឹងថាព្រះជាម្ចាស់ទ្រង់បរិសុទ្ធ និង ល្អឥតខ្ចោះប៉ុណ្ណា ។ ប៉ុន្តែចូរមើលទៅអំពើបាបរបស់អ្នក តើអំពើបាប និង ទោសប៉ុណ្ណាដែលអ្នកបានធ្វើខុស ។ អ្នកមិនអាចប្រៀបជាមួយភាពវិសុទ្ធរបស់ព្រះជាម្ចាស់បានទេ ។

ការផ្តន្ទាទោសរបស់សាតាំង អាចធ្វើអោយគ្រីស្ទបរិស័ទថ្មីបាក់ទឹកចិត្តយ៉ាងងាយស្រួល ហើយធ្វើអោយអារម្មណ៍របស់ពួកគេ ចង់បោះបង់ព្រះជាម្ចាស់ចោល ។ ចូរលើកទឹកចិត្តពួកគេអោយគេពឹងលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ជាពិសេសនៅក្នុង ១ យ៉ូហាន ១:៩ ។ នៅពេលដែលអ្នកសារភាពអំពើបាបរបស់អ្នក ព្រះជាម្ចាស់នឹងលើកលែងទោសអោយ ។ អ្នកមិនចាំបាច់បន្តសារភាពអំពើបាបដដែលៗនោះ ពីមួយថ្ងៃទៅមួយថ្ងៃនោះទេ ។ ប្រសិនបើអ្នកបានសារភាពលើកដំបូងអស់ពីចិត្តហើយនោះវាគ្រប់គ្រាន់ហើយ ។ ព្រះជាម្ចាស់នឹងរក្សាព្រះបន្ទូលសន្យារបស់ទ្រង់ថា នឹងលើកលែងទោសដល់អ្នក ។

សាតាំងវានឹងប្រើគ្រប់អំណាចរបស់វាដើម្បីបោកប្រាស់អ្នក ។ " បើសិនជាព្រះជាម្ចាស់បានលើកលែងទោសអោយអ្នកហើយ ហេតុអ្វីបានជាអ្នកមានអារម្មណ៍ថាមានទោសចំពោះអំពើបាបអ្នកទៀត ? ច្បាស់ណាស់អ្នកទៅតែមានអារម្មណ៍អាម៉ាស់ហើយមានទោសចំពោះអំពើបាបធ្ងន់នោះ! " ចូរប្រាប់សិស្សថា គេយល់ព្រមជាមួយសាតាំងថាគេបានធ្វើបាប ។

លើកទឹកចិត្តគេអោយប្រាប់សាតាំងវិញថា ព្រះជាម្ចាស់បានលើកលែងទោសគេហើយ ហើយគេមានអំណរ និង ភាពសុខសាន្តដោយដឹងថា ព្រះជាម្ចាស់នៅស្រលាញ់គេ ។ ឥឡូវនេះគេគួរតែផ្ចង់ចិត្តទៅព្រះជាម្ចាស់ ហើយអរព្រះគុណ ព្រះអង្គសំរាប់សេចក្តីស្រលាញ់ និង ការលើកលែងទោសនោះ ។ សូមយកឱកាសនេះដើម្បីសុំព្រះជាម្ចាស់ជួយគេ អោយរឹងមាំ និង មិនធ្លាក់ទៅក្នុងអំពើបាបដូចមុនទៀត ។ ប៉ុន្តែទោះបីជាពួកគេធ្វើ ក៏ព្រះអង្គនឹងលើកលែងទោសអោយពួកគេដែរ អោយតែគេសារភាពបាបដោយចិត្តស្មោះ ។

ការឈឺចាប់ខាងអារម្មណ៍ពី ជីវិតបាបអតីតកាលខ្លះអាចត្រូវការជំនួយពីអ្នកផ្តល់ដំបូន្មាន ។ ចូរលើកទឹកចិត្តអ្នកដែលមានបញ្ហាធ្ងន់ធ្ងរពីអតីតកាល អោយរកជំនួយពីអ្នកផ្តល់ឱវាទ ។

# មេរៀន ទី ៣

## ភស្តុតាង : ព្រះគម្ពីរ និង ព្រះវិញ្ញាណដ៏វិសុទ្ធ

### ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវរៀនស្តាប់ពីព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលទ្រង់មានព្រះបន្ទូលមកកាន់ខ្ញុំ ។

### ២. ខ គម្ពីរសំខាន់ រ៉ូម ៨:៩

*ចំពោះបងប្អូន ដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់សណ្ឋិតនៅក្នុងបងប្អូន បងប្អូនមិនមែននៅខាងលោកីយ៍ទៀតទេគឺនៅខាងព្រះវិញ្ញាណ ។ អ្នកណាគ្មានព្រះវិញ្ញាណរបស់ព្រះគ្រិស្ត អ្នកនោះមិនមែនជាកូនចៅរបស់ព្រះអង្គទេ ។*

### ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រ ទី ១៥-២០ នៃសៀវភៅណែនាំរបស់សិស្សដោយរួមជាមួយមេរៀននេះ ។ គំរោង ទី ៦ " ការរកមើលភស្តុតាង " នៅក្នុងសៀវភៅណែនាំសិក្សានឹងត្រូវប្រើមេរៀននេះ ។

### ពត៌មាននៃការរៀបចំរបស់គ្រូជាមុន ✷

សូមរំលឹកចំនុចទី ៤-៨ ខាងក្រោមពីរបីថ្ងៃសិន មុនអ្នកបង្រៀនមេរៀននេះ ។ អ្នកចាំបាច់ត្រូវធ្វើការសំរេចចិត្តនៅចំនុចសំខាន់ៗជាច្រើននៅចំនុចនេះដែលនឹងមានឥទ្ធិពលដល់វិធីអ្នកធ្វើផែនការមេរៀននេះ។

### ៤. ✷ ការជ្រើសរើសនៃវគ្គសិក្សាពីរ

បើកាលវិភាគរបស់អ្នកអនុញ្ញាតអោយអ្នកអាចបែងចែកមេរៀននេះ ហើយបង្រៀនមេរៀននេះជាពីរវគ្គ ។ មេរៀនទី ១លើកយកភស្តុតាងពីព្រះគម្ពីរមកបង្ហាញពីមនុស្សដែលជាគ្រិស្តបរិស័ទ ។ មេរៀនទី ២ លើកយកភស្តុតាងដែលព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញពីមនុស្សជាគ្រិស្តបរិស័ទ ។ ខាងក្រោមនេះគឺជាសេចក្តីពិតនៃព្រះគម្ពីរ និង ខគម្ពីរសំខាន់ៗដែលអាចត្រូវបានយកមកប្រើក្នុងមេរៀនស្តីពីការរកមើលភស្តុតាងខាងព្រះគម្ពីរ ។សេចក្តីពិតសំខាន់ៗនៃព្រះគម្ពីរ : ខ្ញុំចាំបាច់ត្រូវតែរៀនប្រើព្រះគម្ពីរជាឧបករណ៍ដើម្បីប្រមូលយកយកភស្តុតាងដើម្បីបង្ហាញថា ខ្ញុំជាគ្រិស្តបរិស័ទ ។ ខគម្ពីរ សំខាន់ ២ ធីម៉ូថេ ២ : ១៥ ។

### ៥. ✷ ធ្វើផែនការមេរៀនកំឡុងពេលថ្នាក់រៀនមួយ

ផែនការ និង ពេលវេលាដែលត្រូវបានផ្តល់ជូននេះគឺដើម្បីបង្រៀន ភស្តុតាងពីព្រះគម្ពីរ និង ព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងថ្នាក់តែមួយពេល ។

## ៦. ✷ របៀបពីរយ៉ាងដើម្បីរកឃើញភស្តុតាងតាមរយៈព្រះគម្ពីរ

ពាក់កណ្តាលដំបូងនៃមេរៀននេះផ្តោតទៅលើភស្តុតាងនៃព្រះគម្ពីរ ។ មានវិធីពីរយ៉ាងដើម្បីរៀនមេរៀននេះដោយអាស្រ័យទៅលើភាពពេញវ័យខាងព្រលឹងវិញ្ញាណរបស់សិស្ស ។

### ក. របៀបសាមញ្ញ

របៀបសាមញ្ញបំផុតគឺទទួលស្គាល់ថាព្រះគម្ពីរជាធនធានមួយដែលអោយយើងដឹងថាតើមនុស្សនោះគឺជាគ្រីស្តបរិស័ទ ឬក៏ អត់ ។ ចូរចំណាយពេលវេលាដើម្បីពិភាក្សាអំពីខគម្ពីរទាំងនោះ ហើយពន្យល់ថាតើយើងអាចដឹងដោយរបៀបណាអំពីខគម្ពីរទាំងនោះពិតនៅក្នុងជីវិតរបស់យើង ។

### ខ. វិធីដែលមានការពិបាក

វិធីដែលមានការពិបាកជាងនោះគឺ ពាក់កណ្តាលដំបូងនៃមេរៀននេះគឺដើម្បីស្វែងរកពីរបៀបដែលអាចប្រើព្រះគម្ពីរជាឧបករណ៍មួយដើម្បីប្រមូលភស្តុតាងដែលបង្ហាញថាមនុស្សនោះគឺជាគ្រីស្តបរិស័ទ ។ ចូរផ្តោតទៅលើការពិភាក្សានៅលើតំរូវការនៃការសិក្សាព្រះគម្ពីរអោយបានត្រឹមត្រូវ ។ ស្វែងរកពីរបៀបដែលអាចបកស្រាយ និង អនុវត្តព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើងអោយបានត្រឹមត្រូវ និង មើលឃើញនៅលទ្ធផល ។

## ៧. ✷ ធ្វើការវាយតំលៃចំណេះដឹងរបស់សិស្សអំពីព្រះវិញ្ញាណដ៏វិសុទ្ធ

មុនពេលដែលអ្នកចាប់ផ្តើមបង្រៀន វគ្គទីពីរនៃពាក់កណ្តាលមេរៀននេះ ដែលទាក់ទងទៅនឹងភស្តុតាងដែលព្រះវិញ្ញាណដ៏វិសុទ្ធផ្តល់អោយយើងអ្នកចាំបាច់ត្រូវតែប្រុងប្រយ័ត្នក្នុងការវាយតំលៃថាតើសិស្សរបស់អ្នកយល់ដឹងបានប៉ុន្មានហើយអំពីព្រះវិញ្ញាណដ៏វិសុទ្ធនោះ ។ ចូរសំរេចចិត្តវាយតំលៃអោយដឹង មុននឹងចាប់ផ្តើមបង្រៀន ប្រសិនបើអាចធ្វើទៅបាន ។

ចូរបញ្ជាក់អោយពួកគេយល់ច្បាស់ថាព្រះវិញ្ញាណដ៏វិសុទ្ធគឺជាតួអង្គមួយ មិនមែនជាខ្មោចទេ ។ ព្រះអង្គគឺជាព្រះជាម្ចាស់ស្មើជាមួយនឹងព្រះបិតា និង ព្រះបុត្រា ។ សិស្សរបស់អ្នកត្រូវតែយល់ដឹងចំនុចសំខាន់ខ្លះៗនៃគោលបំណងនិង ពន្ធកិច្ចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅថ្ងៃនេះ ។បើមិនគ្មានអ្វីផ្សេងទៀតត្រូវបានសំរេចនៅថ្ងៃនេះទេ យើងចង់អោយសិស្សយល់ដឹងសេចក្តីពិតជាមូលដ្ឋានខ្លះអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ។

ព័ន្ធកិច្ច និងព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺត្រូវបានពិភាក្សាគ្នាជាពិស្តារថែមទៀតនៅក្នុងការសិក្សាជាក្រុមសំរាប់គ្រីស្តបរិស័ទថ្មី ។ " ការរស់នៅរបស់គ្រីស្តបរិស័ទប្រកបទៅដោយជោគជ័យ " (Successful Christian Living)

## ៨. ✷ តើភស្តុតាងរបស់អ្នក ធ្វើអោយអ្នកដែលមិនមែនជាគ្រីស្តបរិស័ទជឿជាក់បានទេ?

ក្នុងការរៀបចំមេរៀននេះ យើងត្រូវការរៀបចំដោយប្រុងប្រយ័ត្នផងដែរ សំរាប់អត្តចរិកមនុស្សសង្ស័យដែលមករកព្រះនិង គ្រីស្តបរិស័ទ ។ តើយើងអាចបង្ហាញភស្តុតាងដែលមនុស្សមិនជឿអាចឃើញនូវតំលៃពិតប្រាកដបានទេ? ប្រសិនបើយើងមិនអាចបង្ហាញភស្តុតាងបានទេ នោះប្រហែលជា យើងមិនបានធ្វើកិច្ចការគ្រប់គ្រាន់ដើម្បីបង្ហាញករណីរបស់យើងនោះទេ ។ វាជាការពិតណាស់ដែល ព្រះវិញ្ញាណដ៏វិសុទ្ធ

ត្រូវធ្វើអោយសេចក្តីពិតទាំងនេះ មានពិតប្រាកដដល់មនុស្សគ្រប់ៗគ្នា ប៉ុន្តែយើងត្រូវតែធ្វើផ្នែករបស់យើងផងដែរ ដោយការរៀបចំដ៏ប្រុងប្រយ័ត្ននៃទស្សនៈរបស់យើង ។

## ៩. ការចាប់ផ្តើមមេរៀន (៥នាទី)

### ក. ការបង្ហាញនូវករណីក្នុងតុលាការ

សូមអោយសិស្សប្រើការត្រិះរិះពិចារណារបស់ពួកគេ នៅពេលដែលអ្នកពិពណ៌នានូវការពន្យល់បង្ហាញខាងក្រោមនេះ ។ សូមធ្វើដំណើរជាមួយខ្ញុំទៅកាន់បន្ទប់កាត់ក្តី ។ ការវិនិច្ឆ័យទោសចាប់ផ្តើម ហើយមេធាវី កំពុងតែបង្ហាញ ខាងពួកគេនៃករណីនេះជាមួយនឹងភស្តុតាងដែលពួកគេបានប្រើ ។ តើភស្តុតាងជាអ្វី?

អនុញ្ញាតអោយសិស្សឆ្លើយ ។ អ្នកអាចបង្អុលបង្ហាញភាពខុសគ្នារវាងភស្តុតាង, ពាក្យចាមអារាម, ពតិមានតៗគ្នា, តឹកតាង ។ ភស្តុតាងអាចជួយអោយគណៈវិនិច្ឆ័យធ្វើការសំរេចចិត្ត ។ តើភស្តុតាងអាចទុកចិត្តបានឬទេ? ការបង្ហាញអ្វីមួយតំរូវ អោយមានភស្តុតាងដែលច្បាស់លាស់ជាទីបំផុតគ្មានសំនួរណាមួយត្រូវបានគេទុកចោលចំពោះការពិតនោះទេ គេត្រូវតែសួរអោយអស់អំពីភស្តុតាងនោះ ។

បន្ទាប់មកនិយាយទៅកាន់សិស្សថា : " នៅពេលដែលមនុស្សក្លាយជាគ្រីស្តបរិស័ទ គាត់ត្រូវតែមានភស្តុតាងដែលអាចយកបាន ។ ភស្តុតាងនេះបង្ហាញយ៉ាងច្បាស់លាស់ពីគ្រីស្តបរិស័ទ ។ តើអ្នកអាចបង្ហាញនូវភស្តុតាងថាអ្នកជាគ្រីស្តបរិស័ទទេ បើសិនជាអ្នកត្រូវគេវិនិច្ឆ័យទោស? តើអ្នកនឹងបង្ហាញនូវភស្តុតាងអ្វីក្នុងរឿងក្តីរបស់អ្នក ? "

ប្រសិនបើសិស្សឆ្លើយនូវសំនួរនេះសូមទទួលចំលើយគេចុះប៉ុន្តែកុំពិភាក្សាយូរពេកទៅលើចំនុចនេះ ។ ប៉ុន្តែប្រសិនបើសិស្សមិនចង់ឆ្លើយតបដោយនិយាយពាក្យសំដីនូវសំនួរនេះទេ គ្រាន់តែនិយាយថា " ថ្ងៃនេះយើងនឹងមើលភស្តុតាងខ្លះៗដែលបង្ហាញថាមនុស្សនេះជាគ្រីស្តបរិស័ទ " ។

## ១០. សកម្មភាពជាក្រុម : រកមើលភស្តុតាង (១៥-២៥ នាទីសំរាប់សកម្មភាពទាំងមូល)

### ក. សកម្មភាពការសិក្សាព្រះគម្ពីរជាក្រុមតូច (៧-១២នាទី )

ចែកសិស្សជាពីរក្រុមហើយអោយក្រុម ក ធ្វើសកម្មភាពដែលទាក់ទងទៅលើភស្តុតាងរបស់ព្រះគម្ពីរ ។ ចាត់ក្រុម ខ អោយធ្វើសកម្មភាពពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញភស្តុតាងថាមនុស្សនេះជាគ្រីស្តបរិស័ទ ។ ប្រសិនបើអ្នកមានសិស្សច្រើន អ្នកអាចបែងចែកច្រើនជាងពីរក្រុម ។

អោយក្រុមនិមួយៗពិនិត្យមើលខគម្ពីរ ដែលមាននៅក្នុងសៀវភៅណែនាំរបស់សិស្ស ដោយភ្ជាប់ជាមួយនឹងសកម្មភាពរបស់ពួកគេ ។ សូមផ្តល់អត្ថបទព្រះគម្ពីរបន្ថែមទៀតដល់ពួកគេ ដែលអ្នកគិតថាការផ្តល់នេះនឹងជួយពួកគេបាន ។ អោយក្រុម និមួយៗនៅក្រដាស ស មួយសន្លឹកធំ និង ហ្វឺតមួយដើម ។ ពួកគេត្រូវសរសេររបាយការណ៍នៅលើក្រដាសនេះ ។

**ក. ក្រុម ក** គួរតែឆ្លើយនូវសំនួរនេះ : តើភស្តុតាងអ្វីដែលព្រះគម្ពីរប្រាប់ខ្ញុំថាខ្ញុំជាគ្រីស្ទបរិស័ទ? ( សូមប្រើ ខ គម្ពីរដែលមានចែងនៅក្នុងសៀវភៅណែនាំរបស់សិស្ស ទំព័រ ទី ៥, ១៥-១៧ )

**ខ. ក្រុម ខ** គួរតែឆ្លើយនូវសំនួរនេះ : តើមានភស្តុតាងអ្វីដែលព្រះវិញ្ញាណផ្តល់មកខ្ញុំ ដើម្បីបង្ហាញយ៉ាងច្បាស់ថា ខ្ញុំជាគ្រីស្ទបរិស័ទពិតប្រាកដ ? (សូមប្រើខគម្ពីរដែលមានចែងនៅក្នុងសៀវភៅណែនាំរបស់សិស្ស ទំព័រ ទី ១៧-១៨)

## ខ. ធ្វើរបាយការណ៍ដល់ថ្នាក់ (៥-១០នាទី)

អោយក្រុម ក រាយការណ៍ដល់ក្នុងថ្នាក់ទាំងមូលពីអ្វីដែលគេបានរកឃើញ ។ បន្ទាប់មកបើកការពិភាក្សានៃប្រធានបទនោះ ។ សិស្សដែលមានសំនួរអោយគេសួរទៅសមាជិករបស់ក្រុមដែលបានផ្តល់របាយការណ៍នេះ ។ អ្នកក៏អាចអោយ សិស្សចែកចាយចំលើយរបស់ពួកគេទៅនឹងសំនួរទី ២ នៃគំរោង ទី ៦ ក៏បានដែរ ។សំនួរនេះសួរគេអោយផ្តល់ខគម្ពីរពីរ ដែលបានជួយគេអោយយល់ដឹងពីជំហានជាមូលដ្ឋានទៅលើរបៀបក្លាយជាគ្រីស្ទបរិស័ទ ។

អោយក្រុម ខ រាយការណ៍ដល់ថ្នាក់ពីអ្វីដែលគេបានរកឃើញនៅក្នុងថ្នាក់ពេលក្រោយ គឺនៅពេលដែលអ្នកចាប់ផ្តើមនិយាយអំពីព្រះវិញ្ញាណដ៏វិសុទ្ធ ។ សូមមើលសកម្មភាព #១៦ នៅក្នុងគំរោងផែនការមេរៀននេះ ។

## ១១. រំលឹកឡើងវិញនូវចំនុចទាំងបីនៃការប្តេជ្ញាចិត្ត (៥នាទី)

បន្ទាប់ពីក្រុម ក បានបង្ហាញរបាយការណ៍រួចហើយ ហើយអ្នកក៏បានពិភាក្សាអំពីការរកឃើញរបស់ពួកគេដែរនោះ ចូរប្រើឱកាសនេះរំលឹកចំនុចទាំងបីដែលជាមូលដ្ឋាននៃការប្តេជ្ញាចិត្តដែលត្រូវបានពិភាក្សានៅក្នុងថ្នាក់លើកមុន ។ ចង្អុលបង្ហាញពីទំនាក់ទំនងជិតស្និតរវាងភស្តុតាងក្នុងព្រះគម្ពីរ និង ការធ្វើការប្តេជ្ញាចិត្តខាងចិត្តគំនិតរបស់អ្នកក្នុងការក្លាយជាគ្រីស្ទបរិស័ទ ។ អ្នកអាចប្រើករណីសិក្សាខាងក្រោមដើម្បីជួយដល់សិស្សអោយគិតពីការប្តេជ្ញាចិត្តទាំងបីនេះ ។

**ករណីសិក្សា : គ្រីស្ទបរិស័ទថ្មីដែលមានចិត្តឆេះឆួល**

ពីរបីថ្ងៃកន្លងមកនេះ ជាពេលដំបូងដែលលោកពេត្រុសបានឮពីផែនការសង្គ្រោះរបស់ព្រះជាម្ចាស់ ។ ពីមុនមកគាត់មិនដែលបាននិយាយជាមួយគ្រីស្ទបរិស័ទដ៏ពិតប្រាកដដូចនេះទេ ដូច្នេះនេះគឺជារឿងថ្មីសំរាប់គាត់ ។ គាត់ពេញចិត្តនឹងអ្វីដែលគាត់បានឮ ហើយបានសំរេចចិត្តក្លាយជាគ្រីស្ទបរិស័ទ ។ នេះគឺជាចរិកលក្ខណៈរបស់លោកពេត្រុស គាត់ជារឿយធ្វើការសំរេចចិត្តយ៉ាងឆាប់រហ័ស ។

រយៈពេល៤ថ្ងៃហើយ ដែលលោកពេត្រុសបានអធិស្ឋានក្លាយជាគ្រីស្ទបរិស័ទ ។ តាំងពីពេលនោះមក គាត់ដកពិសោធន៏ច្រើនជាងទៅលើជំលោះ និង បញ្ហាសាមញ្ញរបស់គាត់ ។ " ខ្ញុំគិតថា ព្រះគួរតែធ្វើអោយជីវិតរបស់ខ្ញុំប្រសើរជាងមុន ។ ខ្ញុំគិតថាការនេះបោកបញ្ឆោតដ៏ធំធេង ។ បើសិនជាគ្រីស្ទបរិស័ទដ៏ពិតប្រាកដមែន រឿងរ៉ាវជាច្រើននឹងប្រព្រឹត្តទៅយ៉ាងល្អប្រសើរសំរាប់ខ្ញុំហើយ ។

**សំនួរសំរាប់ការពិភាក្សា**

១. ប្រើចំនុចទាំងបីនៃការប្ដេជ្ញាចិត្តដែលយើងបានពិភាក្សានៅក្នុងថ្នាក់ពីវគ្គមកហើយ និង ធ្វើការវាយតំលៃទៅលើការសំរេចចិត្តរបស់លោកពេត្រុសក្នុងការក្លាយជាគ្រីស្ទបរិស័ទ ។

២. តើការសំរេចចិត្តយ៉ាងឆាប់រហ័យរបស់លោកពេត្រុសក្នុងការក្លាយជាគ្រីស្ទបរិស័ទមានការទាក់ទងទៅនឹងការប្ដេជ្ញាចិត្តខាងចិត្តគំនិតយ៉ាងដូចម្ដេចដែរ?

៣. ឥឡូវនេះតើអ្នកមានយោបល់អ្វីខ្លះដើម្បីជាជំនួយដល់លោកពេត្រុស?

## ១២. រៀនពីរបៀបសិក្សាព្រះគម្ពីរ (៥-១៥ នាទី)

យើងបានបង្ហាញថា ព្រះគម្ពីរមានសេចក្ដីពិតប្រាប់អ្នកពីរបៀបក្លាយទៅជាគ្រីស្ទបរិស័ទ ។ យើងចង់ពន្យល់អោយបាន ច្បាស់លាស់ថា មានខគម្ពីរជាច្រើននៅក្នុងព្រះគម្ពីរអាចត្រូវបានប្រើដើម្បីផ្ដល់ជាភស្តុតាងថាមនុស្សគឺជាគ្រីស្ទបរិស័ទ ។ ប្រសិនបើ គ្រីស្ទបរិស័ទថ្មីទាំងនេះមានលទ្ធភាពអាចរក និង ប្រើយ៉ាងមានប្រសិទ្ធិភាពនៅសេចក្ដីពិតនៃព្រះគម្ពីរទាំងនេះ នោះពួកគេនឹង បង្កើតនៅវិធីសាស្ត្រមួយដ៏មានប្រយោជន៍ក្នុងការសិក្សាព្រះគម្ពីរ ។

ប្រធានបទនេះនឹងបង្ហាញយ៉ាងពិស្ដារនៅក្នុងការសិក្សាជាក្រុមសំរាប់គ្រីស្ទបរិស័ទថ្មីនៅក្នុងសៀវភៅ *របៀបសិក្សាព្រះគម្ពីរ* ។ ប្រសិនបើអ្នកមានពេលវេលាសូមពិភាក្សាជាមួយសិស្សរបស់អ្នកនៅវិធីសាស្ត្រជាមូលដ្ឋានសំរាប់សិក្សា ព្រះគម្ពីរ ។ សូមធ្វើអោយប្រាកដថា ពួកគេចេះប្រើលេខសំគាល់ដើម្បីរកខគម្ពីរនៅក្នុងប្រធានបទពិសេសណាមួយ ។

អោយគេមានការប្រុងប្រយត្ន័នៅគ្រោះថ្នាក់ក្នុងការយកខគម្ពីរចេញមកពីអត្ថបទ ។ សូមពន្យល់បង្ហាញថាតើមានអត្ថន័យយ៉ាងដូចម្តេច ។ សូមមើលទំព័រ ទី ១៦ នៃសៀវភៅណែនាំរបស់សិស្សសំរាប់ពតិមានបន្ថែម ។

ក្នុងការសង្ខេបផ្នែកនៃមេរៀននេះ សូមចង្អុលបង្ហាញពីសារៈសំខាន់នៃការសិក្សាព្រះគម្ពីរដើម្បីរៀនអោយយល់ដឹងថា អ្វីដែលព្រះជាម្ចាស់ត្រូវមានព្រះបន្ទូលអំពីទំនាក់ទំនងរបស់យើងជាមួយនឹងទ្រង់ក្នុងនាមជាបុត្រធីតារបស់ព្រះអង្គ ។

## ១៣. អ្នកត្រូវតែគោរពការបង្រៀនក្នុងព្រះគម្ពីរ (៣-៥ នាទី)

យើងចាំបាច់ត្រូវតែបញ្ជាក់អោយច្បាស់លាស់ថា ព្រះគម្ពីរផ្តល់ភស្តុតាងច្រើនជាងផ្តល់សេចក្តីពិតដើម្បីបង្ហាញពីរបៀបក្លាយជាគ្រីស្ទបរិស័ទ ។ ក្រោមចំនុចទី ២នៃទំព័រទី១៦ ក្នុងសៀវភៅណែនាំរបស់សិស្សបង្ហាញថា ពេលមនុស្សម្នាក់ក្លាយជាគ្រីស្ទបរិស័ទ គាត់ត្រូវគោរពការបង្រៀនតាមព្រះគម្ពីរ ។ នៅពេលដែលអ្នកគោរពតាមការបង្រៀនទាំងនោះ អ្នកប្រមូលបន្ថែមនូវភស្តុតាងផ្ទាល់ខ្លួនដោយចាត់ទុកថា ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតប្រាកដ ។ យើងភាគច្រើនមិនអាចគោរពបានយ៉ាងខ្ជាប់ខ្ជួនទេនៅការបង្រៀនទាំងនេះដោយកំឡាំងខ្លួនឯងផ្ទាល់របស់យើង ។ យើងត្រូវតែមានជំនួយមកពីព្រះដើម្បីធ្វើកិច្ចការនេះបាន ។

លើកទឹកចិត្តសិស្សឱ្យរកខគម្ពីរ ដែលទាក់ទងទៅនឹងកន្លែងនៃជីវិតពួកគេ ដែលជាកន្លែងដែលពួកគេចង់លូតលាស់ ។ ប្រាប់ពួកគេអោយបង្កើតនៅគោលដៅដែលពួកគេនឹងអាចសំរេចចិត្តបានដោយមានជំនួយពីព្រះជាម្ចាស់ ។ ភាពទទួលជោគជ័យទាំងនេះ ជាពតិមានដ៏សំខាន់សំរាប់ទីបន្ទាល់ផ្ទាល់ខ្លួនដ៏មានប្រសិទ្ធភាព ដើម្បីបញ្ជាក់ថា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាសេចក្តីពិត ។ ប្រាប់ពួកគេអោយចែកចាយគំរូទាំងនេះ នៅពេលដែលពួកគេធ្វើទីបន្ទាល់នៅក្នុងព្រះវិហារ ឬក៏ ពេលដែលពួកគេផ្សាយដំណឹងល្អដល់អ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ ។

## ១៤. សេចក្តីពិតដែលមានក្នុងព្រះគម្ពីរមិនផ្លាស់ប្តូរទេ (៣-១០នាទី)

ព្រះគម្ពីរផ្តល់អោយភស្តុតាងយ៉ាងច្បាស់លាស់ដែលអាចពឹងពាក់បាន ។ សូមមើលនៅទំព័រទី១៦-១៧ សៀវភៅណែនាំរបស់សិស្ស ដើម្បីពតិមានបន្ថែមទៀតទៅលើចំណុចនេះ ។ មិនតែប៉ុណ្ណោះនៅក្នុងការសិក្សាជាក្រុមសំរាប់គ្រីស្ទបរិស័ទថ្មី មុខវិជ្ជា *មើលព្រះគម្ពីរយ៉ាងលឿន* (A Quick look at the bible) មានការរៀបរាប់យ៉ាងលំអិតអំពីរឿងនេះ ដែលជាមុខវិជ្ជាបន្ទាប់ពីមេរៀននេះដែលអ្នកបង្រៀននៅក្នុងសេរីនេះ បើអ្នកធ្វើតាមការស្នើឡើងតាមលំដាប់លំដោយការបង្រៀននោះ ។

## ១៥. ភស្តុតាងដែលតម្រូវឱ្យមានសេចក្តីសំរេចចិត្ត (២-១០នាទី)

លោក យូស អិមស៊ីដូវែល (Josh McDowell) បានសរសេរសៀវភៅជាច្រើនដែលផ្តល់ឱ្យនូវទ្រព្យសម្បត្តិ ជាភស្តុតាងទៅលើភាពពិតរបស់ព្រះគ្រីស្ត និង ព្រះគម្ពីរ ។ ខាងក្រោមនេះជាសៀវភៅខ្លះ៧របស់គាត់ ។ អ្នកអាចណែនាំដល់សិស្សរបស់អ្នកអោយ ស្គាល់នៅសៀវភៅទាំងនេះ និង បង្ហាញពួកគេអំពីរបៀបប្រើប្រាស់ ដើម្បីប្រមូល ផ្តុំភស្តុតាងផ្ទាល់ខ្លួនបន្ថែមទៀត ក្នុងការក្លាយខ្លួនជាគ្រីស្តបរិស័ទ ។

ភស្តុតាងដែលតម្រូវឱ្យមានសាលក្រម

ភស្តុតាងបន្ថែមដែលតម្រូវឱ្យមានសាលក្រម

មិនមែនត្រឹមតែជាងឈើ

ហេតុផលដែលធ្វើឱ្យនៅតែសង្ស័យលើព្រះគ្រីស្ត

កត្តាស្ដីពីការរស់ឡើងវិញ

ភស្តុតាងសំរាប់ជំនឿ

## ១៦. សេចក្តីរាយការណ៍របស់ក្រុម ខ អំពីព្រះវិញ្ញាណដ៏វិសុទ្ធ (៥-១០នាទី)

ធ្វើការណែនាំសង្ខេបពីពាក់កណ្ដាលមេរៀនទី ២ ដោយចង្អុលបង្ហាញថា ព្រះវិញ្ញាណដ៏វិសុទ្ធក៏អាចផ្តល់ភស្តុតាងអោយដឹងថាមនុស្សនោះគឺជាគ្រីស្តបរិស័ទបានដែរ ។ អោយក្រុម ខ ប្រាប់ដល់ថ្នាក់រៀននូវអ្វីដែលពួកគេរកឃើញ ។ សូមមើលសកម្មភាព # ១០នៅក្នុងគំរោងមេរៀន ដើម្បីទទួលពត៌មានលំអិតអំពីរឿងនេះ ។

បន្ទាប់ពីសិស្សធ្វើការបកស្រាយរួចហើយ នោះក៏ឈានដល់ការពិភាក្សាគ្នាទៅលើចំនុចសំខាន់៧ដែលបានធ្វើ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ទំព័រ១៧-២០ ។ បើសិនជាក្នុងក្រុម ធ្វើកិច្ចការនេះបានល្អពេញលេញទៅលើ បញ្ហាទាំងនេះ ចូរបន្តពិភាក្សាអោយបានពិស្តារលើចំនុចណាដែលអ្នកចង់ ។

## ១៧. ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកគង់នៅក្នុងជីវិតអ្នក (៥នាទី)

រឿងរ៉ាវនេះត្រូវបានបកស្រាយនៅទំព័រទី១៦-១៧ ក្នុងសៀវភៅណែនាំរបស់សិស្ស ។ សំរាប់ជាប្រយោជន៍ ដល់ថ្នាក់ទាំងមូល អ្នកអាចអាន ហើយពិភាក្សាទៅលើខគម្ពីរដែលមានក្នុងអត្ថបទនេះ។ ដើម្បីអោយមានភាព ច្បាស់លាស់ លុះត្រាតែព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់ក្នុងជីវិតមនុស្ស នោះគឺមានការសង្គ្រោះភ្លាម ។ តើទ្រង់គង់នៅឯណា? ព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅក្នុងវិញ្ញាណរបស់យើង ។ ចូរពន្យល់ថាតើវិញ្ញាណរបស់អ្នកនៅឯណា ។ (អាចឆ្លើយបែបជាកំប្លែង) ចូរប្រើសំនួរនេះជាចុងក្រោយ ដើម្បីនាំចូលទៅកាន់ការពិភាក្សាគ្នាលើចំនុចសំខាន់ជា បន្តទៀត "ហេតុអ្វីបានជាព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់នៅក្នុងជីវិតរបស់អ្នកបន្ទាប់ពីអ្នកក្លាយជាគ្រីស្តបរិស័ទ?"

## ១៨. ព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើជាគ្រូរបស់អ្នក (៥~១០នាទី)

ធ្វើការពិភាក្សាខ្លីពីតួនាទីនៃព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតគ្រីស្ទបរិស័ទ ។ យើងបាននិយាយរួចហើយតាំងពីដើមដំបូងនៃគំរោងមេរៀននេះអំពីសេចក្តីត្រូវការអោយឆាប់យល់ដឹងចំពោះសិស្សរបស់យើង និង កំណត់នៅអ្វីនៃការយល់ដឹងរបស់ពួកគេចំពោះព្រះវិញ្ញាណដ៏វិសុទ្ធ ។ បើសិស្សរបស់អ្នកមានការយល់ដឹងបន្តិចបន្តួច ឬគ្មានការយល់ដឹងអំពីបញ្ហាទាំងនេះសោះ សូមអ្នករកពេលវេលាពន្យល់គេជាសង្ខេប អោយរឹតតែច្បាស់អំពីព្រះវិញ្ញាណដ៏វិសុទ្ធជានរណា។ សូមឱ្យសិស្សរបស់អ្នកយល់អោយច្បាស់ថាព្រះវិញ្ញាណដ៏វិសុទ្ធនោះហើយគឺជាព្រះ។

អ្នកអាចពិភាក្សាអោយបានល្អិតល្អន់ថែមទៀតនៅចំលើយខ្លះៗទៅលើសំនួរនេះ : " តើព្រះវិញ្ញាណដ៏វិសុទ្ធ បង្រៀនអ្នកដោយរបៀបណា"? ចូរសរសេរចំលើយរបស់ពួកគេនៅលើក្តារខៀន ឬក៏បញ្ចាំងជូនតាមស្លាយ ។ ព្រះអង្គមិនបង្រៀនយើង ឬក៏មិនបញ្ជូនមកអោយយើងជាសំបុត្រតាមប្រៃណសនីយ៍ពិសេសដែរ ។ ជាញឹកញាប់ទ្រង់ប្រើព្រះគម្ពីរ និង មនុស្សដែលនៅជុំវិញយើង និង ឈរនៅក្បែរយើងដើម្បីណែនាំយើងទៅរកសេចក្តីពិត ដោយមាន"ព្រះសូរសៀងខ្សឹបខ្សៀវប្រាប់យើង"។

## ១៩. តើព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលមកយើងដោយរបៀបណា? (៥~១០នាទី)

អោយសិស្សពិភាក្សាគ្នាអំពីចិត្តគំនិតរបស់ពួកគេថាតើពួកគេស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធដោយរបៀបណា និង តើពួកគេដឹងដោយរបៀបណាពេលព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលមកពួកគេ? អ្នកអាចចោទសួរសំនួរខាងក្រោម នៅលើក្តារខៀន ឬបញ្ចាំងស្លាយ រួចហើយសរសេរចំលើយរបស់ពួកគេ : " តើព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូល ទៅកាន់អ្នកដោយរបៀបណា?" ត្រង់ចំនុចនេះ អ្នកអាចពិភាក្សានៅចំលើយរបស់ពួកគេទៅនឹងសំនួរទី ៤ និង ទី ៥ នៃគំរោង ទី ៦ ។

ទុកពេលសំរាប់ការខុសប្លែកគ្នានៅក្នុងចំលើយរបស់សិស្ស ។ គួសបញ្ជាក់ថា ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើជាសក្ខីភាព នៅក្នុងវិញ្ញាណរបស់យើង ដើម្បីប្រាប់យើងថាយើងជាកូនព្រះ ។ កម្រមានគ្រីស្ទបរិស័ទបានឮព្រះវិញ្ញាណដ៏វិសុទ្ធ មានព្រះបន្ទូលមកកាន់ពួកគេខ្លាំងៗទៅតាមមធ្យោបាយដែលមនុស្សមានទំនាក់ទំនងនោះណាស់ ។ ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលមកយើងតាមរយៈវិញ្ញាណរបស់យើង នេះគឺការជាបញ្ហាទំនាក់ទំនងខាងក្នុង ។ អ្នកអាចពិភាក្សា សំនួរនេះជាមួយនឹងបុគ្គលិកដទៃទៀតទៅតាមកន្លែងនៃក្រសួងរបស់អ្នក ឬជាមួយនឹងគ្រូគង្វាល ដើម្បីទទួលនូវ គំនិតខ្លះៗថែមទៀត ពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលមកកាន់ពួកគេ ។

ជាច្រើនដងគ្រីស្ទបរិស័ទថ្មីមានមន្ទិលសង្ស័យ ថាតើពួកគេជាគ្រីស្ទបរិស័ទពិតប្រាកដ ឬមិនមែនជាគ្រីស្ទបរិស័ទ ពិតប្រាកដ? ពួកគេមានគំនិតនេះ។ ឥឡូវនេះអ្នកអាចពិភាក្សាសំនួរទាំងនេះបើអ្នកមានពេល។

បើគ្មានពេលទេសូមធ្វើការបកស្រាយខ្លីៗចំពោះរឿងនេះរួចហើយជំរាបពួកគេថាយើងនឹងពន្យល់ថែមទៀតនៅជំពូកទីបួននៃ មុខវិជ្ជានេះ នៅពេលដែលយើងនិយាយអំពីមន្ទិលសង្ស័យ ។

(១) តើខ្ញុំដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលមកខ្ញុំដោយរបៀបណា ឬវាគ្រាន់តែជាគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំ?

(២) តើមានវិធីណាអោយយល់ដឹងនៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូល ដើម្បីកុំអោយច្រឡំនៅពេលដែលមានការគិតផ្សេងៗពីក្នុងគំនិតរបស់ខ្ញុំនោះដែលមិនមែនមកពីព្រះវិញ្ញាណដ៏វិសុទ្ធទេ?

(៣) តើខ្ញុំដឹងបានដោយរបៀបណានៅពេលសាតាំងបញ្ចូលគំនិតមកក្នុងខ្ញុំ? (សូមចងចាំសាតាំងនឹងធ្វើដូចជាពន្លឺរបស់ទេវតា) ។

ក្នុងការពិភាក្សាអំពីសំនួរទាំងនេះ យើងត្រូវជួយឱ្យពួកគេមើលឃើញថា ការស្តាប់ព្រះជាម្ចាស់គឺជាចំនុចមួយ ដែលមានឱកាសសំរាប់ឱ្យលូតលាស់ទៅមុខក្នុងរយៈពេលជាច្រើនឆ្នាំ។ សូមមើលទំព័រទី១៧-១៩ នៅក្នុងសៀវភៅណែនាំសំរាប់សិស្ស ដើម្បីជាពត៌មានបន្ថែមនៅ គំនិត ៥ យ៉ាងដែលអាចប្រើដើម្បីសំរេចចិត្តថាតើព្រះវិញ្ញាណដ៏វិ សុទ្ធមានបន្ទូលមកកាន់អ្នកឬយ៉ាងណា ។

ត្រូវចេះរកវិធីផ្សេងៗ ដើម្បីធ្វើការថ្លឹងថ្លែង ថាតើជាគំនិតយើងឬជាព្រះសូរសៀងពីព្រះវិញ្ញាណដ៏វិសុទ្ធ ។ យើង មានព្រះគម្ពីរដែលបញ្ជូនមកពីព្រះជាម្ចាស់យ៉ាងច្បាស់លាស់ អ្វីដែលមានចែងក្នុងព្រះគម្ពីរមិនមែនជាគំនិតយើង ទេ។ យើងអាចអានព្រះគម្ពីរហើយដឹងថានេះគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

## ២០. កាន់តែយល់ដឹងថែមទៀតនូវសំលេងនៃព្រះវិញ្ញាណដ៏វិសុទ្ធ (៥-១០នាទី)

បើសិនជាអ្នកមានពេល ហើយសិស្សមានការរឹងមាំគ្រប់គ្រាន់សំរាប់ទទួលផលប្រយោជន៍មកពីការពិភាក្សា ចូរនិយាយអំពីរបៀបដែលកាន់តែយល់ដឹងថែមទៀតនូវសំលេងនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។ សូមអោយពួកគេមានការ យល់ដឹងអោយច្បាស់នូវមូលហេតុដែលព្រះវិញ្ញាណមានព្រះបន្ទូលមកកាន់យើង។

ជាច្រើនដង ព្រះវិញ្ញាណដ៏វិសុទ្ធ មានព្រះបន្ទូលមកកាន់យើងតាមរយៈសតិសម្បជញ្ញៈរបស់យើង។ អ្នកអាច ពិភាក្សាពីអ្វីដែលជាមនសិការរបស់យើង និង ពីរបៀបអំពើបាបប៉ះទង្គិចដល់មនសិការ។ ចង្អុលបង្ហាញពីតម្រូវការ ក្នុងនាមយើងជាកូនព្រះ ដើម្បីរៀនអោយកាន់តែយល់ដឹងថែមទៀតចំពោះសតិសម្បជញ្ញៈរបស់យើង។

## ២១. ការអនុវត្តន៍ផ្ទាល់ខ្លួន

កិច្ចការអនុវត្តន៏ផ្ទាល់ខ្លួនជាច្រើនទៀតនៅមាននៅខាងក្រោម ។ សូមជ្រើសរើសមួយ ឬច្រើនទៀតដែល អ្នកគិត ថាអាចជួយដល់សិស្សរបស់អ្នក ។

### ក. សរសេរអត្ថបទមួយអំពីព្រះវិញ្ញាណដ៏វិសុទ្ធ (៥-១០នាទី)

អោយសិស្សសរសេរការពិពណ៌នាអត្ថបទមួយទៅលើការទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកគេជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធ។ សូមឱ្យពួកគេគិត ហើយឆ្លើយសំនួរទាំងនេះខណៈពេលដែលពួកគេសរសេរ ។

(១) តើព្រះវិញ្ញាណដ៏វិសុទ្ធដែលមានព្រះបន្ទូលមកខ្ញុំឬអត់?

(២) តើព្រះវិញ្ញាណដ៏វិសុទ្ធបានបង្រៀនអ្វីខ្លះដល់ខ្ញុំ? បើសិនជាទ្រង់បានបង្រៀនតើបង្រៀនអ្វីសូមអោយឧទាហរណ៍មួយ? ចូរសរសេរបញ្ជីចំនុចខ្លះៗនៃជីវិតរបស់អ្នកផងដែរ ដែលអ្នកចង់អោយព្រះវិញ្ញាណដ៏វិសុទ្ធបង្រៀនអ្នក ។

(៣) តើខ្ញុំអាចស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធឱ្យកាន់តែជិតស្និតបន្ថែមទៀតដោយរបៀបណា?

### ខ. ករណីសិក្សានៅលើរឿងអំពីគ្រីស្ទបរិស័ទថ្មី (៥-១០នាទី)

បង្ហាញរឿងខាងក្រោម ហើយអោយសិស្សសរសេរចំលើយរបស់ពួកគេលើក្រដាស ។ មិត្តថ្មីរបស់អ្នកម្នាក់បានបង្ហាញការចាប់អារម្មណ៏យ៉ាងខ្លាំងក្នុងការក្លាយទៅជាគ្រីស្ទបរិស័ទ។ មនុស្សនេះបានអធិស្ឋានជាមួយអ្នក សូមព្រះយេស៊ូយាងមកគង់ក្នុងជីវិតរបស់គាត់ ហើយសង្គ្រោះគាត់។ មិត្តរបស់អ្នកបានឆ្លងកាត់បញ្ហាពិបាកៗយ៉ាងច្រើនកាលពី ពីរបីថ្ងៃកន្លងមកនេះ ។ គាត់បានប្រាប់អ្នកថា " ខ្ញុំមិនគិតថាខ្ញុំជាគ្រីស្ទបរិស័ទទេ ពីព្រោះបើខ្ញុំជាគ្រីស្ទបរិស័ទ ខ្ញុំមិនគិតថាព្រះនឹងអោយខ្ញុំជួបពីបញ្ហាទាំងនេះទេ " ។ តើអ្នកលើកទឹកចិត្ត មិត្តភក្តិ របស់ អ្នកដោយរបៀបណា បើគាត់មិនច្បាស់លាស់ថាគាត់ជាគ្រីសបរិស័ទនោះ? បន្ទាប់ពីសិស្សបានសរសេរ ចំលើយ របស់ពួកគេ អ្នកអាចយកពេលវេលាដើម្បីពិភាក្សាទៅលើចំលើយរបស់ពួកគេខ្លះៗជាមួយនឹងសិស្សនៅក្នុងថ្នាក់ទាំងអស់ ។

### គ. កំណត់ហេតុនៃភស្តុតាងផ្ទាល់ខ្លួននៃការក្លាយជាគ្រីស្ទបរិស័ទ (៥នាទី)

លើកទឹកចិត្តសិស្សអោយសាកល្បងពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ រួចចាំមើលថាតើពួកគេអនុវត្តន៏ប្រចាំថ្ងៃ ក្នុងជីវិតរបស់ពួកគេឬអត់ ។ សូមឱ្យពួកគេចុះក្នុងសៀវភៅកំណត់ហេតុ ឬក៏ ទស្សនាវដ្តីនៃរឿងរ៉ាវពិសេសៗ ដែលព្រះបានធ្វើសំរាប់ពួកគេ ។ ពួកគេគួរតែសរសេរទីកន្លែងដែលពួកគេបានឃើញ

ព្រះអម្ចាស់ឆ្លើយតបទៅនឹងព្រះបន្ទូល សន្យារបស់ទ្រង់ដល់ពួកគេ ។ ឥឡូវនេះអ្នកអាចអោយពួកគេយកពេលវេលាដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ហេតុ ឬក៏ ទស្សនាវដ្ដី ជាលើកដំបូងរបស់ពួកគេ ។

**ឃ. បញ្ជីនៃបញ្ហាថ្មីៗ (៥នាទី)**

កិច្ចការអនុវត្តន៍ផ្ទាល់នេះទាក់ទងទៅនឹងការរៀនដើម្បីពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធបន្ថែមទៀត នៅក្នុងសកម្មភាពប្រចាំថ្ងៃ ។ អោយពួកគេធ្វើបញ្ជីបញ្ហាមួយដែលពួកគេជួបប្រទះក្នុងសប្ដាហ៍នេះ ជាពិសេសគឺបញ្ហាទាំងនេះដែលពួកគេមិនអាចដោះស្រាយបាន តាមប្រាជ្ញាផ្ទាល់ខ្លួន ឬក៏ កំលាំងផ្ទាល់ខ្លួនរបស់ពួកគេ ។ អោយពួកគេរកមើល ខគម្ពីរដែលទាក់ទងទៅនឹងបញ្ហាទាំងនេះ ហើយបន្ទាប់មកអធិស្ឋានសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធផ្ដល់នូវប្រាជ្ញា ដើម្បីអោយបានយល់ដឹងហើយចាប់ផ្ដើមតទល់ទៅនឹងបញ្ហានិមួយៗ ។

## ២២. កិច្ចការដែលត្រូវធ្វើ

១. មុននឹងបញ្ចប់ការសិក្សា សូមផ្ដល់ចំណោទសួរ នៅខ គម្ពីរ រ៉ូម ៨:១៦

២. ដាក់ពិន្ទុគំរោង ទី ៣ " ធ្វើការប្ដេជ្ញាចិត្តចំពោះព្រះយេស៊ូគ្រីស្ទ "

៣. ដាក់ពិន្ទុគំរោង ទី ៤ " ការបង្ហាញចំនុចទាំងបីនៃការប្ដេជ្ញាចិត្ត " នៅថ្ងៃនេះ ឬបន្ទាប់ពីវគ្គសិក្សាក្រោយ ។

## ២៣. ការវាយតំលៃ និង គំនិតរបស់ខ្ញុំសំរាប់ការបង្រៀនមេរៀននេះនៅពេលក្រោយ

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក ។

# មេរៀន ទី ៤

## គស្ទុគាថ : ការផ្លាស់ប្តូរគ្នូចជីវិតរបស់អ្នក

### ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំត្រូវការរួមជាមួយនឹងព្រះជាម្ចាស់ដើម្បីធ្វើការផ្លាស់ប្តូរនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំ ដែលជួយខ្ញុំអោយរីតតែនៅក្បែរទ្រង់ ។

### ២. ខគម្ពីរសំខាន់ : ភីលីព ១ : ៣

ខ្ញុំជឿជាក់ថាព្រះអង្គដែលបានធ្វើការយ៉ាងអស្ចារ្យនៅក្នុងជីវិតលោកអ្នក ទ្រង់នឹងធ្វើការនេះរហូតដល់ព្រះយេស៊ូគ្រីស្តយាងមកវិញម្តងទៀត ។

### ៣. យោងតាមឯកសាររបស់សិស្ស

ក្នុងសៀវភៅណែនាំរបស់សិស្សទំព័រ ទី ២០-២៦ ស៊ីគ្នាជាមួយនឹងមេរៀននេះ។ គំរោង ទី ៣,៤,៦ និង ទី ៧ នៅក្នុងសៀវភៅណែនាំក្នុងការសិក្សា នឹងត្រូវបានយកមកប្រើជាមួយនឹងមេរៀននេះដែរ ។

### ៤. ការចាប់ផ្តើមមេរៀន " ៥នាទី "

#### ក. សង្ខេបរឿងយុវវ័យចូលបំរើកងទ័ព

អានរឿងបុរសម្នាក់ចូលបំរើក្នុងជួរកងទ័ព ដែលមិនបានប្រាប់នរណាម្នាក់អស់រយៈពេលពីរឆ្នាំមក ហើយដែលគាត់បានធ្វើជាគ្រីស្តបរិស័ទ ។ រឿងនេះមកពីសៀវភៅ The Mind Changes ដោយលោក **អែមគ្រីវហ្វីន** ជាអ្នករៀបចំប្រវត្តិនេះឡើងនៅឆ្នាំ ១៩៧៦ ទំព័រ ២០៧ ។

រឿងនេះមានភាពជូរចត់ណាស់អំពីតំបន់ភ្នំ **វីជិនសៀ** ភាគខាងលិចដែលក្មេងប្រុសបាន ចូលបំរើជាកងទ័ព។ តាមការលើកឡើងអំពីព្រះវិហារដ៏តូចមួយនៅដាច់ស្រយាល ហើយគាត់និងសមាជិកព្រះវិហារទាំងអស់មានសេចក្តីព្រួយបារម្ភដោយការចេញទៅពិភពខាងក្រៅនាំអោយគាត់បាត់បង់នូវជំនឿរបស់គាត់ពួកគេនាំគ្នាអធិស្ឋានពេញមួយយប់ក្នុងការនៅរង់ចាំគាត់ក្នុងរាត្រីនោះមុនពេលគាត់ចាកចេញពីជំរុំ ។ ក្មេងប្រុសនោះមិនបាន សរសេរសំបុត្រមកផ្ទះទេ ក្នុងរយៈពេលពីរឆ្នាំនោះស្ថិតក្នុងការងារយ៉ាងខ្ជាប់ខ្ជួន ដូច្នេះរឿងនេះសមាជិកទាំងមូលត្រិះរិះ ពិចារណា ហើយមានការ រួបរួមគ្នាសួរគាត់ថា តើរឿងនេះប្រព្រឹត្តទៅដោយរបៀបណា? តើអ្នកប្រកាន់ជាប់យ៉ាងខ្លាំង នឹងជំនឿអ្នកបានទេ? បុរសនោះឆ្លើយវិញថា តើអ្នកដឹងថាខ្ញុំមានការភិតភ័យយ៉ាងខ្លាំងទេ ប៉ុន្តែ សេចក្តីអធិស្ឋាន របស់អ្នកជួយខ្ញុំបាន ច្រើនណាស់ ។ ខ្ញុំបានធ្វើជាទាហានពីរឆ្នាំហើយ ហើយគ្មាននរណាម្នាក់ដឹងថា ខ្ញុំជាគ្រីស្តបរិស័ទទេ ។

ចូរពន្យល់ជាសង្ខេបដែលយើងនឹងពិភាក្សាថ្ងៃនេះអោយមានឥទ្ធិពលលើជីវិតថ្មីរបស់យើងរួមជាមួយព្រះគ្រីស្ទដោយចាប់ផ្តើមនៅនឹងគំនិតរបស់យើង នៅក្នុងអារម្មណ៍របស់យើង និង នៅក្នុងការប្រព្រឹត្តរបស់យើង ។

## ៤. រំលឹកឡើងវិញនៅលើការប្តេជ្ញាចិត្តទាំងបីចំនុច

បន្ទាប់ពីអ្នកបានចែកចាយសាច់រឿងខាងលើ សូមសួរសិស្សអោយវាយតំលៃទៅលើកិរិតប្តេជ្ញាចិត្តនៃបុរសម្នាក់នេះ អំពីការមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ។ បន្ទាប់មកសូមសួរសិស្សមួយនាក់ ឬ ពីរនាក់អោយចែកចាយចំលើយរបស់ពួកគេដល់សិស្សនៅក្នុងថ្នាក់តាមគំរោង ទី៤ ដែលនិយាយពី( ការបង្ហាញចំនុចទាំងបីនៃការប្តេជ្ញាចិត្ត) នៅក្នុងសៀវភៅណែនាំក្នុងការសិក្សា ។ សង្ឃឹមថាសិស្សនឹងចាប់ផ្តើមយល់ពីសារសំខាន់នៃការប្តេជ្ញាចិត្តនៃចំនុចទាំងបីនេះ សំរាប់ជីវិតរបស់ពួកគេ ។

## ៥. ណែនាំប្រធានបទនៅលើការកែប្រែជីវិតថ្ងៃនេះ (៥នាទី)

ដើម្បីជាការផ្លាស់ប្តូរវគ្គជាបន្តបន្ទាប់ក្នុងមេរៀន ចូរគូសបញ្ជាក់ចំនុចនៃការប្តេជ្ញាចិត្តពេលដែលមនុស្ស ក្លាយជាគ្រីស្ទបរិស័ទ ត្រូវតែមានប្រសិទ្ធភាពលើជីវិតរស់នៅប្រចាំថ្ងៃរបស់គាត់ ។ ថ្ងៃនេះយើងនឹងពិភាក្សាអំពីការផ្លាស់ប្តូរ ដែលនឹងចាប់ផ្តើមធ្វើឡើងនៅក្នុងជីវិតរបស់ពួកគេ ដែលពួកគេបានក្លាយទៅជាអ្នកបំរើព្រះ ។

អ្នកអាចចែកចាយជាមួយនឹងសិស្សរួមថ្នាក់តាមលក្ខណៈបួនសំនួរ ។ ឥឡូវកុំទាន់ឆ្លើយ អោយពួកគេដឹងទុកជាមុនថា ការរៀនវគ្គនេះនឹងឆ្លើយនូវសំនួរទាំងបួននេះ ។

- តើការផ្លាស់ប្តូរអ្វីខ្លះនឹងកើតមានឡើងក្នុងជីវិតរបស់ខ្ញុំ ?
- ហេតុអ្វីបានជាការផ្លាស់ប្តូរទាំងនេះកើតមានឡើង ?
- តើការផ្លាស់ប្តូរទាំងនេះផ្តល់អោយនៅភស្តុតាងយ៉ាងណាពេលដែលខ្ញុំជាគ្រីស្ទបរិស័ទ ?
- តើខ្ញុំអាចធ្វើការផ្លាស់ប្តូរទាំងនេះបានទេនៅក្នុងជីវិតរបស់ខ្ញុំ ?

## ៦, ករណីនៃការសិក្សាព្រះបន្ទូលរបស់លោកសាខេ "៥-១០នាទី"

សូមសិស្សអានរឿង **សាខេ** នៅក្នុង **លូកា** ១៩:១-១០ ។ មុននឹងអោយសិស្សម្នាក់អាន ខ គម្ពីរខាំង៧ឡើង ចូរប្រាប់ពួកគេអោយមើលថាតើ សាខេ បានផ្លាស់ប្តូរដោយរបៀបណាក្រោយពីគាត់បានក្លាយជាគ្រីស្ទបរិស័ទ ។

នេះជាសំនួរ ពិភាក្សាដែលអ្នកអាចប្រើក្រោយពីបានអានគម្ពីរមក ។

១. តើអ្នកមានចំណាប់អារម្មណ៍អ្វីពេលដែលយើងបានអានរឿងនេះ ?

២. អ្វីជាការផ្លាស់ប្ដូរពិតប្រាកដដែល សាខេ បានសន្យាថាធ្វើក្រោយពីគាត់បានក្លាយជាគ្រីស្ទបរិស័ទ ?

សូមបញ្ជាក់ថា យើងទាំងអស់គ្នាគ្មាននរណាម្នាក់មានស្ថានភាពដូចគ្នាទៅនឹងលោកសាខេទេ ។ ប៉ុន្តែព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចង់ឃើញយើងធ្វើការផ្លាស់ប្រែដែលនឹងផ្តល់នូវភស្តុតាងច្បាស់លាស់ទៅលើចំពោះខ្លួនយើង និង អ្នកដទៃទៀតថា យើងពិតជាបានក្លាយទៅជាគ្រីស្ទបរិស័ទយ៉ាងពិតប្រាកដមែន។

## ៧. ធ្វើបញ្ជីនៃការផ្លាស់ប្ដូរ (៥-១០នាទី)

សូមឱ្យសិស្សប្រគល់បញ្ជីនៃការផ្លាស់ប្ដូរ មកឱ្យអ្នកនៅអ្វីដែលបានកើតឡើង ០នៅក្នុងជីវិតពួកគេតាំងពីពួកគេ បានក្លាយទៅជាគ្រីស្ទបរិស័ទ ។សូមដាក់បញ្ជីនេះដោយបញ្ចាំងស្លាយ ឬលើក្តារខៀន ។ ឱ្យសិស្សប្រាប់ចំលើយរបស់ពួកគេ ពីគំរោង ទី ៣ សំនួរទី ៦ និងទី ៧ ហើយ និង គំរោង ទី ៦សំនួរ ទី ៨ ។ សូមកុំអោយពាក់ព័ន្ធទៅលើការពិភាក្សាគ្នា ដ៏វែងទៅលើគំនិតផ្តួចផ្តើមនិមួយៗ ។ ធ្វើបញ្ជីដូច្នេះសិស្សទាំងអស់នឹងចាប់ផ្តើមយល់ពីបញ្ហាដ៏មានសារៈសំខាន់ដែលយើងចង់ដោះស្រាយថ្ងៃនេះ ។

## ៨. តើខ្ញុំផ្លាស់ប្ដូរភ្លាមបានដោយរបៀបណា? (៥នាទី)

បញ្ហាមួយដែលអាចធ្វើឱ្យមានការប្រទាញប្រទង់គ្នា គឺថាតើមនុស្សម្នាក់ត្រូវធ្វើការផ្លាស់ប្ដូរឱ្យបានលឿនដោយរបៀបណា? ឧទាហរណ៍បើការរៀបរាប់នរណាម្នាក់អំពីការឈប់ជក់បារី ដើម្បីអោយមនុស្សនោះមានការផ្លាស់ប្ដូរ អ្នកអាចប្រើការពន្យល់ដោយបង្ហាញអំពីចំនុចនេះជាគំរូ ។

១. តើលោកអ្នកឈប់ជក់បារីមុនពេលអ្នកក្លាយជាគ្រីស្ទបរិស័ទទេ ?

២. តើអ្នកត្រូវតែឈប់ជក់បារីមុនរយៈពេលមួយថ្ងៃ ឬ ពីរថ្ងៃទេក្នុងការក្លាយខ្លួនជាគ្រីស្ទបរិស័ទ ?

៣. តើអ្នកបន្តការជក់បារីរយៈពេលជាច្រើនខែឬ ច្រើនឆ្នាំតទៅទៀតទេក្រោយពីអ្នកបានទៅជាគ្រីស្ទបរិស័ទហើយ ?

៤. តើព្រះជាម្ចាស់ត្រូវការអោយយើងកែប្រែក្នុងការប្រព្រឹត្តទៅលើចំនុចពិសេសៗណាខ្លះ ?

កុំមានអារម្មណ៍ថា ជាកាតព្វកិច្ចគំរូវអោយឆ្លើយបញ្ជាក់អោយបានច្បាស់លាស់ពីព្រះគម្ពីរទៅលើសំនួរទាំងនេះស្ដីពី បញ្ហាការជក់បារីនោះឡើយ ។បង្ហាញថា បញ្ហាដែលយើងចង់ធ្វើគឺជាបញ្ហាខាងក្រោមនេះ ។

១. តើព្រះជាម្ចាស់ជឿជាក់ថា នេះគឺជាការផ្លាស់ប្ដូរសំខាន់ទេ ដែលខ្ញុំគួរតែធ្វើ? ឬក៏ព្រះអង្គមានចំណាប់អារម្មណ៍ចង់អោយខ្ញុំដោះស្រាយជាមួយនឹងការកែប្រែផ្សេងៗទៀតជាមុនសិន ?

២. តើពេលណាព្រះជាម្ចាស់ចង់អោយខ្ញុំចាប់ផ្តើមធ្វើការកែប្រែនិស្ស័យនេះចេញពីជីវិតរបស់ខ្ញុំ ?

យើងត្រូវការស្វែងរកព្រះជាមុនសិន។ តើយើងធ្វើដូចនោះដោយរបៀបណា? យើងអាចអធិស្ឋាន អានព្រះគម្ពីរហើយរកទីប្រឹក្សាចាស់ទុំ គឺជាគ្រីស្ទបរិស័ទមានជំនឿយូរ។

វាហាក់ដូចជាមានរយៈពេលបីខុសគ្នាដើម្បីត្រិះរិះពិចារណានៅក្នុងការកែប្រែទាំងនេះ ។ ចំនុចនិមួយៗនឹងត្រូវបានពិភាក្សាយ៉ាងពិស្តារថែមទៀតដែលមានដូចខាងក្រោម។

១. ផ្លាស់ប្តូរមុន ឬក៏ នៅពេលទទួលការសង្គ្រោះ

២. ការផ្លាស់ប្តូរចាំបាច់ត្រូវតែកើតឡើងភ្លាមៗបន្ទាប់ពីមនុស្សម្នាក់ក្លាយខ្លួនជាគ្រីស្ទបរិស័ទ

៣. ការផ្លាស់ប្តូរនឹងកើតមាននៅពេលក្រោយក្នុងជីវិតរបស់គ្រីស្ទបរិស័ទ

## ៩. ផ្លាស់ប្តូរមុន ឬក៏ នៅពេលទទួលការសង្គ្រោះ (៣-៥នាទី)

ជួនកាលការកែប្រែជាផ្នែកមួយយ៉ាងចាំបាច់ដើម្បីអោយក្លាយជាគ្រីស្ទបរិស័ទ ។ លុះត្រាណាតែការផ្លាស់ប្តូរកើតឡើងនៅពេលទទួលការសង្គ្រោះ ឬក៏ មុនពេលទទួលការសង្គ្រោះ បើមិនអញ្ចឹងទេ មនុស្សនោះអាចសួរសំនួរយ៉ាងប្រាកដ ថាតើការសង្គ្រោះនៅពិតជាមែនឬមួយយ៉ាងណា ?

ខាងក្រោមនេះជាឧទាហរណ៍ ជាច្រើនដែលជាញឹកញាប់កើតមានមុន ឬ នៅនឹងពេលទទួលការសង្គ្រោះ ។

១. ការប្រោសមនុស្សខ្មោចចូលម្នាក់មកពី កាដារ៉ា ក្នុងគម្ពីរ **លូកា** ៨:២៦-៣៩

២. លោកប៉ូលបានឈប់ធ្វើទុក្ខទោសដល់ គ្រីស្ទបរិស័ទ **កិច្ចការ** ៩:១-២២

៣. មនុស្សម្នាក់ញៀនថ្នាំយ៉ាងខ្លាំង ។ ពួកគេមិនត្រូវបោះបង់ថ្នាំញៀនរបស់ពួកគេទេ ប៉ុន្តែបើពួកគេមានការញៀនថ្នាំខ្លាំងម្នាក់អាចសួរថាតើពួកគេដឹងពីអ្វីដែលពួកគេកំពុងធ្វើទេ? ពេលយើងពិភាក្សាអំពីការប្តេជ្ញាចិត្តខាងចិត្តគំនិតដើម្បី អោយគេក្លាយទៅជាគ្រីស្ទបរិស័ទ ខ្ញុំគិតថាការនោះអាចបានសង្គ្រោះដោយនិយាយថា មនុស្សនោះត្រូវតែមានចិត្តគំនិតច្បាស់លាស់មិនញៀនថ្នាំទៀត ។

៤. នៅពេលដែលមនុស្សម្នាក់ញៀនសុរ៉ា ហេតុផលដូចគ្នានឹងអនុវត្តនៅទីនេះដូចជាមនុស្សដែលញៀនថ្នាំដែរ ។ មានភាពខុសប្លែកគ្នាទៅលើកំរិតនៃការញៀនស្រា ដូច្នេះយើងមិនអាចជំនះចិត្តបានទេ ប៉ុន្តែចំនុចសំខាន់ៗនោះគឺកម្រមាន ណាស់ពីមុនមកនៅការសារភាពពីទង្វើរបៀបនេះ ។

បើអ្នកណាម្នាក់អធិស្ឋានដើម្បីអោយក្លាយជាគ្រីស្ទបរិស័ទនៅពេលដែលគាត់ញៀនថ្នាំឬញៀនស្រា អ្នកគួរតែមានផែនការ ដើម្បីពិភាក្សាអំពីបញ្ហាទាំងអស់នោះ ម្តងទៀតពេលមនុស្សនោះបាត់ស្រវឹង ។ ការញៀនថ្នាំនេះមិនទទួលបានដោយ ព្យាយាមបញ្ចុះបញ្ចូលដល់មនុស្សដោយវាយផង អធិស្ឋានដល់គាត់ផងបានទេ ។ នៅពេលដែលញៀនថ្នាំខ្លាំងនោះ លើកទឹកចិត្តដល់មនុស្សនោះម្តងហើយម្តងទៀតអោយពិចារណាទៅលើសេចក្តីត្រូវការនៃការសង្គ្រោះ ហើយបន្ទាប់មក អធិស្ឋានម្តងទៀត ដើម្បីបញ្ជាក់ឡើងវិញនូវអ្វីដែលពួកគេបានអធិស្ឋានជាច្រើនម៉ោង ឬប្រើរយៈពេលជា ច្រើនថ្ងៃនោះ ។

## ១០. ការផ្លាស់ប្តូរចាំបាច់ត្រូវតែកើតឡើងភ្លាមៗបន្ទាប់ពីមនុស្សម្នាក់ក្លាយខ្លួនជាគ្រីស្តបរិស័ទ (៣-៥នាទី)

មានបញ្ហានិង ទំលាប់ខ្លះៗដែលចាំបាច់ត្រូវតែផ្លាស់ប្តូរយ៉ាងឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន ក្រោយពីបានក្លាយជាគ្រីស្តបរិស័ទ ។ ការរងចាំកាន់តែយូរក្នុងការផ្លាស់ប្តូរ នោះគ្រោះថ្នាក់កាន់តែធំឡើងក្នុងការបំផ្លាញជីវិតថ្មីដែលគាត់មាននៅក្នុងព្រះគ្រីស្តកាន់តែឆាប់ ។ ការផ្លាស់ប្តូរទាំងនេះប្រហែលជាពិបាកធ្វើណាស់ ប៉ុន្តែនៅពេលគាត់ផ្លាស់ប្តូរកាន់តែឆាប់ នោះការរីកចំរើនខាងព្រលឹងវិញ្ញាណតែលឿន ។

ជាមួយនឹងបញ្ហាខ្លះៗមានចំនុចដែលបានមកពីព្រះបន្ទូលរបស់ព្រះថា បើអ្នកគ្មានបំណងលះបង់ជីវិតចាស់របស់អ្នកទេនោះ អ្នកនឹងនិយាយថា ព្រះយេស៊ូមិនមែនជាព្រះអង្គម្ចាស់នៅក្នុងជីវិតរបស់អ្នកទេ ។ បើសិនជាព្រះគ្រីស្តមិនបានធ្វើជាម្ចាស់ ជីវិតអ្នកទេ នោះទ្រង់ក៏មិនមែនជាម្ចាស់លើគ្រប់ទាំងអស់ដែរ ។ នេះជាឧទាហរណ៍ខ្លះៗ ។

១. ព្រះយេស៊ូប្រាប់អោយអ្នកមានម្នាក់លះបង់ប្រាក់របស់គាត់ទាំងអស់ហើយដើរតាមព្រះអង្គ ។ មើល ខគម្ពីរ **ម៉ាថាយ** ១៩:១៦-៣០

២. សាខេ សងគេវិញចំពោះការយកពន្ធលើសរបស់គាត់ ។ **លូកា** ១៩:១-១០

៣. មនុស្សញៀនថ្នាំ ឬ ស្រា

៤. មនុស្សពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់ រំលោភច្បាប់ប្រទេសរបស់ខ្លួនក៏ដូចជាការបំពានលើបទបញ្ជារបស់ព្រះអោយយើងគោរពអាជ្ញាធរស៊ីវិលផងដែរ ។

## ១១. ការផ្លាស់ប្តូរនឹងកើតមាននៅពេលក្រោយក្នុងជីវិតរបស់គ្រីស្តបរិស័ទ (៣-៥ នាទី)

មានការផ្លាស់ប្តូរខ្លះៗដែលព្រះមិនទាន់ចាប់ផ្តើមបើកសំដែងដល់មនុស្សរហូតដល់អស់រយៈពេលជាច្រើនខែ ឬ ច្រើនឆ្នាំ ក្រោយពីបានក្លាយជាគ្រីស្តបរិស័ទមក ។ ការបំរើព្រះយេស៊ូគ្រីស្តកាន់តែយូរនោះព្រះវិញ្ញាណបរិសុទ្ធកាន់តែបង្រៀនអ្នក បន្ថែមទៀត ។ ព្រះមានបំណងរង់ចាំយ៉ាងយូរមុនពេលទ្រង់ចាប់ផ្តើមត្រាស់ហៅអោយកែប្រែ ។ នេះជាឧទាហរណ៍ខ្លះៗ :

១.អត្តចរិករបស់លោកពេត្រុសនៃការប្រកាន់ពូជសាសន៍ឆ្ពោះទៅរកការមិនប្រកាន់ទៅវិញហើយបានចែកចាយដំណឹងល្អទៅវិញ ។ មើលគម្ពីរ **កិច្ចការ** ១០:១ ដល់ ១១:១៨

២. បញ្ហាខ្លះៗមិនមែនជាអំពើបាបទេ ប៉ុន្តែវាអាចនាំអ្នកអោយធ្លាក់ទឹកចិត្តហើយទាញអ្នកមិនអោយសប្បាយរីករាយនឹងអ្វីដែលព្រះចង់អោយអ្នក ។ បញ្ហាដូចជា ការព្រួយបារម្ភ, កំហឹង, ការចុះសំរុងគ្នាជាមួយសមាជិកគ្រួសារ, ឈប់អួត ។ នៅក្នុងករណីខ្លះព្រះជាម្ចាស់ចង់អោយអភិវឌ្ឍន៍នៅការផ្លាស់ប្តូរជីវិជ្ជមាននៅក្នុងជីវិតរស់នៅរបស់អ្នក ដូចជា មានចិត្តល្អចំពោះអ្នកដទៃ, អត់ធ្មត់, អត់ទោស និង មានចិត្តមេត្តាករុណា ។

ភាពខុសប្លែកគ្នារវាងផ្នែក ទីពីរ និងផ្នែក ទីបី គឺមិនដូចសំរាប់មនុស្សទាំងអស់គ្នាទេ។ ព្រះវិញ្ញាណបរិសុទ្ធអាចបង្ហាញ មនុស្សម្នាក់អោយកែប្រែយ៉ាងឆាប់រហ័ស ក៏ប៉ុន្តែមនុស្សម្នាក់ទៀតទ្រង់អោយរង់ចាំរយៈពេលជាច្រើនខែ ឬ ច្រើនឆ្នាំ ។ តាមពិតព្រះវិញ្ញាណបរិសុទ្ធប្រហែលមិនបង្ហាញមនុស្សនៃរឿងពិសេសៗទេ ។ វាមិនមែនជាកិច្ចការរបស់យើងដើម្បី ធ្វើកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធទេ ។ យើងត្រូវប្រុងប្រយ័ត្នដែលយើងមិនបង្ខំអោយសិស្សរបស់យើងមានជំនឿស៊ប់ ដោយផ្ទាល់ខ្លួនរបស់យើងទេ។

## ១២. បើខ្ញុំកែប្រែតើនៅតែខ្ញុំទៀតទេ (៥នាទី)

គ្រីស្ទបរិស័ទថ្មីខ្លះទៀតរឹងទទឹង មិនកែប្រែព្រោះពួកគេគិតថា អ្នកព្យាយាមបង្ខិតបង្ខំពួកគេអោយក្លាយទៅជានរណាម្នាក់ ដែលវាមិនអាចទៅរួចនោះ ។ ព្រះជាម្ចាស់មិនសុំអោយពួកគេធ្វើជាអ្នកក្លែងក្លាយ ឬ ក៏ ធ្វើពុតជានរណាម្នាក់ផ្សេងទៀតនោះទេ ។ ព្រះជាម្ចាស់មិនចង់អោយអ្នកជឿថ្មីគ្រប់ៗរូប ផ្លាស់ប្តូរហើយក្លាយដូចជា**ប៊ុលីក្រាហាំ** នោះទេ ។ ដូច្នេះ តើកន្លែងណាទុកជាសញ្ញាសំគាល់ខ្លួន ក្នុងដំណើរការនៃការកែប្រែខ្លួនទាំងនេះ?

ដុកទ័រ **ការីខូលីន** សរសេរយ៉ាងច្បាស់នៅក្នុងសៀវភៅរបស់គាត់ឈ្មោះថា របៀបក្លាយជាអ្នកជួយមនុស្ស នៅ ទំព័រ ទី ២០១-២០៤ ។ គាត់បង្ហាញ ពីរបៀបព្រះគ្រីស្ទដែលដឹកនាំនៅក្នុងជីវិតរបស់អ្នកទ្រង់បានធ្វើការក្នុងខ្លួនអ្នករួចទៅហើយដោយបញ្ជាក់អំពីផលផ្លែរបស់ទ្រង់ ក្នុងជីវិតរបស់អ្នក ។ ជួនកាលមនុស្សនឿយណាយអំពីសញ្ញាសំគាល់របស់ទ្រង់ដែលបិទបាំងទៅលើទំលាប់ធម្មតា ឬ សកម្មភាព ឧទាហរណ៍ការញៀនថ្នាំ ។ គាត់ប្រហែលជានិយាយទៅខ្លួនគាត់ថា " ខ្ញុំដឹងថាខ្ញុំញៀនថ្នាំ ។ បើខ្ញុំឈប់ប្រើថ្នាំញៀនតើនឹងសល់អ្វីនៅក្នុងជីវិតសំរាប់ខ្ញុំ? " សូមគូសបញ្ជាក់ថាព្រះចង់អោយអ្នកឃើញនៅការពិត ក្នុងខ្លួនរបស់អ្នក ។ ទ្រង់ចង់អោយអ្នកឈប់នូវភាពវង្វេងវង្វាន់ទៀត ហើយរៀនពីរបៀបក្លាយទៅជាមនុស្សស្មោះត្រង់។

## ១៣. តើនរណាអាចកែប្រែជីវិតបាន-ព្រះជាម្ចាស់ ឬ ខ្ញុំ ? (៥-១០នាទី)

បញ្ហាពិបាក៧ដទៃទៀតដើម្បីយល់តួនាទីដែលព្រះមាន និង ការទទួលខុសត្រូវអ្វីដែលខ្ញុំមាន នៅក្នុងការកែប្រែជីវិតរបស់ខ្ញុំ អ្នកអាចយកឧទាហរណ៍មួយ ឬ ពីរហើយពិភាក្សានូវអ្វីជាផ្នែកខាងព្រះអង្គ និង អ្វីជាផ្នែកខាងអ្នក សូមគូសបន្ទាត់នៅលើក្ដារខៀនដើម្បីជាពីរផ្នែកគឺមួយផ្នែកដាក់ សរសេរខាងផ្នែករបស់ព្រះ និងមួយផ្នែកទៀត សរសេរផ្នែករបស់អ្នក ។

ការល្បួងអោយធ្វើបាបគឺជាបញ្ហាសាមញ្ញអ្នកអាចប្រើក្នុងការពន្យល់នេះ ។ ស្រង់ចំលើយពីខគម្ពីរជាច្រើនដើម្បីដាក់ទៅ តាមផ្នែកនិមួយៗ។ គម្ពីរ **យ៉ាកុប** ៤:៧-៨ បានចែង នៅកិច្ចការជាច្រើនដែលអ្នកត្រូវធ្វើ និង កិច្ចការមួយដែលព្រះនឹងធ្វើ ។ **១ កូរិនថូស** ១០:១៣ ផ្តល់នៅគំនិតបន្ថែមទៀតចំពោះផ្នែកទាំងពីរនេះ ។

## ១៤. ការផ្លាស់ប្តូរជាមូលដ្ឋាន ៦ ចំនុចសំរាប់គ្រីស្ទបរិស័ទថ្មី (១០-២០នាទី)

នៅត្រង់ចំនុចនេះអ្នកមានបំណង ដើម្បីប្រព្រឹត្តទៅតាម ការផ្លាស់ប្តូរ ៦ យ៉ាងជាមូលដ្ឋានដែលបានសរសេរនៅ ទំព័រ ២១-២៦ ក្នុងសៀវភៅណែនាំរបស់សិស្ស។ ចូរពន្យល់ចំនុចនិមួយៗពីជីវិតផ្ទាល់របស់អ្នក ឬ មានសិស្សផ្តល់អោយ ឧទាហរណ៍និមួយៗ ។ ព្យាយាមពន្យល់ថាតើហេតុអ្វីបានជាការផ្លាស់ប្តូរទាំងនេះចាំបាច់ត្រូវតែកើតឡើងនៅក្នុងជីវិតគ្រីស្ទបរិស័ទ ។

បញ្ហាមួយដែលទាក់ទងអោយធ្វើបាប គួរតែត្រូវបានពិភាក្សាជាមួយនឹងការផ្លាស់ប្តូរទី ៤ ស្តីពី " អ្នកនឹងមានការសាកល្បង ការល្បួង និង បញ្ហាបន្ថែមទៀត " ។ ពន្យល់ការខុសប្លែកគ្នាអោយបានច្បាស់រវាងការប្រព្រឹត្តអំពើបាប និង ការរស់នៅក្នុងអំពើបាប ។ អត្ថបទខគម្ពីរ ពីរពិភាក្សាពីបញ្ហានេះ **១ យ៉ូហាន** ១:៩ និង ៣:៥-១០ ។ មនុស្សប្រព្រឹត្ត អំពើបាបដោយចេតនា ហើយមានអាកប្បកិរិយា " ខ្ញុំមិនខ្វល់ថាព្រះជាម្ចាស់មានព្រះបន្ទូលយ៉ាងម៉េចនោះទេ " គាត់នឹងមានបញ្ហាធំ ជាពិសេសបើគាត់បន្តអត្តចរិកនេះពីមួយខែទៅមួយខែនោះ ។ បញ្ហានេះវាខុសគ្នាឆ្ងាយណាស់ចំពោះមនុស្សដែលមានបាបនៅក្នុងសភាពទន់ខ្សោយ ដូចជា **លោកពេត្រុស**បានធ្វើនៅក្នុងយប់ដែលព្រះយេស៊ូត្រូវគេឆ្កាង ។ យើងនិយាយអំពីភាពខុសប្លែកគ្នារវាង បរាជ័យ និង មនុស្សដែលបន្តតាមទំលាប់អំពើបាប ហើយមិនយកចិត្តទុកដាក់ទៅលើការកែប្រែខ្លួន ។

## ១៥. ការសំដែងរឿង (៥-១០នាទី)

អ្នកអាចអោយសិស្សសំដែងរឿងការវិនិច្ឆ័យមួយនៅសាលក្រម ។ សូមអោយគ្រីស្ទបរិស័ទធ្វើជាអ្នកដែលត្រូវគេកាត់ទោស សូមអោយគាត់បង្ហាញជូននៅភស្តុតាងដែលឆ្លុះបញ្ចាំងថាគាត់ជាគ្រីស្ទបរិស័ទយ៉ាងច្បាស់លាស់ ។ អោយមេធាវីកំពុងកាត់ទោស ព្យាយាមបង្ហាញភស្តុតាងថាគាត់មិនមែនគ្រីស្ទបរិស័ទទេ ។ សូមសន្និដ្ឋានផ្នែកនៃមេរៀននេះដោយសួរ សិស្សទាំងអស់ថា បើអ្នកត្រូវបានគេបញ្ជូនទៅអោយតុលាការបានចោទប្រកាន់អំពី ការក្លាយខ្លួនជាគ្រីស្ទបរិស័ទតើអ្នកអាចមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញទេ ?

## ១៦. ពិភាក្សាដោយការវាយតំលៃនៅលើលទ្ធផលនៃ គំរោង ទី ៧ (៣-១០នាទី)

បើអ្នកមានពេល អ្នកអាចអោយសិស្សជាច្រើនរាយការណ៍នៅអ្វីដែលពួកគេបានរៀន នៅពេលគេបានបំពេញ គំរោង ទី ៧ *ស្តាប់ស្ទង់គ្រីស្ទបរិស័ទដទៃដើម្បីរកភស្តុតាង* ។

## ១៧. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥នាទី)

### ១. ផែនការសំរាប់ការផ្លាស់ប្តូរផ្ទាល់ខ្លួន

ក, បើសិស្សមិនទាន់បានធ្វើការផ្លាស់ប្តូរទេ សូមអោយពួកគេធ្វើបញ្ជីនៃចំនុចទាំងឡាយដែលពួកគេត្រូវការផ្លាស់ប្តូរ ។

ខ, ចូរអោយសិស្សអធិស្ឋានជ្រើសរើសចំនុចល្អបំផុតបីដែលពួកគេមានអារម្មណ៍ក្នុងការផ្លាស់ប្តូរដ៏មានសារៈសំខាន់បំផុតដើម្បីធ្វើការនេះជាលើកដំបូង ។ ដោយដាក់លេខចាប់ពី ១-៣ លេខ១គឺជាចំនុចដែលជាអទិភាពបំផុត ។ បន្ទាប់មកអោយសិស្សម្នាក់ៗសរសេរមួយ ឬ ពីរចំនុចដែលពួកគេនឹងធ្វើនៅសប្តាហ៍នេះដើម្បីធ្វើទៅតាមផ្នែករបស់ពួកគេដែលនាំមកនូវការផ្លាស់ប្តូរទៅលើចំនុចនេះដល់ជីវិតរបស់ពួកគេ ។ សង្កត់ធ្ងន់គឺអោយពួកគេស្វែងរកជំនួយមកពីព្រះជាម្ចាស់ក្នុងការធ្វើការផ្លាស់ប្តូរ ទាំងនេះ។ នេះជាសំនួរបន្ថែមខ្លះៗទៀត អ្នកអាចអោយពួកគេត្រិះរិះ និង សិក្សាបន្ថែមទៀត ។

. ហេតុអ្វីខ្ញុំត្រូវការផ្លាស់ប្តូរចំនុចនេះនៃជីវិតរបស់ខ្ញុំ ?
. តើព្រះមានព្រះបន្ទូលនៅក្នុងគម្ពីរដូចម្តេចអំពីបញ្ហានេះ ?
. តើខ្ញុំមានចំណែកអ្វីក្នុងការផ្លាស់ប្តូរនេះ ?
. តើព្រះបានសន្យាថាធ្វើអ្វីដើម្បីជួយខ្ញុំអោយមានការផ្លាស់ប្តូរនេះបាន ?
. តើការផ្លាស់ប្តូរនេះនឹងមានឥទ្ធិពលដល់ការរីកចំរើនខាងគ្រីស្ទបរិស័ទរបស់ខ្ញុំដោយរបៀបណា ?
. តើខ្ញុំគួរតែធ្វើយ៉ាងម៉េចដើម្បីការផ្លាស់ប្តូរនេះនៅជាប់រហូតនៃជីវិតរបស់ខ្ញុំបាន ?
. តើការផ្លាស់ប្តូរនេះនិងមានឥទ្ធិពលទៅលើការទំនាក់ទំនងជាមួយមិត្តភក្តិរបស់ខ្ញុំដូចម្តេច?
( ទាំងគ្រីស្ទបរិស័ទនិងមិនមែនគ្រីស្ទបរិស័ទ )

## ២. ចាកសំដែងអំពីឱកាសផ្សាយដំណឹងល្អ

អោយសិស្សម្នាក់ធ្វើជាអ្នកផ្សាយដំណឹងល្អទៅដល់មិត្តភក្តិដែលមិនមែនជាគ្រីស្តបរិស័ទ ។ មិត្តភក្តិនោះក៏សួរថាតើការផ្លាស់ប្តូរអ្វីបានកើតឡើងនៅក្នុងជីវិរបស់អ្នកចាប់តាំងពីអ្នកបានក្លាយជាគ្រីស្តបរិស័ទមក? សូមអោយសិស្សឆ្លើយតបទៅគាត់ ។

## ៣. តើត្រង់ចំនុចណាដែលពួកគេគួរតែចាប់ផ្តើមធ្វើការផ្លាស់ប្តូរ ?

បើសិស្សរបស់អ្នកមានការលំបាក ក្នុងការសំរេចចិត្ត ថាតើត្រូវចាប់ផ្តើមធ្វើការផ្លាស់ប្តូរនៅកន្លែងណានោះ ចូរលើកទឹកចិត្តពួកគេ ដោយព្យាយាមនៅគំរូនេះ ។

១. ចាប់ផ្តើមនៅស្ថានភាពក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកដែលនាំអោយអ្នកមានភាពស្មុកស្មាញ ភាពក្តៅក្រហាយ ជម្លោះ ។

២. បង្ហាញកន្លែងដែលអ្នកត្រូវការលូតលាស់ដែលត្រូវបានបង្ហាញអោយគេឃើញដោយស្ថានភាពតានតឹងទាំងនេះ ។

៣. ធ្វើបញ្ជីខគម្ពីរដែលប្រាប់អ្នក នៅកិច្ចការដែលអ្នកអាចធ្វើដើម្បីអោយលូតលាស់នៅក្នុងកន្លែងទាំងនេះនៅក្នុងជីវិតរបស់អ្នក ។

៤. បង្កើតគោលដៅមួយ ឬ ពីរដែលអ្នកអាចធ្វើបាន នៅក្នុងរយៈពេលពីរបីថ្ងៃខាងមុខ ដើម្បីលូតលាស់នៅកន្លែងទាំងនេះនៃជីវិតរបស់អ្នក ។

៥. បន្ទាប់ពីអ្នកបានធ្វើកិច្ចការតាមគោលគៅរបស់អ្នក ធ្វើការវាយតំលៃនៅលទ្ធផល ដើម្បីមើលឃើញថាថាតើវាបានជួយអ្នកដល់កំរិតណា ។ បន្ទាប់មកបង្កើតគោលដៅថ្មីមួយមួយទៀតសំរាប់ការរីកលូតលាស់បន្ថែម ។

## ១៨. កិច្ចការដែលត្រូវធ្វើ

១. នៅពេលបញ្ចប់រៀន សូមផ្តល់នៅសំនួរខ្លី អំពី " យ៉ូហាន១:១២ "

២. ដាក់ពិន្ទុគំរោង ទី ៤ ដែលស្តីពី "*ការបង្ហាញចំនុចទាំងបីនៃការប្តេជ្ញាចិត្តរបស់អ្នក*"

៣. ដាក់ពិន្ទុគំរោង ទី ៦ ដែលស្តីពី "*ការរកមើលភស្តុតាង*"

៤. ដាក់ពិន្ទុ គំរោង ទី ៧ ដែលស្តីពី "ស្តាប់ស្នងគ្រីស្តបរិស័ទដទៃទៀតដើម្បីរកភស្តុតាង "

អ្នកអាចដាក់កាលបរិច្ឆេទនៃការដាក់ពិន្ទុនេះនៅពេលក្រោយ បើសិស្សរបស់អ្នកមិនទាន់មានឱកាសដើម្បីទាក់ទងនឹងមនុស្សនោះនៅឡើយដែលពួកគេត្រូវការសំរាប់គំរោងនេះ ។

## ១៩. ការវាយតំលៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក ។

# មេរៀន ទី ៥

## ទំនាក់ទំនងផ្ទាល់ខ្លួនរបស់ខ្ញុំជាមួយនឹងព្រះយេស៊ូគ្រីស្ទ

### ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំចាំបាច់ត្រូវតែរកអោយឃើញ នៅផ្លូវដែលប្រកបទៅដោយអត្ថន័យក្នុងការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនយ៉ាងជិតស្និតជាមួយនឹងព្រះយេស៊ូ ។

### ២. ខគម្ពីរសំខាន់ ហេព្រើ ៤:១៦

ហេតុនេះយើងត្រូវចូលបល្ល័ង្ករបស់ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យប្រណីសន្តោសទាំងទុកចិត្ត ដើម្បីឱ្យព្រះអង្គ មេត្តាប្រណីសន្តោសយើង ព្រមទាំងជួយយើងពេលយើងត្រូវការ ។

### ៣. យោងតាមឯកសាររបស់សិស្ស

ទំព័រ ២៧-៣៦ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ស៊ីគ្នាជាមួយមេរៀននេះ ។ គំរោង ទី ៨ ដែលស្តីអំពី " *បង្កើតទំនាក់ទំនង ផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ* " ក៏ស៊ីគ្នាជាមួយនឹងមេរៀននេះដែរ ។

### ៤. ការរៀបចំសំរាប់គ្រូបង្រៀន

ដើម្បីជាជំនួយដល់អ្នក អ្នកអាចអានគំរោងផែនការមេរៀនឡើងវិញ សំរាប់ មេរៀនទី ៥ និង ទី ៦ ខណៈដែល អ្នករៀបចំបង្រៀនវគ្គសិក្សានេះ ។ ជំពូកទី៣នៃមេរៀននេះមិនងាយស្រួលនឹងបែងចែកជាពីផ្នែកសំរាប់វគ្គសិក្សា ជាពីរបានទេ។ យុទ្ធសាស្ត្រដែលយើងអោយយោបល់អំពី ការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូគ្រីស្ទគឺមាននៅក្នុងមេរៀនទី ៥ នេះ។ បន្ទាប់មកនៅក្នុងវគ្គសិក្សាក្រោយទៀតនឹងរៀនឡើងវិញនៅគំនិតដដែលម្តងទៀតតាមរយៈការប្រើការពន្យល់បង្ហាញខាងព្រះគម្ពីរ ជាពិសេសជីវិតព្រះគ្រីស្ទ ។ ចូរិះគិតឡើងវិញទៅតាមចិត្ត សំរាប់ផែនការមេរៀនទាំងពីរនេះ ប្រសិនបើអ្នករកឃើញវិធីល្អប្រសើរជាងនេះដើម្បីបង្រៀន ។

បើសិស្សមានការពិបាកទទួលយកនូវការយល់ដឹងបាន អ្នកអាចត្រិះរិះពិចារណាដោយចំណាយពេលបង្រៀនបីដងនៅជំពូក ទី៣នៃមុខវិជ្ជានេះ ។ អ្នកអាចបង្រៀនពីរដង ដើម្បីបង្ហាញបញ្ហាជាមូលដ្ឋាននៅក្នុងគំរោងមេរៀនទី ៥ ។ ក្នុងវគ្គសិក្សាទី បី អ្នកសរុបមេរៀនដោយបង្ហាញនៅក្នុងគំរោងមេរៀនទី៦ ។

## ៥. ការចាប់ផ្តើមមេរៀន " ចរិកលក្ខណៈនៃចំណងមិត្តភាពដ៏ល្អប្រសើរ " (៥-១០នាទី)

ពន្យល់សិស្សនៅថ្ងៃនេះថា យើងនឹងចាប់ផ្តើមការពិភាក្សារបស់យើង នៃរបៀបដើម្បីទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ ។ ប៉ុន្តែសំរាប់សកម្មភាពបើកចំហរបស់យើង ក៏យើងចង់មើលមកទំនាក់ទំនងដែលយើងមាន ជាមួយមនុស្សអ្នកដទៃ ទៀតដែរ ។

អោយសិស្សសរសេរចរិកលក្ខណៈទាំងដប់យ៉ាងនិងគុណភាពដែរពួកគេរកឃើញនៅ ក្នុងមិត្តភក្តិដ៏ជិតស្និតរបស់ពួកគេ ។ អោយពួកគេជ្រើសរើសចំនុចសំខាន់ៗបួន ហើយដាក់ចំនុចនិមួយៗតាមលំដាប់លេខរៀងនៃអទិភាព ។ បន្ទាប់ពីពួកគេបានបំពេញកិច្ចការរបស់ពួកគេរួចមក សូមឱ្យពួកគេអាននូវគុណភាពដែលពួកគេបានសរសេរ ។ សូមសរសេររឿងទាំងនេះនៅក្តារខៀន ក្រដាសសរ ឬនៅលើស្លាដ ។

ពិភាក្សាគ្នាដោយសង្ខេបទៅលើកការជ្រើសរើសចរិកលក្ខណៈជាអទិភាពរបស់ពួកគេ ។ ជាពិសេសបង្កើតនូវបរិយាកាសដែលពួកគេមានសេរីភាព ដើម្បីបញ្ជាក់ពីអទិភាពខុសប្លែកគ្នានូវដែលសិស្សដទៃទៀតបានជ្រើសរើស ។

## ៦. ពន្យល់អត្ថន័យ " ទំនាក់ទំនងផ្ទាល់ខ្លួន " (៣-៥នាទី)

ពិភាក្សាជាមួយគ្នាខ្លីៗ ថាតើមានអត្ថន័យយ៉ាងដូចម្តេច នៅពេលដែលយើង និយាយអំពី ការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូគ្រីស្ទ ។ ជាពិសេសយើងពិភាក្សាអំពីមិត្តភាពជាមួយព្រះយេស៊ូ ។ យើងត្រូវស្គាល់ទ្រង់ដោយផ្ទាល់ខ្លួន។ ថ្ងៃនេះយើងចង់ពិភាក្សាអំពីរបៀបដែលធ្វើកិច្ចការនេះ ។

បញ្ហាមួយក្នុងចំនោមបញ្ហាសំខាន់ៗ ដែលយើងប្រឈមមុខគឺថា តើអ្នកបង្កើតមិត្តភាពជាមួយមនុស្សដែលអ្នកមើលមិនឃើញដោយរបៀបណា? លើសពីនេះទៅទៀត ទ្រង់មិននិយាយខ្លាំងៗដល់អ្នកនោះទេ ហើយអ្នកថែមទាំងមិនអាចប៉ះពាល់ទ្រង់បានទៀតផង ។ សូមអ្នកបង្ហាញចំនុចនេះឱ្យបានច្បាស់លាស់ថា ព្រះអង្គអាចត្រូវបានគេស្គាល់ និង ទ្រង់ចង់បង្កើតទំនាក់ទំនងជាមួយនឹងសិស្សរបស់អ្នកម្នាក់ៗ ។

## ៧. ហេតុអ្វីត្រូវពង្រីងនូវទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូ? (៥-១០នាទី)

យើងត្រូវការឆ្លើយទៅនឹងសំនួរពីរទៀតមុនពេលយើងអាចឆ្លើយសំនួរនេះដែលថា " ហេតុអ្វីបានជាខ្ញុំត្រូវសង់នូវទំនាក់ ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ? " នេះជាសំនួរពីរ :

- តើអ្នកជឿថាព្រះជាម្ចាស់មានព្រះជន្មគង់នៅឬទេ?
- តើអ្នកជឿថាព្រះយេស៊ូគ្រីស្ទជាព្រះពិតទេ?

បើសិស្សរបស់អ្នកខ្លះទៀតនៅតែមានសំនួរ អំពីបញ្ហាទាំងពីរនេះ នោះត្រូវបញ្ជាក់អោយបានច្បាស់លាស់ដល់ពួកគេ មុនពេលដែលអ្នកបន្តនូវបញ្ហាខាងមុខទៀត ។ សូមឱ្យសិស្សអានហេប្រឺ១១ : ៦ ដែលមានរួមជាមួយសំនួរទីមួយ ។ ពិភាក្សាផងដែរនៃខគម្ពីរខ្លះៗដែលនិយាយអំពីព្រះយេស៊ូគឺជាព្រះពិត ។

បន្ទាប់មកទើបដោះស្រាយទៅនឹងសំនួរពីរដែលបានពិភាក្សានៅទំព័រទ២៧-២៨នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។ ចំលើយនៅលើសំនួរទាំងពីរនេះ បង្ហាញយ៉ាងច្បាស់លាស់ថាតើហេតុអ្វីបានជាយើងត្រូវបង្កើតទំនាក់ទំនងផ្ទាល់ជាមួយព្រះយេស៊ូ ។

១. ហេតុអ្វីបានជាព្រះជាម្ចាស់បង្កើតអ្នក?

២. តើអ្វីដែលនាំមកនូវការបំពេញដ៏ពិតប្រាកដនៅក្នុងជីវិត?

ការដកស្រងរបស់លោក **ផាកឃើ** អំពីការស្គាល់ព្រះនៅទំព័រទី២៨នៃសៀវភៅណែនាំរបស់សិស្សគួសបញ្ជាក់ពីអទិភាព ដែលយើងត្រូវមានក្នុងការស្គាល់ព្រះផ្ទាល់ខ្លួន ។ អ្នកគួរតែមើលទៅលើគម្ពីរសាស្តាបាននិយាយ អំពីការរកឃើញនូវអត្ថន័យពិតនៅក្នុងជីវិត ។ នៅខគម្ពីរពីរបីចុងក្រោយនេះដកស្រង់នូវអ្វីដែលមានសារៈសំខាន់យ៉ាងពិតៗ ក្នុងជីវិត ដើម្បីឱ្យ មានសេចក្តីគោរពដល់ព្រះនិងការស្តាប់បង្គាប់ព្រះ ។ វាផ្ទុយទៅនឹងសេចក្តីពិតនៃព្រះគម្ពីរ ដែលសាររបស់ពិភពលោកបានផ្តល់ឱ្យនូវអ្វីដែលនាំមកនូវអត្ថន័យដល់ជីវិតម្នាក់ៗ ។

## ៨. កុំរកមើលបទពិសោធន៍អាថ៌កំបាំងជាមួយព្រះយេស៊ូ (៣-៥នាទី)

នេះគឺជាចំនុចទីមួយដែលបានលើកឡើងនៅក្នុងសៀវភៅណែនាំរបស់សិស្សនៅទំព័រទី២៩ ដែលទាក់ទងជាមួយនឹងប្រធានបទថាតើប្រភេទអ្វីនៃទំនាក់ទំនងដែលអ្នកអាចបង្កើតជាមួយព្រះយេស៊ូ ។ បើសិស្សរបស់អ្នកខ្លះមកពីប្រវត្តិដែលប្រើមន្តអាគមន៍ ។ ពួកគេប្រហែលជាមានបទពិសោធន៍ឃើញវិញ្ញាណ ។ កុំស្វែងរកបទពិសោធន៍របៀបនេះក្នុងការស្វែងរកព្រះយេស៊ូ ។

យើងអាចមានចំណងមិត្តភាពដ៏ពិតជាមួយព្រះយេស៊ូបាន ។ សូមពិភាក្សាពីសារៈសំខាន់នៃព្រះគម្ពីរយ៉ូហាន ៦:៤៤ ដែលព្រះយេស៊ូមាន បន្ទូល " គ្មាននរណាម្នាក់អាចមកកាន់ខ្ញុំ(យេស៊ូ)បានឡើយដរាបណាបើព្រះបិតាមិនបានបញ្ជូនគេមក " ។

## ៩. តើខ្ញុំត្រូវតែបញ្ឈប់ជាខ្លួនខ្ញុំឬទេ? (៣-៥នាទី)

គ្រីស្ទបរិស័ទថ្មីខ្លះមានការតូចចិត្តខ្លួនឯងខ្លាំងណាស់។ នៅពេលដែលអ្នកសួរគេអោយមានការផ្លាស់ប្តូរហើយលះបង់នូវ សកម្មភាពចាស់ដែលជាប់ដោយអំពើបាបនោះចេញ នោះពួកគេនឹងគិតថាអ្នកកំពុងតែប្រាប់ឱ្យពួកគេលះបង់ចោលនូវ អត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេ ។ ពួកគេនិយាយថា " ប្រសិនបើខ្ញុំលះបង់ការនោះ វាមិនមែនជាខ្ញុំទេ ។ នោះគឺជាការយល់ខុសអំពីការពិត ។

សូមប្រៀបធៀបការនេះជាមួយនឹងមិត្តភាពជិតស្និទ្ធជាមួយនឹងមនុស្សដទៃទៀត ។

នៅពេលដែលមនុស្សពីរនាក់ក្លាយជាមិត្តសំលាញ់នឹងគ្នា ពួកគេនៅតែរក្សានៅអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេ ។ ពិតណាស់ គេចេះថ្លឹងថ្លែងទៅលើការប្រព្រឹត្តរបស់ពួកគេ ដូច្នេះពួកគេមិនធ្វើឱ្យទាស់ចិត្តគ្នាទេ ។ ប៉ុន្តែគេធ្វើដូច្នេះព្រោះគេស្រលាញ់មិត្តរបស់គេ មិនមែនដោយគេបង្ខំអោយធ្វើទេដូច្នោះនោះទេ ។ សូមមើលទំព័រទី ២៧ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីពត៌មានបន្ថែមទៀតទៅលើបញ្ហានេះ ។

## ១០. ព្រះជាម្ចាស់ចង់បានមិត្តភាពពិសេសមួយជាមួយអ្នកមិនមែនមិត្តភាពស្មើគ្នានោះទេ (៥-១៥)

តើយើងអាចមានចំណងមិត្តភាពប្រភេទណាជាមួយព្រះយេស៊ូ? ចង្អុលបង្ហាញថា ព្រះជាម្ចាស់មិនបានបង្កើតទ្រង់ទ្រាយធំនៅមិត្តភាពរបស់ទ្រង់ជាមួយនឹងមនុស្សទេ ។ ព្រះអង្គចាត់ទុកមនុស្សម្នាក់ៗពិសេស ហើយទ្រង់ផ្តល់អោយមនុស្សម្នាក់ៗមានការចាប់អារម្មណ៏ដោយផ្ទាល់ខ្លួនគេ ។ ទោះជាយ៉ាងណាក៏ដោយ ចំណងមិត្តភាពរបស់មនុស្សជាមួយព្រះជាម្ចាស់នេះមិនធ្វើអោយមនុស្សស្មើនឹងព្រះអង្គទេ ។ យើងក៏មិនអាចទាមទារការនេះពីទ្រង់បានដែរ ប៉ុន្តែទ្រង់អាចធ្វើតាមសេចក្តីត្រូវការសំរាប់អ្នកហើយនឹងខ្ញុំបាន ។

ចូរប្រើតារាងនៅចុងបញ្ចប់គំរោងមេរៀននេះ ដើម្បីពន្យល់ពីកំរិតទាំងបីនៃការទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូ ។

១. ព្រះយេស៊ូជាព្រះអង្គសង្គ្រោះ ទ្រង់អត់ទោសអំពើបាបរបស់អ្នក ។
២. ព្រះយេស៊ូជាអ្នកដឹកនាំរបស់អ្នក ទ្រង់ត្រូវតែគ្រប់គ្រងលើជីវិតរបស់អ្នក ។
៣. ព្រះយេស៊ូចង់ធ្វើជាមិត្តសំលាញ់របស់អ្នក ទ្រង់ចង់មានចំណងមិត្តភាពដោយសេចក្តីស្រលាញ់ ។

យើងមិនអាចរំលងកំរិតទីពីរនៃការមានទំនាក់ទំនងនេះបានឡើយ ។ យើងមិនអាចធ្វើជាមិត្តជាមួយនឹងព្រះយេស៊ូ ហើយបោះបង់ចោលវិន័យរបស់ទ្រង់ និង តំណែងរបស់ទ្រង់នៃអំណាចនៅក្នុងជីវិតរបស់យើងបានទេ ។ ដូចគ្នានេះដែរ បើអ្នកជាមិត្តភក្តិនឹងនាយប៉ូលីស នោះអ្នកមិនមានសេរីភាពធ្វើខុសច្បាប់តាមតែអ្នកចង់ធ្វើនោះទេ ។

មិត្តភាពរបស់យើងជាមួយព្រះយេស៊ូអាចពិតប្រាកដ និង ជិតស្និទ្ធ ។ ព្រះយេស៊ូនឹងមិនប្រើអំណាចរបស់ទ្រង់ ជាអំណាចអាជ្ញាសឹក(ដូចមនុស្សខ្លះប្រើនោះទេ)និង និយាយថា " ខ្ញុំមិនអាចចូលទៅជិតមនុស្សនោះទេ ពីព្រោះខ្ញុំនៅក្នុងឋានៈដែលខ្ពស់ជាងគាត់ ។ "

ចូរពិភាក្សាទៅលើរូបភាពខ្លះៗដែលព្រះយេស៊ូធ្លាប់ពិពណ៌នាអំពីទំនាក់ទំនងបែបនេះ ។ ទំនាក់ទំនងរវាងឪពុកនិងកូនគឺជា រូបភាពដ៏សាមញ្ញបំផុតដែលបានប្រើយ៉ាងច្រើននៅក្នុងព្រះគម្ពីរ ។ ព្រះយេស៊ូបានបង្ហាញផងដែរពីទំនាក់ទំនងអ្នកគង្វាល និង ចៀមរបស់គាត់ ។ ក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី ក៏មានការប្រៀបធៀបផងដែរនូវទំនាក់ទំនងរបស់យើង ជាមួយព្រះគ្រីស្ទ គឺ ដូចជាកូនកំលោះនិងកូនក្រមុំ ។ អ្នកអាចពិពណ៌នាការពន្យល់នេះជាសង្ខេប នៅត្រង់ចំនុចនេះ រួចហើយពិភាក្សាជាពិស្តារ ថែមទៀតនៅមេរៀនខាងមុខទៀត។

សូមមើលទំព័រ ទី ៣៣ នៃសៀវភៅណែនាំរបស់សិស្សដើម្បីជាពតិមានថែមទៀតលើចំនុចនេះ ។

## ១១. រៀនអំពីព្រះជាម្ចាស់ក្នុងព្រះគម្ពីរ (៥-១០នាទី)

ការរៀនអំពីព្រះជាម្ចាស់គឺជាជំហានដំបូង ដែលមនុស្សត្រូវតែបង្កើតទំនាក់ទំនង ជាមួយព្រះយេស៊ូ។ អោយសិស្សមើល ឡើងវិញនៅសំនួរទី ២ នៃគំរោង ទី ៨ ដែលឱ្យពួកគេដាក់ពិន្ទុ ពី ១-១០តាមក៏រិតដែលគេស្គាល់ព្រះយេស៊ូ ។ បើសិស្សរបស់អ្នកមិនមានបញ្ហាក្នុងការធ្វើកិច្ចការនេះទេ សូមអោយពួកគេអានការដាក់ពិន្ទុរបស់ពួកគេអោយខ្លាំងៗ ។ម្យ៉ាងទៀតវិញអ្នក អាចដើរនៅក្នុងថ្នាក់អានយ៉ាងស្ងៀមស្ងាត់ ទៅលើពិន្ទុរបស់សិស្សនិមួយៗ ។ ការនេះនឹងផ្តល់ឱ្យនូវគំនិតខ្លះៗដល់អ្នកអំពីរបៀបពួកគេយល់ដឹងទាំងអស់នៃចំណោះដឹងរបស់ពួកគេអំពីព្រះជាម្ចាស់ ។នៅទំព័រ ទី ៣០-៣១ នៅក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងផ្នែកនៃមេរៀននេះ។

បើអ្នកខ្លះនៅក្នុងថ្នាក់របស់អ្នកមិនមែនជាគ្រីស្ទបរិសទ័ សូមលើកទឹកចិត្តពួកគេដើម្បីឱ្យសិក្សាអំពីជីវិតរបស់ព្រះគ្រីស្ទ កុំប្រញាប់ឱ្យពួកគេធ្វើការសំរេចចិត្តទទួលព្រះគ្រីស្ទ រហូតដល់ពួកគេដឹងថាព្រះយេស៊ូជានរណាសិន ។ ប្រសិនបើព្រះគ្រីស្ទនឹងធ្វើជាអ្នកដឹកនាំគ្រប់កន្លែងទាំងអស់នៃជីវិតរបស់អ្នកចាប់ពីពេលនេះរហូតដល់ថ្ងៃដែលពួកគេស្លាប់ មិនត្រូវបង្ខំគេឱ្យមានការសំរេចចិត្តដោយប្រញាប់ប្រញាល់ ឬក៏ ការប្តេជ្ញាចិត្តដែលរាក់កំផែលនោះទេ ។ ពួកគេរៀនអំពីព្រះយេស៊ូកាន់តែច្រើន ពួកគេនឹងកាន់តែអាចមើលឃើញថាទ្រង់គឺជាជំរើសដ៏ត្រឹមត្រូវសំរាប់ជីវិតរបស់ពួកគេ ។

ប្រើគម្ពីរយ៉ូហាន ១៤:៩-១១ចង្អុលបង្ហាញប្រាប់ពីព្រះត្រៃឯក គឺព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធគឺ មិនខុសគ្នានោះទេ ជាអង្គទ្រង់តែមួយ ។ ព្រះបីអង្គមានលក្ខណៈដូចគ្នា ។ ព្រះយេស៊ូមានបន្ទូលថា : " បើអ្នកចង់ដឹង ថាតើព្រះបិតាមានអារម្មណ៍យ៉ាងណាអំពីបញ្ហានៅក្នុងជីវិតសូមមើលពីរបៀបដែលខ្ញុំមានអារម្មណ៍ ទៅលើបញ្ហា គឺព្រះបិតាខ្ញុំ មានអារម្មណ៍ដូចគ្នា " ។

## ១២. សូមកុំសន្មត់ថាព្រះជាម្ចាស់គិតដូចអ្នកគិតនោះឡើយ (៣-៥នាទី)

សូមប្រើគម្ពីរ អេសាយ៥៥:៨-៩ ដើម្បីនាំឱ្យគេឃើញពីសារៈសំខាន់អំពីព្រះជាម្ចាស់ ។ មាគ៌ារបស់ទ្រង់ហើយនិងគំនិតរបស់ទ្រង់ខ្ពង់ជាងយើងឆ្ងាយណាស់ ដូច្នេះយើងមិនគួរព្យាយាមប៉ាន់ប្រមាណ គំនិតរបស់ព្រះទេ នៅពេលដែលទ្រង់នៅស្ងៀមស្ងាត់ចំពោះបញ្ហារបស់យើង ។ ព្រះជាម្ចាស់ដឹង ប៉ុន្តែយើងមិនដឹងអ្វីទាំងអស់ ដែលទ្រង់ដឹងបានឡើយ ។

នេះជាពេលដ៏ល្អដើម្បីចង្អុលបង្ហាញថាជីវិត មានសំនួរជាច្រើនដែលគ្មានចំលើយ ។ អ្នកមិនអាចរងចាំរហូតដល់អ្នកមានចំលើយទៅលើសំនួរទាំងនេះ មុនអ្នកធ្វើការប្តេជ្ញាចិត្តចំពោះព្រះគ្រីស្ទ និង ក្លាយទៅជាគ្រីស្ទបរិសទ័នោះទេ ។ បញ្ហាខ្លះៗ ក្នុងបញ្ហាទាំងនេះនឹងត្រូវ " ដាក់នៅលើធ្នើរ " រហូតដល់ពេលក្រោយ ធ្វើដូច្នេះអ្នកអាចស្វែងរកកិច្ចការសំខាន់ៗជាងនៅក្នុងជីវិតគឺរៀនសេចក្តីស្រលាញ់ និងគោរពព្រះ ។

នេះជាពេលដ៏ល្អដើម្បីអោយសិស្សប្រុងប្រយ័ត្ន អំពីការប្រើព្រះធ្វើជាប្រភពពត៌មានរបស់ពួកគេ ។ " ព្រះជាម្ចាស់បានប្រាប់ខ្ញុំថា ... " ប្រហែលជាព្រះបានប្រាប់មនុស្សនោះនៅកិច្ចការអ្វីមួយ ប៉ុន្តែការនេះមិនមែនតែងតែជាករណីពិសេសនោះទេ ។ ព្រះគម្ពីរត្រូវតែជាឧបករណ៍វាស់វែងរបស់យើង ដើម្បីអោយមើលរឿងដែល យើងបានឮ ថាតើជា " ព្រះបន្ទូលមកពីព្រះ " ឬក៏មកពីមនុស្ស ។

## ១៣. ការស្គាល់អំពីព្រះជាម្ចាស់ ឬក៏ ការស្គាល់ព្រះជាម្ចាស់ដោយផ្ទាល់ខ្លួន (៥-១០នាទី)

អ្នកនឹងចំណាយពេល ជាច្រើនទៅលើបញ្ហានេះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំគិតថាយើងគួរតែមើលទៅឯកសារមួយទៀត ដែលនិយាយអំពីការបង្កើតទំនាក់ទំនង អោយជិតស្និតជាមួយនឹងព្រះយេស៊ូ ។ សូមមើលទំព័រទី ៣១-៣២ នៅក្នុង សៀវភៅណែនាំរបស់សិស្សដើម្បីជាពត៌មានបន្ថែមទៅលើបញ្ហានេះ ។

អោយសិស្សចែកចាយចំលើយរបស់ពួកគេ ទៅលើសំនួរ ទី ៣នៃគំរោង ទី ៨ ។ សំនួរនោះសួរឱ្យពួកគេពន្យល់ពីរបៀបមនុស្សម្នាក់អាចស្គាល់ព្រះជាម្ចាស់បានប្រសើរដោយផ្អែកទៅលើអ្វីដែល គម្ពីរ កូឡូស ១:៩-១០ បានចែង ។ អ្នកអាចប្រើកិច្ចការនេះដើម្បីពន្យល់បង្ហាញបញ្ហាខ្លះដែលដែលពួក ផារ៉ាស៊ីមាននៅជំនាន់ព្រះយេស៊ូ ។ ពួកគេបានដឹងយ៉ាងច្រើននៅអ្វីដែលព្រះគម្ពីរបានចារទុក ប៉ុន្តែពួកគេមិនមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូទេ ។ អត្ថបទនៅក្នុងព្រះគម្ពីរម៉ាថាយ ៧:២១-២៣ ក៏ស៊ីគ្នានឹងដំណើររឿងនេះដែរ ។

សិស្សរបស់អ្នកមានការសិក្សាសមល្មម នឹងយល់ពាក្យប្លែកៗ ដែលបានប្រើនៅក្នុងភាសាក្រិកពាក្យ " ដឹង " ។ នៅក្នុងភាសា អង់គ្លេសយើងមានពាក្យតែមួយមាត់ ប៉ុន្តែនៅក្នុងភាសាក្រិកនៃសម័យព្រះយេស៊ូមានពីរ ។ ភាសាក្រិក " Oida " យោងទៅលើចំណេះដឹងពិតប្រាកដ - នោះគឺជាការយល់ដឹងអំពីអ្វីមួយ ។ ភាសាក្រិចមួយទៀតគឺ " inosko " ដែលជាញឹកញាប់លើកឡើងពីអាថិកំបាំង នៃ ការដឹងពីបទពិសោធន៍ផ្ទាល់ខ្លួន ។

ចូរលើទឹកចិត្តសិស្សរបស់អ្នកឱ្យសិក្សាពាក្យដែលមានចែងនៅក្នុងអត្ថបទគម្ពីរដែលទាក់ទង ។

## ១៤. ការណែនាំអោយស្គាល់ជំហានមូលដ្ឋានដើម្បីបង្កើតនូវទំនាក់ទំនងផ្ទាល់ជាមួយនឹងព្រះយេស៊ូ (៣_៥នាទី)

ដោយយោងទៅតាមពេលវេលាដែលអ្នកបានសិក្សាជាច្រើនរួចមកហើយ អ្នកនឹងត្រូវការប៉ាន់ប្រមាណថាតើរយៈពេល ប៉ុន្មានដែលអ្នកទុក ដើម្បីស្រាវជ្រាវនៅផ្នែកនេះ ហើយនិងការអនុវត្តន៍សកម្មភាពផ្ទាល់សំរាប់មេរៀននៅថ្ងៃនេះ។ បើសិន ជាអ្នកអាចសង្ខេបត្រួសៗទៅលើចំនុចទាំងនេះ ហើយពន្យល់នៅលើរឿងនោះ ដែលយើងនឹងសរុបបញ្ហាទាំងនេះក្នុងការ រៀបរាប់បន្ថែមនៅវគ្គសិក្សាពេលក្រោយ។

ការណែនាំនៅទំព័រទី ៣៣ នៃសៀវភៅណែនាំរបស់សិស្ស មានជាច្រើនចំនុចដែលអ្នកអាចពិភាក្សាជាសង្ខេប ។ លើកទឹកចិត្តពួកគេដើម្បីឱ្យឃើញគោលបំណងដ៏ពិតប្រាកដ ទោះបីជាក្មេងក៏អាចបង្កើតនូវមិត្តភាពជាមួយនឹងព្រះយេស៊ូផ្ទាល់បានដែរ ។ យើងមិនដែលឃើញព្រះយេស៊ូទេ ប៉ុន្តែយើងអាចនិយាយបានថា : " ព្រះយេស៊ូជាមិត្តដ៏ល្អរបស់ខ្ញុំ " ។

ខណៈដែលអ្នកពិភាក្សាតាមលំដាប់និមួយៗនៅជំហានទាំងបួន ដើម្បីបង្កើតទំនាក់ទំនងផ្ទាល់ជាមួយព្រះយេស៊ូ អ្នកអាចរកឃើញជំនួយដើម្បីពន្យល់តាមពេលវេលានិមួយៗនៃមិត្តភាពដែលមនុស្សពីរនាក់មាន ។ គោលការណ៍ស្ទើរតែទាំងអស់នេះ អាចយកទៅអនុវត្តនៅក្នុងចំណងមិត្តភាពប្រភេទណាក៏បានដែលអ្នកចង់បង្កើត ។

## ១៥. មនុស្សទាំងពីរត្រូវតែចង់បានចំណងមិត្តភាពបែបនេះ (៣-៥នាទី)

សូមចង្អុលបង្ហាញអោយបានច្បាស់លាស់ថា ព្រះជាម្ចាស់មិនរារែកនៅក្នុងគោលបំណងរបស់ទ្រង់ ដើម្បីភ្ជាប់ចំណងមិត្តភាព ជាមួយនឹងមនុស្សម្នាក់ៗនៅក្នុងថ្នាក់នេះទេ ។ ព្រះអង្គចង់ភ្ជាប់ចំណងមិត្តភាព ជាមួយអ្នកទោះជាអ្នកស្ថិតនៅក្នុងអំពើបាបក៏ដោយ ។ ព្រះអង្គបានប្រើវិធីជាច្រើនដើម្បីបង្ហាញពីសេចក្តីស្រលាញ់របស់ទ្រង់ ។ តែសំនួរពិតប្រាកដគឺថា " តើខ្ញុំចង់បង្កើតមិត្តភាពជិតស្និទ្ធជាមួយព្រះជាម្ចាស់ប៉ុណ្ណា? "

ម៉ាថាយ ៧:៧-១១ គឺជាអត្ថបទគម្ពីរដ៏ល្អដើម្បីពិភាក្សានៅទីនេះ។ សូមចង្អុលបង្ហាញ ពីរបៀបជំហាននេះជាប់ទាក់ទងទៅនឹងការដំបូងដែលយើងបានពិភាក្សានៅក្នុងមុខវិជ្ជានេះ ដែលស្តីអំពីការថ្វាយជីវិតរបស់យើងដល់ព្រះយេស៊ូ ។ សូមមើល ទំព័រ ទី ៣៣ នៅក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ជាពត៌មានបន្ថែមនៅលើចំនុចនេះ ។

## ១៦. រៀនទាក់ទងជាមួយនឹងព្រះយេស៊ូ (៥-១០នាទី)

រៀនពីរបៀបការទាក់ទងដោយបង្កើនចិត្តគំនិតនូវការទាក់ទងផ្ទាល់ជាមួយនឹងព្រះយេស៊ូ ។សូមមើល ទំព័រ ទី ៣៤ ក្នុងសៀវភៅណែនាំរបស់សិស្សសំរាប់ពត៌មានបន្ថែមទៀតនៅលើចំនុចនេះ ។ ចង្អុលបង្ហាញទៅលើតំរូវការបង្កើតពេលវេលាអធិស្ឋានដ៏មានតំលៃរាល់ថ្ងៃ ។ ប្រសិនបើសិស្សរបស់អ្នកជាគ្រីស្ទបរិស័ទថ្មីអ្នកអាចចំណាយពេលខ្លះៗនិយាយអំពីមូលដ្ឋាននៃការអធិស្ឋាន ។ បញ្ហាការអធិស្ឋាននេះត្រូវបានពិភាក្សាយ៉ាងពិស្តារបន្ថែមទៀត នៅក្នុងមុខវិជ្ជាការសិក្សាជាក្រុមសំរាប់គ្រីស្ទបរិស័ទថ្មី គឺ ការប្រណិបត៌របស់គ្រីស្ទបរិស័ទ ។

អោយសិស្សចែកចាយចំលើយរបស់ពួកគេលើសំនួរទី៤ទៅ ទី៥នៅគំរោង ទី ៨ ។ សំនួរទី៤មានការវាយតំលៃទៅលើពេលវេលាខ្លះៗ នៅពេលដែលពួកគេមានអារម្មណ៏នៅជាប់នឹងព្រះ ។ សំនួរទី ៥ នាំឱ្យពួកគេកំណត់ ថាតើពួកគេមានអារម្មណ៏យ៉ាងដូចម្តេចអំពីវេលាអធិស្ឋានរបស់ពួកគេ ។ បើមានអ្នកមានពេលវេលាខ្លី អ្នកអាចពិភាក្សានូវសំនួរ ទី ៥ត្រង់ចំនុចនេះ ហើយទុកការពិភាក្សារបស់អ្នកចំពោះសំនួរ ទី ៤នៅវគ្គសិក្សាពេលក្រោយ ។

បញ្ជាក់ពីតំរូវការទៅលើទំនាក់ទំនងជាមួយព្រះជាម្ចាស់ នៅក្នុងផ្លូវមួយដែលបើកចំហរ និង ស្មោះត្រង់ ។ លើកទឹកចិត្តដល់ពួកគេដើម្បី និយាយទៅកាន់ព្រះអង្គអំពីព្រឹត្តិការណ៏ដែលខុសៗគ្នាដែលប្រព្រឹត្តិទៅជារៀងរាល់ថ្ងៃរបស់ពួកគេ ។ពួកគេមិនចាំបាច់ពូ " សំលេងពីឋានសួគ៌ទេ "មុនពួកគេធ្វើអ្វីៗនៅថ្ងៃនេះ។ ប៉ុន្តែពួកគេចាំបាច់ត្រូវតែរៀនទំលាប់ដែលយកព្រះអង្គមកនៅក្នុងគំនិតរបស់ពួកគេជាប្រចាំពេញមួយថ្ងៃ ។

ប្រស្នាអំពីពួកផារ៉ាស៊ី និង មនុស្សសាមញ្ញអធិស្ឋានបង្ហាញនូវ ភាពខុសគ្នារវាងការនិយាយក្នុងការអធិស្ឋានដោយគិតតែប្រយោជន៍ខ្លួន និង ការនិយាយបើកចំហរដោយសេចក្តីពិត ចំពោះព្រះជាម្ចាស់ ។ សូមមើលលូកា ១៨:៩-១៤ ។

## ១៧. រៀនបង្កើតការទុកចិត្ត និង ភាពស្មោះត្រង់ (៥-១០នាទី)

ចំនុចទាំងពីរនេះស្រដៀងគ្នាតែខុសគ្នា។ សូមមើលទំព័រ ទី ៣៤ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីពតិមានបន្ថែមនៅលើប្រធានបទនេះ ។ ចង្អុលប្រាប់ពីតំរូវការជ្រើសរើសឱ្យបានច្បាស់លាស់ នូវរបៀបដែលអ្នកនឹងឆ្លើយតបទៅលើវិធីទាំងពីរនេះ ។ អ្នកជ្រើសរើសទុកចិត្តនរណាម្នាក់ ។ អ្នកជ្រើសរើសស្មោះត្រង់ជាមួយពួកគេ ។

ព្រះជាម្ចាស់ល្អឥតខ្ចោះ នៅក្នុងកន្លែងទាំងពីរនេះ ។ ទ្រង់ស្មោះត្រង់នឹងយើងគ្រប់ពេលវេលា ហើយទ្រង់មិនផ្តល់ឱ្យយើងនូវហេតុផលខ្លះៗដែលមិនពិតនោះទេ ។ យើង (មិនមែនជាព្រះ) ចាំបាច់ត្រូវតែរីកលូតលាស់នៅក្នុងកន្លែងទាំងពីរនេះ ។ ចង្អុលបង្ហាញពីការស្តាប់បង្គាប់ដែលបានណែនាំដោយព្រះជាម្ចាស់ ដើម្បីឱ្យព្រះអង្គអាចទុកចិត្តលើយើង ។

## ១៨. រៀនគោរពកោតខ្លាចទ្រង់និងស្រលាញ់ទ្រង់

ព្រះគម្ពីរថ្លែងយ៉ាងច្បាស់លាស់ថា ព្រះជាម្ចាស់មានសេចក្តីស្រលាញ់យ៉ាងខ្លាំង ហើយឱ្យមនុស្សមានការគោរពកោតខ្លាចដល់ទ្រង់ ។ អោយសិស្សមើលទៅចរិកលក្ខណៈនៃសេចក្តីស្រលាញ់ដែលបានផ្តល់ឱ្យនៅ ១ កូរិនថូស ១៣:៤-៨ រួចហើយមើលការអត្ថាធិប្បាយទាំងពីរនេះ ពីផ្លូវដែលព្រះឆ្លើយតបដល់យើង ។ ប្រសិនបើអ្នកមិនមានពេលវេលានៅថ្ងៃនេះ សូមរងចាំរហូតដល់វគ្គសិក្សាក្រោយទៀតដើម្បីមើល ព្រះគម្ពីរ ១ កូរិនថូស ១៣ ។

ចង្អុលបង្ហាញចំនុចដែលយើងត្រូវការដើម្បីឆ្លើយតបទៅនឹងសេចក្តីស្រលាញ់និងសេចក្តីគោរពចំពោះព្រះជាម្ចាស់ ។ ចំពោះក៏រិតដែលយើងឆ្លើយតបចំពោះសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ នោះគឺជាអ្វីដែលកំណត់នៅជំរៅនៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះអង្គ ។ សូមពិភាក្សានៅបញ្ញត្តិដ៏សំខាន់របស់ព្រះអង្គ គឺអោយយើងស្រលាញ់ព្រះអង្គ ។ យើងពិភាក្សានូវមូលហេតុដែលព្រះបង្គាប់ឱ្យយើងមានសេចក្តីស្រលាញ់ចំពោះព្រះអង្គ ។ ព្រមទាំងពិភាក្សានូវខគម្ពីរដែលចែងថា : ប្រសិនបើយើងស្រលាញ់ទ្រង់ យើងនឹងគោរពទ្រង់ ។ យោងទៅតាមតារាងដែលលើកឡើងពីទំនាក់ទំនងបីក៏រិតរបស់យើងជាមួយនឹងព្រះយេស៊ូ ។ បង្ហាញថា តើយើងស្រលាញ់និងគោរពព្រះយេស៊ូដោយ របៀបណាដើម្បីអោយទ្រង់ធ្វើជាអ្នកដឹកនាំរបស់យើង ។ សូមមើលទំព័រ ទី ៣៥-៣៦ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីជាពតិមានបន្ថែមទៀត ។

## ១៩. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥នាទី)

បង្កើតចំនុចឱ្យច្បាស់លាស់នៃការប្រលងប្រណាំងពួកគេដើម្បីប្រាប់ដល់ព្រះដោយមិនលាក់លៀម នៅអ្វីដែលពួកគេចង់ធ្វើ ដោយយោងទៅតាម ទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកគេ ជាមួយព្រះយេស៊ូ ។ ជំរុញអោយពួកគេអនុវត្តន៍នៅជំហានដ៏មានសារៈសំខាន់រាល់ថ្ងៃ ដើម្បីអោយចូលទៅកាន់តែជិតព្រះយេស៊ូ ។

### ក. ផ្តល់តំលៃទំនាក់ទំនងផ្ទាល់ខ្លួនរបស់អ្នកជាមួយព្រះយេស៊ូ

លើកទឹកចិត្តសិស្សអោយផ្តល់តំលៃខ្លួនឯងដោយការថ្លឹងថ្លែងពី ១-១០ ចំនុចនៅគន្លឹះសំខាន់ៗនៃទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះយេស៊ូគ្រីស្ត ( #១ មានអត្ថន័យថា ដែលខ្ញុំមិនស្គាល់ព្រះយេស៊ូ #១០មានអត្ថន័យថា ខ្ញុំមានទំនាក់ទំនងផ្ទាល់ខ្លួនយ៉ាងជិតស្និទ្ធជាមួយនឹងព្រះយេស៊ូ ។)

អោយសិស្សពីរៗនាក់ចែកចាយនូវចំលើយរបស់ពួកគេជាមួយនឹងដៃគូរ ។ បន្ទាប់មកឱ្យគេអធិស្ឋានអោយគ្នាទៅវិញទៅមក ដែលថាពួកគេអាចបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនយ៉ាងជិតស្និទ្ធជាមួយនឹងព្រះយេស៊ូ ។ បើអ្នកគិតថាមិនស្រួលដោយមានសិស្សពីរនាក់រួមគ្នារួមគ្នាអធិស្ឋាន អ្នកអាចឱ្យសិស្សសរសេរការអធិស្ឋានដល់ព្រះជាម្ចាស់បន្ទាប់ពីពួកគេបានបញ្ចប់នូវការផ្តល់តំលៃ ។ សូមប្រាប់ពួកគេឱ្យទូលដល់ព្រះអង្គនូវអ្វីដែលពួកគេចង់ឃើញកើតឡើងនៅក្នុងទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកគេជាមួយព្រះយេស៊ូគ្រីស្ត នៅក្នុងរយៈពេលជាច្រើនថ្ងៃនិងច្រើនសប្តាហ៍ទៅមុខទៀត ។

### ខ. ចំនុចចាប់ផ្តើមសំរាប់ទំនាក់ទំនងផ្ទាល់ខ្លួនយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ

**( គំរោង ទី ១០ ក្នុងសៀវភៅណែនាំសិក្សាសំរាប់សិស្ស )**

តើមនុស្សម្នាក់ចាប់ផ្តើមបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធផ្ទាល់ខ្លួនជាមួយព្រះយេស៊ូនៅកន្លែងណា? គំរោងទី ១០ នៅក្នុងសៀវភៅណែនាំសិក្សារបស់សិស្សផ្តល់ឱ្យការណែនាំនេះ ដែលអាចជួយសិស្សរបស់អ្នកនូវគំនិតខ្លះៗយកមកអនុវត្តន៍ថែមទៀត ។

សូមអោយសិស្សបើកទៅគំរោងនេះហើយមើលត្រួសៗនៅសេចក្តីណែនាំជាមួយពួកគេ ។ ប្រសិនបើជាប្រើរយៈពេលជាងមួយថ្ងៃមុនពេលការសិក្សាបន្តទៅទៀតរបស់អ្នក អ្នកត្រូវការឱ្យពួកគេបំពេញយ៉ាងហោចណាស់នូវការវាយតំលៃមួយក្នុងមួយរយៈថ្ងៃសំរាប់ការសិក្សាពេលក្រោយ ។ បទពិសោធន៍របស់ពួកគេអាចត្រូវបានប្រើនៅក្នុងការពិភាក្សាពីរបៀបមនុស្សម្នាក់ពង្រឹងទំនាក់ទំនងរបស់ពួកគេជាមួយព្រះយេស៊ូ ។

## ២០. កិច្ចការត្រូវធ្វើ

១. ដាក់ពិន្ទុលើ គំរោង ទី ៨ " បង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ ។ "

២. ឱ្យសិស្សអានទំព័រទី ២៧-៣៦ នៅក្នុងសៀវភៅណែនាំរបស់សិស្សដើម្បីរំលឹកការពិភាក្សានៅក្នុងថ្នាក់ និង រៀបចំសំរាប់ថ្នាក់រៀនពេលក្រោយ ។

៣. ដាក់ពិន្ទុគំរោង ទី ៧ " ស្តាប់ស្មង់គ្រីស្ទបរិសទ័ដទៃទៀតដើម្បីរកភស្តុងតាង " នៅថ្ងៃនេះ ប្រសិនបើអ្នកមិនទាន់បានដាក់ពិន្ទុចាំពេលវគ្គសិក្សាក្រោយទៀត។

៤. ត្រួតពិនិត្យដើម្បីធ្វើអោយប្រាកដថា សិស្សរបស់អ្នកយល់ដឹងពីរបៀបបំពេញគំរោង ទី ៩ ស្តីអំពី " ពង្រឹងទំនាក់ទំនងផ្ទាល់ខ្លួនរបស់ខ្ញុំជាមួយនឹងព្រះយេស៊ូ " ។ ពួកគេគួរតែបំពេញកិច្ចការនេះអោយចប់សព្វគ្រប់យ៉ាងហោចណាស់អោយបានមួយថ្ងៃមុនមេរៀនបន្ទាប់ទៀត ។

## ២១. ការវាយតំលៃមេរៀន

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក ។

# បីដំណាក់កាលនៃទំនាក់ទំនងផ្ទាល់ខ្លួនរបស់ខ្ញុំជាមួយនឹងព្រះយេស៊ូ

តារាងនេះសំដែងអោយឃើញបីដំណាក់កាល ដែលមនុស្សអាចពិសោធន៍ក្នុងការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ ។ អ្នកអាចធ្វើតារាងនេះនៅក្នុងក្រដាសធំៗ និង តាំងនៅក្នុងថ្នាក់ រៀនរបស់អ្នកនៅពេលដែលអ្នកបង្រៀនពីការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូ ។

តារាងនៅចំកណ្តាលមានឈ្មោះថា " ចំនុចនៃការទាក់ទង " គឺជាបញ្ហាសំខាន់ៗដែលត្រូវពិភាក្សា ។ ការផ្តោតទៅលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូដែលសំដៅទៅលើបញ្ហាជីវិតដែលបានលើកឡើងនៅក្នុងតារាងនេះ ។ មនុស្សត្រូវតែដោះស្រាយនូវបញ្ហានៃអំពើបាប មុនពេល គេអាចមានប្រសិទ្ធភាពប្តូរមករកកំរិតទីពីរដែលទាក់ទងទៅនឹងរឿងផ្ទាល់ខ្លួនគឺការគោរពវិន័យរបស់ព្រះ យកព្រះគ្រីស្ត ឱ្យដឹកនាំដល់ជីវិតរបស់ខ្លួន ។

សូមមើល សកម្មភាព #១០ នៅក្នុងគំរោងផែនការមេរៀន ទី ៥សំរាប់គ្រូ ដើម្បីជាពត៌មានបន្ថែមនៅលើការប្រើប្រាស់តារាងនេះ ។ កិច្ចការនេះអាចត្រូវបានប្រើនៅក្នុងមេរៀនទី ៦ ដែលជាកន្លែងដែលយើងពិភាក្សាយ៉ាងពិស្តារពីបញ្ហានៃទំនាក់ទំនងផ្ទាល់ខ្លួនជាកូនសោរយ៉ាងសំខាន់ក្នុងការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ ។

**<u>មានបីកំរិតនៃការទាក់ទងផ្ទាល់ជាមួយនឹងព្រះយេស៊ូ</u>**

| អត្ថបទ ខ គម្ពីរ | តួនាទីរបស់ព្រះយេស៊ូឬ ផ្តែតនៅក្នុងទំនាក់ទំនងនេះ | សកម្មភាពរបស់ព្រះយេស៊ូ | ចំនុចនៃការទាក់ទង | តួនាទីរបស់ខ្ញុំ ឬ ផ្តែតនៅក្នុងទំនាក់ទំនងនេះ | សកម្មភាពរបស់ខ្ញុំ |
|---|---|---|---|---|---|
| ១ យ៉ូហាន ១:៩<br>១ យ៉ូហាន ២:១-២<br>កិច្ចការ ៤:១២ | ព្រះសង្គ្រោះ | ទ្រង់ចេញថ្លៃអំពីបាបរបស់ខ្ញុំ ទ្រង់អត់ទោសពីអំពើបាបរបស់ខ្ញុំ | អំពើបាបរបស់ខ្ញុំ | អ្នកមានបាប | សារភាពអំពើបាបរបស់ខ្ញុំ ថ្វាយជីវិតរបស់ខ្ញុំ ដើរតាមព្រះយេស៊ូ |
| ១ យ៉ូហាន ២:៣<br>១ ពេត្រុស ២:២១<br>យ៉ូហាន ១៦:១៣<br>១ កូរិនថូស៦ : ១៩-២០ | ព្រះអម្ចាស់<br>អ្នកដឹកនាំមានចិត្ត<br>អ្នកជាបំរើ | ផ្តល់នូវការដឹកនាំ<br>គ្រូបង្រៀន<br>ជីវិតរបស់ទ្រង់ក្នុងព្រះគម្ពីរផ្តល់ជាជីវិតគំរូ | វិន័យរបស់ព្រះ និងការបង្រៀនស្តីពីអាកប្បកិរិយារបស់ខ្ញុំ | អ្នកដើរតាម<br>អ្នកបំរើ<br>ទាសករ | ស្គាល់វិន័យរបស់ទ្រង់ គោរពវិន័យរបស់ទ្រង់ ស្គាល់ពីព្រះហឫទ័យរបស់ទ្រង់ធ្វើតាមព្រះហឫទ័យ របស់ទ្រង់ |
| យ៉ូហាន ១៥: ១២-១៤<br>យ៉ូហាន ១៥:១៥ | មិត្តភក្តិ | ស្រលាញ់ខ្ញុំ<br>ចែកចាយដោយបើកចំហរ | សកម្មភាពនិមួយៗនៅក្នុងមួយថ្ងៃរបស់ខ្ញុំ | មិត្តភក្តិ | ស្រលាញ់ទ្រង់<br>ចែកចាយដោយបើកចំហរ |

# មេរៀន ទី ៦

## មិត្តភក្តិ

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំត្រូវការសហការជាមួយនឹងព្រះជាម្ចាស់នៅក្នុងការកែប្រែជីវិតប្រចាំថ្ងៃរបស់ខ្ញុំ ដែលជួយខ្ញុំអោយរីតតែជិតស្និទ្ធជាមួយនឹងព្រះអង្គ ។

## ២. ខគម្ពីរសំខាន់ ភីលីព ១ : ៦

*ខ្ញុំជឿជាក់ថាព្រះអង្គដែលបានចាប់ផ្តើមធ្វើការល្អនៅក្នុងបងប្អូនទ្រង់ក៏នឹងបង្ហើយការនេះរហូតដល់ថ្ងៃព្រះ គ្រីស្តយេស៊ូយាងមក ។*

## ៣. យោងតាមឯកសាររបស់សិស្ស

ទំព័រទី ២៧-៣៦ ក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ។ គំរោង ទី ៨, ៩ និង ១០ ពីសៀវភៅណែនាំការសិក្សា អាចប្រើជាមួយនឹងមេរៀននេះ ។

## ៤. ការចាប់ផ្តើមមេរៀន "តើអ្នកបង្កើតចំណងមិត្តភាពនៅឆ្ងាយពីគ្នាដោយរបៀបណា?" (៥-១០ នាទី)

### ក. បញ្ហា (សូមអានដល់សិស្សរបស់អ្នក)

អ្នកចង់បង្កើតមិត្តភាពជាមួយនឹងមនុស្សម្នាក់នៅប្រទេសផ្សេង ។ អ្នកដឹងថា អ្នកនឹងមិនអាចមើលឃើញមនុស្សនោះទេ ព្រោះអ្នកមិនដែលទៅលេងនៅប្រទេសនោះ ។ តើអ្នកបង្កើតចំណងមិត្តភាពជាមួយនឹងមនុស្សនោះដោយរបៀបណា?

### ខ. សកម្មភាពក្រុមតូច

ឱ្យសិស្សក្នុងថ្នាក់បំបែកគ្នាជាក្រុមតូចៗពី៣ទៅ៥នាក់ ។ ទុកពេលអោយគេបួននាទីដើម្បីនាំយកជាមួយនៅបញ្ជីនៃគំនិតផ្សេងៗ ។ ពួកគេគួរតែផ្តល់នៅផែនការសកម្មភាពជាក់លាក់ ។ អ្នកក៏អាចអោយគេសរសេរនូវបញ្ហាខ្លះៗ ដែលពួកគេប្រឈមមុខក្នុងការស្គាល់មនុស្សនោះ ។

### គ. ពេលវេលារាយការណ៍

អោយក្រុមនិមួយៗផ្តល់របាយការណ៍ទៅដល់ថ្នាក់នៃគំនិតរបស់ពួកគេ ។ ពិភាក្សាខ្លីៗទៅលើបញ្ហាដែលពួកគេជួបប្រទះក្នុងការព្យាយាមដើម្បីបង្កើតចំណងមិត្តភាពបែបនេះ ។

អ្នកអាចប្រៀបធៀបអំពីបញ្ហាទាំងនេះដែលយើងប្រឈមមុខក្នុងការព្យាយាមដើម្បីបង្កើតមិត្តភាពជាមួយនឹងព្រះយេស៊ូផងដែរ ។ យើងទាំងអស់គ្នាមិនទាន់បានឃើញព្រះយេស៊ូទេ រហូតដល់យើងទៅកាន់ឋានសួគ៌ទើបឃើញទ្រង់ ប៉ុន្តែយើងអាចរៀនអំពីទំនាក់ទំនងជាមួយព្រះអង្គ ។

នេះជាសំនួរមួយចំនួនដែលយើងនឹងឆ្លើយនៅក្នុងវគ្គសិក្សានេះ ។

១. តើអ្នកចង់បានទំនាក់ទំនងប្រភេទណាជាមួយនឹងព្រះយេស៊ូ?
២. តើអ្នកអាចស្គាល់ព្រះយេស៊ូអោយបានពិតប្រាកដនៅក្នុងខ្លួនរបស់អ្នកដោយរបៀបណា?
៣. តើរយៈពេលយូរប៉ុណ្ណាដើម្បីអោយមានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ?
៤. តើខ្ញុំអាចធ្វើយ៉ាងម៉េចនៅសប្តាហ៍នេះដើម្បីឱ្យទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះយេស៊ូកាន់តែស៊ីជំរៅ?
៥. រំលឹកចំនុចសំខាន់ៗពីមេរៀនទី៥ (៥-១០នាទី)

រំលឹកចំនុចដែលបានធ្វើនៅទំព័រទី ២៨ នៅក្នុងសៀវភៅណែនាំរបស់សិស្ស " តើអ្វីដែលនាំមកការបំពេញចិត្តយ៉ាងពិតប្រាកដនៅក្នុងជីវិត?" សូមសួរបើពួកគេមានសំនួរខ្លះៗអំពីបញ្ហាដែលអ្នកបានបង្រៀនកាលពីមេរៀនវគ្គមុន ។ គូសបញ្ជាក់ខ្លាំងទៅលើការប្តេជ្ញាចិត្តខាងចិត្តគំនិត ខាងឆន្ទះ និងខាងអារម្មណ៍ នៅពេលកំពុងតែស្វែងរកការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ ។

៦. " ការក្លាយជា ១ " ជាមួយព្រះយេស៊ូ (៥-១៥នាទី)

រំលឹកតារាងដែលមានការពិភាក្សាបីដំណាក់នៃទំនាក់ទំនងរបស់យើងជាមួយនឹងព្រះយេស៊ូ ។ តារាងនៅទំព័រ ទី ៦៤ នៅក្នុងសៀវភៅណែនាំសំរាប់គ្រូ ។ កណ្តាលតារាងពិពណ៌នាចំនុចនៃទំនាក់ទំនងដែលយើងមានជាមួយនឹងព្រះយេស៊ូក្នុងដំណាក់និមួយៗ ។ អ្នកអាចបន្ថែមនូវគំនិតនោះដោយការបង្ហាញជូនតាមពតិមានដូចខាងក្រោម ។

ព្រះយេស៊ូអធិស្ឋានក្នុង យ៉ូហាន ១៧:២០-២១ " *ទូលបង្គំមិនអង្វរព្រះអង្គ អោយតែអ្នកទាំងនេះប៉ុណ្ណោះទេ គឺអង្វរអោយអស់អ្នកដែលជឿលើទូលបង្គំតាមរយៈពាក្យ ដែលអ្នកទាំងនេះថ្លែងប្រាប់ផងដែរ (២១) សូមអោយគេទាំងអស់គ្នារួមជាអង្គតែមួយ ដូចព្រះអង្គស្ថិតនៅជាប់ទូលបង្គំ ហើយទូលបង្គំស្ថិតនៅជាប់នឹងព្រះអង្គយ៉ាងណា សូមអោយគេរួមគ្នាជាអង្គតែមួយនៅក្នុងយើងយ៉ាងនោះដែរ ដើម្បីអោយមនុស្សលោកជឿថាព្រះអង្គ បានចាត់ទូលបង្គំអាយមកមែន* " ។ តាមការអធិស្ឋាននៅក្នុងយ៉ូហាន ជំពូក ទី ១៧ នេះគឺជាគំនិតដ៏ធំទូលាយ ។ ព្រះយេស៊ូចង់អោយយើងមានបទពិសោធន៍ ប្រភេទនេះគឺមានភាពតែមួយដែលទ្រង់ហើយនឹងព្រះបិតាមានជាមួយគ្នា ។ នោះគឺជាគោលបំណងយ៉ាងធំរបស់យើង ។

ចាប់ផ្តើមទំនាក់ទំនងជាអតិបរិមាដើម្បីបង្កើតនូវទំនាក់ទំនងរវាងមនុស្សពីរនាក់គឺការការទាក់ទង (ចូរគូររង្វង់ពីរស្ទើរតែជាប់គ្នា)

ទំនាក់ទំនងដែលមនុស្សពីរនាក់នេះមានកាន់តែច្រើន នោះភាពជិតស្និទ្ធកាន់តែមានឡើង ។ (គូររង្វង់ពីរអោយជាន់លើគ្នាខាងចុងបន្តិច ។ ) ការទាក់ទងគ្នាកាន់តែជិតស្និទ្ធការស្គាល់គ្នាក៏កាន់តែច្បាស់លាស់ ។

ការអោយជាន់លើគ្នាកាន់តែច្រើន នោះគេកាន់តែក្លាយទៅជាតែ ១ ។ (ពន្យល់ត្រង់នេះដោយការគូររង្វង់ជាគូរ១យ៉ាងច្រើន ។ ពេលវេលាគូរម្តង១ កាន់តែខិតជិតគ្នា) ។ រង្វង់គូរចុងក្រោយធ្វើអោយវាស្ទើរតែជាន់ពីលើគ្នា ។

ការកាន់តែ " ក្លាយទៅជា ១ " ជាមួយនឹងមនុស្សម្នាក់ទៀត ការស៊ីជំរៅយ៉ាងខ្លាំងក៏កាន់តែមានជាមួយនឹងមនុស្សដែលអ្នកទាក់ទងជាមួយ ។ ដំណើរការទាក់ទងអោយទៅជាមនុស្សតែមួយនេះមិនមែនមានន័យថាម្នាក់ក្នុងចំណោមគ្នាពីរនាក់បាត់បង់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់គេទេ ។ មនុស្សទាំងពីរនោះនៅតែមានភាពច្បាស់លាស់ និង មានបុគ្គលិកលក្ខណៈរបស់គេផ្ទាល់ផងដែរ ។ ប៉ុន្តែជីវិតពួកគេមានដំណើរស្របគ្នា មានគោលបំណង, តំលៃ, អាទិភាពនិង ចំណាប់អារម្មណ៏ស្រដៀងគ្នា ។ ពួកគេស្គាល់ចិត្តគ្នា ពួកគេបើកចំហរក្នុងទំនាក់ទំនងគ្នាទៅវិញទៅមក ។ កូឡូស ៣:១៤ លើសពីនេះទៅទៀតមានចិត្តស្រលាញ់ ដ្បិតសេចក្តីស្រលាញ់ធ្វើអោយបងប្អូនរួបរួមពេញលក្ខណៈ ។

សូមមើលទៅតារាងដែលពិពណ៌នាបីដំណាក់សារឡើងវិញស្តីពីទំនាក់ទំនងជាមួយនឹងព្រះយេស៊ូ ។ សូមគូររូបពីរ៉ាមីត ដោយចាប់ពីកំពូលដល់បាតក្រោមនៃតារាងនោះ ។ នៅពេលដែលយើងទទួលស្គាល់ព្រះយេស៊ូដំបូង វាហាក់ដូចជា កំពូលនៃពីរ៉ាមីតនោះ ។ ខណៈដែលសេចក្តីស្រលាញ់របស់យើងមានកាន់តែខ្លាំងឡើង ទំនាក់ទំនងរបស់យើងក៏រីតតែធំនៅក្នុងជីវិតរបស់យើងដែរ ។ ការពង្រីកនូវសេចក្តីស្រលាញ់របស់យើង នាំអោយយើងមានភាពកាន់តែស្និទ្ធស្នាលក្នុងការទាក់ទងជាមួយនឹងព្រះយេស៊ូ ។

## ៧. ជំហានសំខាន់ៗក្នុងការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ (៥-១៥នាទី)

បងប្អូនបានជ្រាបអំពីរឿងនេះកាលមេរៀនមុនរួចទៅហើយ ដូច្នេះសូមរំលឹកប្អូនចំនុចខ្លី១នៅទំព័រ (៣៣-៣៥) នៃសៀវភៅណែនាំរបស់សិស្ស ។ បើបងប្អូនគ្រាន់តែអត្ថាធិប្បាយទៅលើមេរៀននេះដោយខ្លី១ក៏បាន បន្ទាប់មកអាចបន្ត រីកញែកអោយលំអិតថែមទៀតនូវបញ្ហាទាំងនេះនៅពេលនេះ ។ មើលសកម្មភាពទី ១៤-១៨ នៅលើគំរោងមេរៀនរបស់គ្រូក្នុងមេរៀនទី៥ ទំព័រទី ៥៩- ៦១ ។

## ៨. ការពន្យល់បន្ថាញអំពីជីវិតរបស់ព្រះគ្រីស្ទ (១០-២០នាទី)

ការយកគំនិតទាំងអស់នេះមកអនុវត្ត អ្នកត្រូវសំលឹងមើលទំនាក់ទំនងរបស់ព្រះយេស៊ូជាមួយនឹងមនុស្សផ្សេងៗ នៅក្នុងសម្ពន្ធមេត្រីថ្មី ។ ជាពិសេសផ្តោតទៅលើជំហានជាមូលដ្ឋានបួនដែលតម្រូវអោយមានដើម្បីបង្កើតទំនាក់ទំនង ជាមួយនឹងព្រះយេស៊ូ ដែលបានពិភាក្សានៅទំព័រទី ៣៣-៣៥ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។

## ៩. តើព្រះគម្ពីរបន្ថាញរូបភាពស្តីពីទំនាក់ទំនងរបស់យើងផ្ទាល់ជាមួយនឹងព្រះយេស៊ូដោយរបៀបណា (៥-១៥នាទី)

ពិភាក្សាលើរូបភាពផ្សេងៗដែលមាននៅក្នុងព្រះគម្ពីរពិពណ៌នាអំពីទំនាក់ទំនងរបស់យើងផ្ទាល់ជាមួយនឹងព្រះជាម្ចាស់ ។ អ្នកអាចបន្ថែមអត្ថបទខគម្ពីរ ឬក៏ រូបភាពដទៃទៀតដែលត្រូវបានប្រើ នៅក្នុងព្រះគម្ពីរ ។

១. ឪពុក-កូន យ៉ូហាន ១:១២ ហេប្រឺ ១២

២. អ្នកគង្វាល-ចៀម យ៉ូហាន ១០

៣. កូនក្រមុំ-កូនកំលោះ ម៉ាថាយ ២៥

៤. មេមាន់-កូនរបស់វា ម៉ាថាយ ២៣:៣៧-៣៩

មើលទំព័រ ទី ២៩ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីជាពត៌មានបន្ថែមទៀតនៃចំនុចនេះ ។ បើអ្នកបានរៀនយ៉ាងពិស្តារហើយនៃប្រធានបទមេរៀន ទី ៥ នេះ (សូមមើលសកម្មភាពទី ១០ នៅទំព័រ ទី ៥៦) អ្នកអាចរំលងសកម្មភាពនេះបាន ឬគ្រាន់តែថ្លែងជាសង្ខេបដើម្បីរំលឹកវាឡើងវិញ ។

## ១០. ពិភាក្សា ខគម្ពីរ អេភេសូ ៣:១៤-២១ (៥-១០នាទី)

អេភេសូ ៣:១៤-២១ មានសេចក្តីពិតដែលគួរអោយចាប់អារម្មណ៍យ៉ាងខ្លាំងអំពីទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ ។ សំនួរទី៦ នៅគំរោង ទី ៨ ស្តីពី " បង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូ " ។ សួរសិស្សអោយ បញ្ចេញយោបល់ថាតើ ពួកគេអាចបង្កើតចំណងមិត្តភាពយ៉ាងជិតស្និទ្ធជាមួយនឹងព្រះយេស៊ូដោយរបៀបណា ។ អោយពួកគេចែកចាយនូវចំលើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ អ្នកអាចយកការរកឃើញរបស់ពួកគេដាក់លើក្តារខៀន ឬ ឧបករណ៍បញ្ចាំងអក្សរ ។

## ១១. គំរូទំនើប និង ខាងប្រវត្តិសាស្ត្ររបស់មនុស្សដែលបានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ (៥-១៥នាទី)

បើអ្នកមានពេលសូមអ្នកពិភាក្សាជាមួយនឹងសិស្សនៅក្នុងថ្នាក់អំពីភាពខុសប្លែកគ្នានៃមនុស្សសម័យមុននិងមនុស្សឥឡូវនេះ អំពីមនុស្សដែលមានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះយេស៊ូ ។ អ្នកអាចសំភាសគ្រីស្ទបរិស័ទចាស់ៗខ្លះ នៅតាមតំបន់របស់អ្នក ដោយសួរពួកគេថាតើ ពួកគេមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូដោយរបៀបណា? សូមចែកចាយចំលើយនេះជាមួយសិស្សក្នុងថ្នាក់ ។ អ្នកអាចត្រិះរិះពិចារណា

ដោយកត់សំគាល់នូវការសាកសួរសំនួរទាំងនោះ ដើម្បីអ្នកអាចបកស្រាយតាមផ្នែកសំខាន់ៗដល់សិស្សនៅក្នុងថ្នាក់ ។

## ១២. រាយការណ៍នៅលើគំរោង ទី ៩ និង ទី ១០ (៥-១៥នាទី)

បើសិស្សរបស់អ្នកមានពេលគ្រប់គ្រាន់ដើម្បីចាប់ផ្តើមធ្វើគំរោង ទី ៩ និង ទី ១០ សូមអោយពួកគេច្រើននាក់ចែកចាយនូវចំលើយនៃគំរោងរបស់ពួកគេ ។ បើសិស្សរបស់អ្នកគ្មានពេលធ្វើកិច្ចការនេះទេអ្នកអាចចែកចាយឧទាហរណ៍ជាច្រើនពីកិច្ចការដែលសិស្សបានធ្វើនៅលើគំរោងទាំងនេះពីពេលមុននៅពេលដែលអ្នកបានបង្រៀននៅមុខវិជ្ជានេះ ។ ប្រសិនបើពេលនេះគឺជាពេលដំបូងដែលអ្នកបង្រៀននៅមុខវិជ្ជានេះ អ្នកប្រហែលចង់រក្សាទុកដោយថតចំលងនៅកិច្ចការរបស់ពួកគេនៅលើគំរោងទាំងនេះ ធ្វើដូច្នេះអ្នកអាចប្រើឧទាហរណ៍របស់ពួកគេ នៅពេលក្រោយដែលអ្នកបង្រៀនមេរៀននេះ ។ សូមធ្វើអោយប្រាកដថាអ្នកទទួលការអនុញ្ញាតពីសិស្ស ប្រសិនបើអ្នកចង់ធ្វើកិច្ចការនេះ ។

## ១៣. ការបង្ហាញនូវការអនុវត្តន៍នៃសេចក្តីស្រលាញ់ពី ១ កូរិនថូស ១៣:១-៨ (៥-១៥នាទី)

ការស្វែងរកនូវវិធីអនុវត្តន៏ ដើម្បីបង្ហាញនៅសេចក្តីស្រលាញ់របស់យើង ទៅកាន់ព្រះជាម្ចាស់ជាញឹកញាប់គឺមានការខិតខំអស់ពី សមត្ថភាព។ លក្ខណៈនៃសេចក្តីស្រលាញ់គឺនៅ ១ កូរិនថូស ១៣:១-៨ ផ្តល់អោយចំនុចចាប់ផ្តើមដ៏ល្អ សំរាប់អស់អ្នកដែល ស្វែងរកផ្លូវអនុវត្តន៏នៃសេចក្តីស្រលាញ់របស់ពួកគេទៅកាន់ព្រះជាម្ចាស់។ បើសិនជាមានពេល ចូរមើលចំនុចនិមួយៗនៃសេចក្តីស្រលាញ់ រួចពិភាក្សារករបៀបដែលយើងអាចបង្ហាញទៅកាន់ព្រះជាម្ចាស់ ។

ខ ទី បួន បានថែងថា " សេចក្តីស្រលាញ់គឺអត់ធ្មត់ " តើមធ្យោបាយអ្វីខ្លះដែលយើងអាចបង្ហាញនៅការអត់ធ្មត់ក្នុងទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់? ប្រហែលអ្នកខ្លះកំពុងតែទូលសុំព្រះអង្គចំពោះការអស្ចារ្យនៅក្នុងជីវិតរបស់គេ ។ ការបង្ហាញពីភាពអត់ធ្មត់ទៅព្រះជាម្ចាស់ គឺបញ្ជាក់ពីសេចក្តីស្រលាញ់ ។ រៀងរាល់ពេលដែលអ្នកបង្ហាញពីការអត់ធ្មត់នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នក នោះក៏អាចជាការបញ្ជាក់ពីសេចក្តីស្រលាញ់ចំពោះព្រះជាម្ចាស់ដែរ ។

បើយើងចេះអត់ធ្មត់ និង បំណងរបស់យើងបង្ហាញពីស្រលាញ់ដល់ព្រះអង្គ ទ្រង់នឹងមើលឃើញសកម្មភាពនៃសេចក្តីស្រលាញ់របស់យើង ។ ព្រះយេស៊ូបានមានព្រះបន្ទូលនៅក្នុងម៉ាថាយ ១០ : ៤០-៤២ ថាអ្នកណាអោយទឹកត្រជាក់សូម្បីតែមួយកែវដល់អ្នកតូចតាចក្នុងនាមព្រះអង្គទ្រង់មើលឃើញ។

មានបញ្ហាពីរដែលលើកឡើងនៅក្នុង ១ យ៉ូហាន ស៊ីគ្នានឹងបញ្ហានេះ ។ ១ យ៉ូហាន ២:៣-១១ និយាយអំពីទំនាក់ទំនងរវាងការស្រលាញ់ព្រះជាម្ចាស់ និង ការស្អប់ខ្ពើមបងប្អូនរបស់អ្នក។ ១យ៉ូហាន ២:១៥ និយាយអំពីការស្រលាញ់ព្រះជាម្ចាស់ ឬក៏ ស្រលាញ់ពិភពលោកឬក៏ មិនស្រលាញ់ទាំងពីរ ។ អ្នកក៏អាចពិភាក្សាផងដែរពីការគោរពវិន័យរបស់ព្រះជាម្ចាស់ គឺជាការបង្ហាញសេចក្តីស្រលាញ់របស់យើងចំពោះទ្រង់ ។

## ១៤. តើមានលទ្ធផលអ្វីក្នុងការស្គាល់ព្រះជាម្ចាស់ផ្ទាល់ខ្លួន? (៥-១០នាទី)

សូមពិភាក្សាលទ្ធផលនៃការស្គាល់ព្រះជាម្ចាស់ផ្ទាល់ខ្លួន ។ តើឥទ្ធិពលអ្វីនឹងមានចំពោះមិត្តភាពនេះទៅលើការរស់នៅប្រចាំថ្ងៃរបស់អ្នក ។ សូមមើលទំព័រ ៣៥-៣៦ នៅក្នុងសៀវភៅណែនាំរបស់សិស្សដើម្បីជាពតិមានបន្ថែមទៀតត្រង់ចំនុចនេះ ។

## ១៥. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥នាទី)

គ្រប់ទំនាក់ទំនងទាំងអស់អាចផ្តល់ប្រយោជន៏ ដោយការប្រើពេលវេលាចំពោះការគិតគូហើយ និង ការវាយតំលៃ ។ មានប្តីម្នាក់សួរខ្លួនឯងថា ប្រសិនបើទំនាក់ទំនងគាត់ជាមួយនឹងប្រពន្ធគាត់គឺជាកិច្ចការទាំងអស់ដែលអាចទទួលយកបាន ។ ប្រពន្ធរបស់គាត់ក៏សួរខ្លួនឯងដូចនេះដែរ ។ យើងវិញក៏ត្រូវធ្វើអោយដូចជាប្តី និង ប្រពន្ធនេះដែរ ក្នុងទំនាក់ទំនងរបស់យើងជាមួយនឹងព្រះយេស៊ូ ។ យើងគិតសិនហើយសួរខ្លួនឯងថា! តើកំពុងមានទំនាក់ទំនងល្អទេជាមួយនឹងព្រះអង្គ?

ឥឡូវនេះអោយសិស្សចំណាយពេលខ្លះៗដើម្បីគិតអំពីទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះយេស៊ូ។ ជ្រើសរើស មួយនៃសកម្មភាពខាងក្រោមនេះដើម្បីជាសេចក្តីសន្និដ្ឋានមេរៀននេះ ។

**ក, ការវាយតំលៃផ្ទាល់ខ្លួនជាមួយនឹងគំនូរ ឬក៏ កំណាព្យ**

ប្រើសំនួរទាំងនេះដើម្បីជួយអ្នកក្នុងការវាយតំលៃទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះយេស៊ូ ។ (បង្ហាញសំនួរទាំងនេះដោយម៉ាស៊ីនបញ្ចាំង ឬ ថតចំលងរួចចែកអោយពួកគេ) ។

១. តើទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះយេស៊ូរីកចំរើនទេ?

២. តើព្រះយេស៊ូហាក់ដូចជានៅឆ្ងាយឬ?

៣. តើខ្ញុំពិតជាស្រលាញ់ព្រះយេស៊ូឬទេ? តើស្រលាញ់ប៉ុណ្ណា?

៤. តើព្យាយាមស្រលាញ់ទ្រង់ច្រើនថែមទៀតឬទេ?

៥. តើខ្ញុំអាចធ្វើយ៉ាងដូចម្តេចដើម្បីអោយទំនាក់ទំនងរបស់ខ្ញុំប្រសើរឡើងជាមួយនឹងព្រះយេស៊ូ?

បន្ទាប់ពី៥ទៅ១០នាទីកន្លងផុត (តាមតែអ្នកគិតថាគ្រប់គ្រាន់សំរាប់ពួកគេហើយ) អោយសិស្សជ្រើសរើសតែ មួយនៃសកម្មភាពដូចខាងក្រោម :

(១) ធ្វើជារូបភាព ឬ សញ្ញាផ្សេងៗ ឬក៏សំលេង ដែលបង្ហាញពីរបៀបដែលអ្នកមានអារម្មណ៍អំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះយេស៊ូ ។

(២) សរសេរកំណាព្យដែលបង្ហាញពីរបៀបដែលអ្នកមានអារម្មណ៍អំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះយេស៊ូ ។

**ខ ការវាយតំលៃនៃចំនុចតឹងតែងរបស់ខ្ញុំ**

អោយសិស្សរបស់អ្នកសំដែងចំនុចមួយដែលពួកគេតឹងតែង ខឹង ឬ បាក់ទឹកចិត្ត ។ ពួកគេមិនចាំបាច់ត្រូវប្រាប់សិស្សក្នុងថ្នាក់អំពីបញ្ហានេះទេ ។ អោយពួកគេគិតអំពីស្ថានភាពប្រភេទនេះ ដែលអាចជាឱកាសអោយពួកគេចូលទៅរកព្រះជាម្ចាស់បាន ។ អោយពួកគេសរសេរវិធីមួយដែលពួកគេអាចបញ្ចេញសេចក្តីស្រលាញ់របស់ពួកគេដល់ព្រះអង្គតាមរយៈស្ថានភាពដ៏លំបាកនេះ ។ ប្រហែលជាអ្នកពន្យល់អំពីបញ្ហានេះមកពីជីវិតរបស់អ្នកផ្ទាល់ជាមុនសិន ។ ចូរបិទវគ្គសិក្សាដោយការអធិស្ឋានថ្វាយ និង ប្តេជ្ញាចិត្តដើម្បីបង្កើតទំនាក់ទំនងអោយកាន់តែជិតស្និទ្ធជាមួយនឹងព្រះយេស៊ូ ។

## ១៦. កិច្ចការដែលត្រូវធ្វើ

១. ដាក់ពិន្ទុគំរោង ទី ៨នៅថ្ងៃនេះ ។

៣. ពិនិត្យមើលការរីកចំរើនរបស់ពួកគេនៅគំរោង ទី៩ដែលស្តីពី "សរសេររឿងរបស់អ្នក" ចូរអោយគេដឹងថា គេមិនត្រូវពន្យាពេលហួសថ្ងៃកំណត់ឡើយ ។

## ១៧. ការវាយតំលៃនិងគំនិតរបស់ខ្ញុំសំរាប់ការបង្រៀនមេរៀននេះនៅពេលក្រោយ

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក ។

# មេរៀន ទី ៧

## ការបង្កអោយមានមន្ទិលសង្ស័យ

### ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំត្រូវតែរកអោយឃើញនូវអ្វីដែលកើតឡើងចំពោះជីវិតប្រចាំថ្ងៃរបស់ខ្ញុំ ដែលបណ្តាលអោយខ្ញុំមានមន្ទិលសង្ស័យ នៅក្នុងជីវិតជាគ្រីស្តបរិស័ទ ។

### ២. ខគម្ពីរសំខាន់ យ៉ាកុប ១:៥-៦

*ក្នុងចំណោមបងប្អូន ប្រសិនបើមាននរណាម្នាក់ខ្វះប្រាជ្ញា អ្នកនោះត្រូវតែទូលសូមពីព្រះជាម្ចាស់ព្រះអង្គ នឹងប្រទានអោយមិនខាន ដ្បិតទ្រង់ប្រទានអោយមនុស្សទាំងអស់ ដោយព្រះហឫទ័យទូលាយ ឥតបន្ទោសឡើយ ក៏ប៉ុន្តែ អ្នកនោះត្រូវទូលសូម ដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ ដ្បិតអ្នកដែលមានចិត្តសង្ស័យ ប្រៀបបានទៅ នឹងរលកសមុទ្រត្រូវបក់បោកចុះឡើងទៅតាមខ្យល់ ។*

### ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រទី ៣៧-៤៦ ក្នុងសៀវភៅណែនាំរបស់សិស្ស ស៊ីគ្នាជាមួយនឹងមេរៀននេះ។ គំរោងទី ១១ ស្តីពីរ " ចុះចំណែកមន្ទិលសង្ស័យវិញ? " នៅក្នុងសៀវភៅណែនាំសិក្សា ក៏នឹងត្រូវយកមកប្រើនៅក្នុងមេរៀននេះដែរ ។

### ៤. ការរៀបចំមុនរបស់គ្រូ

នៅក្នុងជំពូកទីបួននៃមុខវិជ្ជានេះទាក់ទងជាមួយការសង្ស័យ ។ អាស្រ័យទៅលើថាអ្នកមានពេលប៉ុន្មានហើយនិងការ ចាប់អារម្មណ៏របស់សិស្ស អ្នកត្រូវតែសំរេចចិត្តថាអ្នកត្រូវចំណាយពេលពីរឬបីវគ្គក្នុងការបង្រៀនមេរៀននៃការសង្ស័យ នេះ ។ មានគំរោងមេរៀនបីដែលត្រូវបានផ្តល់នៅទីនេះ ។

មេរៀនទី ៧ ទាក់ទងទៅនឹងការបង្កអោយមានមន្ទិលសង្ស័យ ។

មេរៀនទី ៨ ផ្តល់គំរូសំរាប់ដោះស្រាយបញ្ហាដែលបណ្តាលអោយមានការសង្ស័យ។ បទពិសោធន៏របស់លោក ***ថូម៉ាស*** ដែលជាសាវ័ករបស់ព្រះយេស៊ូ ជាផ្នែកសំខាន់នៅក្នុងមេរៀននេះ ។

មេរៀនទី៩ ផ្តល់ការហ៊ឹកហាត់បន្ថែមពីរបៀបបំបាត់ចោលនូវមន្ទិលសង្ស័យ និង ឥទ្ធិពលដែលមាននៅក្នុងជីវិតគ្រីស្តបរិស័ទ ។

### ៥. ការចាប់ផ្តើមមេរៀន " ដាក់ពិន្ទុលើមន្ទិលសង្ស័យ និង សំនួររបស់ខ្ញុំ (៥-១០នាទី)

ប្រើសំនួរខ្លីៗដែលមានចំណងជើងថា " ដាក់ពិន្ទុលើមន្ទិលសង្ស័យ និង សំនួររបស់ខ្ញុំ " ដើម្បីចាប់ផ្តើមមេរៀននៅថ្ងៃនេះ។

អ្នកអាចរកបាននៅក្រដាសថតចំឡងសំនួរខ្លីៗនេះភ្ជាមៗនៅគំរោងមេរៀននេះនៅក្នុងទំព័រទី ៨២ ។ សូមថតចំលងនូវសកម្មភាពវាយតំលៃនេះ ហើយអោយដល់សិស្សម្នាក់ៗ។ សូមអោយពេលពួកគេ ៣-៥នាទីដើម្បីអោយគេដាក់ពិន្ទុខ្លួនឯង ។ ចង្អុលបង្ហាញប្រាប់ពួកគេថា សេចក្តីណែនាំមិនតំរូវអោយពួកគេវាយតំលៃពីថាតើពួកគេមានអារម្មណ៍យ៉ាងដូចម្តេចអំពីកន្លែងទាំងនេះនៅថ្ងៃនេះនោះទេ ។ ពួកគេត្រូវធ្វើការវាយតំលៃប្រសិនបើពួកគេមាន( នៅក្នុងអតីតកាល ឬក៏បច្ចុប្បន្នកាល) មន្ទិលសង្ស័យ ឬក៏ សំនួរនៅក្នុងកន្លែងទាំងនេះ ។

បន្ទាប់ពីពួកគេបានដាក់ពិន្ទុខ្លួនគេរួចហើយ អ្នកអាចស្តាប់ការពន្យល់របស់គេវិញក្នុងរបៀបផ្សេងៗពីគ្នាជាច្រើន ។ ទីមួយត្រូវមើលចំលើយរបស់ពួកគេ ហើយសុំអោយគេលើកដៃឆ្លើយចំលើយនិមួយៗដែលអ្នកចង់អោយគេពន្យល់ ។ មួយទៀត គឺសូមអោយសិស្សម្នាក់ៗចែកចាយនូវចំនុចខ្លះៗ ដែលគេធ្លាប់មានបទពិសោធន៍ពីការសង្ស័យ ឬក៏ សំនួរ " ច្រើន " ។ បន្ទាប់ពីសិស្សរបស់អ្នកបានធ្វើកិច្ចការនេះហើយ អ្នកអាចអោយពួកគេរាល់គ្នាចែកចាយនូវកន្លែងមួយ ឬ ពីរទៀត (បើសិនជាពួកគេមាន) ជាកន្លែងដែលពួកគេស្ទើរតែមិនដែលមានការសង្ស័យ ឬ សំនួរប្រភេទនោះ ។

ត្រង់ចំនុចនេះសូមណែនាំឱ្យគេស្គាល់ជំពូកទី៤ នៃមុខវិជ្ជានេះ ។ ចូរពន្យល់នូវចំនុចណាដែលអ្នកយកមកបង្រៀនក្នុងមេរៀននេះ និង អ្វីដែលអ្នកនឹងបង្រៀនសំរាប់មេរៀនបន្ទាប់ ។ ការធ្វើយ៉ាងដូច្នេះនឹងជួយផ្តល់អោយពួកគេនូវទិសដៅពីរបៀបដែលអ្នកនឹងបង្រៀន ។

## ៦. និយមន័យនៃ " ការសង្ស័យ " (៣-៥នាទី)

ចំណាយពេលវេលានៃពេលដំបូងរបស់ថ្នាក់រៀនដើម្បីពន្យល់ពីអត្ថន័យនៃពាក្យថា " សង្ស័យ " ។ អោយសិស្សអាននូវ ចំលើយ នៃសំនួរទី២ នៅក្នុងគំរោងទី១១ ដែលសួរពួកគេអោយសរសេរនូវនិយមន័យរបស់ពាក្យ "សង្ស័យ " ។ សិស្សខ្លះត្រូវការពន្យល់បង្ហាញច្រើន ទើបគេអាចចាប់បាននូវអ្វីដែលយើងកំពុងតែនិយាយ ។ នៅក្នុងចំនុចនេះយើងប្រើ ពាក្យ "សង្ស័យ" នៅក្នុងន័យជាទូទៅ ។ តាមពិតយើងសំដៅទៅលើសំនួរ ឬ ការមិនច្បាស់លាស់ដែលមនុស្សម្នាក់ៗមាន ។

## ៧. ធ្វើបញ្ជីការសង្ស័យខ្លះៗដែលគ្រីស្ទបរិស័ទថ្មីមាន (៥នាទី)

ឱ្យសិស្សចែកចាយពីការសង្ស័យខ្លះៗដែលពួកគេមានអំពីព្រះជាម្ចាស់ និង ការធ្វើជាគ្រីស្ទបរិស័ទ ។ វាអាចជួយបានដែរដោយមើលទៅលើបញ្ហា ដែលត្រូវបានលើកឡើងនៅក្នុងសកម្មភាពចាប់ផ្តើមមេរៀន ។ ពួកគេអាចចែកចាយនូវចំលើយ ដែលពួកគេបានឆ្លើយក្នុងគំរោងទី ១១ សំនួរទី ៥ ដែលសួរថា តើការសង្ស័យនិង សំនួរអ្វីខ្លះដែលអ្នកមានអំពីព្រះជាម្ចាស់, អំពីព្រះគម្ពីរ ឬក៏ អំពីការក្លាយជាគ្រីស្ទបរិស័ទ ។

យើងចង់ព្យាយាមផ្តោតអារម្មណ៍របស់យើងទៅលើការសង្ស័យពីព្រះជាម្ចាស់ហើយនិងទំនាក់ទំនងរបស់យើងជាមួយនឹងព្រះអង្គ ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាខ្លះមើលមុនដំបូងទៅ គឺហាក់ដូចជាគ្មានអ្វីទាក់ទងជាមួយនឹងទំនាក់ទំនងព្រះជាម្ចាស់សោះ តែអាចបណ្តាលមានមកពីការសង្ស័យអំពីព្រះជាម្ចាស់ និងការមិនច្បាស់លាស់នៃសេចក្តីសង្គ្រោះ។ សូមប្រុងប្រយ័ត្នកុំចោលសំនួរដែលសិស្សបានសួរ ។ ប៉ុន្តែត្រូវត្រៀមខ្លួន យកការពិភាក្សាត្រឡប់ទៅរឿងដែលអ្នកចង់បង្រៀន ។ លើកទឹកចិត្តសិស្សដែលមានសំនួរខ្លះទៀត អោយជួបអ្នកនៅក្រោយម៉ោងរៀន ។ យើងក៏ចង់ការពារកុំអោយមាននូវការពិភាក្សាជ្រាលជ្រៅខ្លាំងពេកនៃសាសនាវិទ្យា អំពីសំនួរដែលពិបាក ដែលមានការបែងចែកនូវនិកាយផ្សេងៗដែរ ។ សូមរក្សាអោយមានការអនុវត្តន៏ និង អាចជាប្រយោជន៏ដល់អ្នករាល់គ្នា។

មានសក្តានុពលភាពយ៉ាងពិតប្រាកដសំរាប់ការលាក់ពុតខាងព្រលឹងវិញ្ញាណចូលមក ពេលដែលយើងបកស្រាយនូវ ជំពូកទី ៤ នៃមុខវិជ្ជានេះ ។ " សង្ស័យ? ខ្ញុំមិនដែលមានការសង្ស័យផង! លើកលែងតែគ្រីស្តបរិស័ទខ្សោយទេ ដែលមានការសង្ស័យ ។ ខ្ញុំពេញដោយព្រះវិញ្ញាណ ខ្ញុំមិនដែលមានការសង្ស័យទេ " ។ កុំអនុញ្ញាតអោយខ្លួនអ្នក ឬ សិស្សណាម្នាក់កើតមាននូវអាកប្បកិរិយានេះ ។ មិន មែនអ្នករាល់គ្នាមានបញ្ហាជាមួយការសង្ស័យទេ ប៉ុន្តែមនុស្សភាគច្រើនមាន ហើយយើងត្រូវតែទទួលយកនូវវិន័យដែល មាននៅក្នុងគម្ពីរយូដាស ខ ទី ២២ " ត្រូវមេត្តាករុណាដល់បងប្អូនដែលមានចិត្តស្ទាក់ស្ទើរ " ។

## ៨. តើអ្វីដែលបង្កអោយមានការសង្ស័យដល់មន្ត្រីអ្នកមានទ្រព្យវ័យក្មេងម្នាក់? (១០-១៥នាទី)

សូមអោយសិស្សអាននូវគម្ពីរម៉ាកុស ១០:១៧-២២ រឿងអំពីមន្ត្រីអ្នកមានទ្រព្យវ័យក្មេងម្នាក់ដែលមករកព្រះយេស៊ូ ។ ខាងក្រោមនេះជាសំនួរខ្លះៗ ដែលអ្នកអាចប្រើដើម្បីពិភាក្សាតាមការពន្យល់បកស្រាយក្នុងព្រះគម្ពីរ ។

១. តើសំនួរអ្វីដែលបុរសនោះចង់អោយព្រះយេស៊ូឆ្លើយ?

- " លោកគ្រូដ៏សប្បុរសអើយ! តើខ្ញុំត្រូវធ្វើអ្វីដើម្បីអោយបានទទួលជីវិតអស់កល្បជានិច្ច? "

២. តើព្រះយេស៊ូឆ្លើយតបទៅគាត់វិញដោយរបៀបណា?

- " ដកស្រង់ខ្លះចេញពីក្រឹត្យវិន័យទាំង១០ប្រការ ។ "

៣. តើចំលើយអ្វីដែលបុរសអ្នកមាននោះបានឆ្លើយតបទៅនឹងក្រឹត្យវិន័យទាំង១០ប្រការ?

- " ខ្ញុំបានប្រតិបត្តិតាមវិន័យទាំងនេះតាំងពីក្មេងមក " ។

ការពន្យល់- តែគាត់មានការសង្ស័យអំពីការទៅស្ថានសួគ៌ទៀត ។ ចូរគូសបញ្ជាក់ថា គ្រីស្តបរិស័ទជាច្រើនមិនមែនត្រឹមតែអ្នកជឿថ្មីទេដែលត្រូវឆ្លងកាត់នូវការសង្ស័យ ។

៤. តើព្រះយេស៊ូបានចង្អុលបង្ហាញបញ្ហាអ្វីដែលបង្កអោយបុរសនេះនៅតែមានការសង្ស័យ? តើដំណោះស្រាយ អ្វីដែលព្រះយេស៊ូបានឆ្លើយទៅកាន់បុរសនេះ?

-បញ្ហារបស់គាត់--គឺលុយ

-ដំណោះស្រាយរបស់ព្រះយេស៊ូ- " ត្រូវទៅលក់អ្វីៗដែលអ្នកមានរួចចែកអោយជនក្រីក្រទៅ ធ្វើដូច្នេះ ទើបអ្នកមានសម្បត្តិសួគ៌ បន្ទាប់មកសូមអញ្ជើញមកតាមខ្ញុំ " ។

៥. តើអ្នកមានម្នាក់នេះឆ្លើយតបទៅនឹងដំបូន្មានរបស់ព្រះយេស៊ូយ៉ាងណា?

- " គាត់មានទឹកមុខស្រពោន ហើយវិលត្រឡប់ទៅវិញ ទាំងព្រួយចិត្ត " ។

ចូរបង្ហាញអោយសិស្សដឹងថា បុរសម្នាក់នេះគឺជាអ្នកជឿស្មោះចំពោះព្រះជាម្ចាស់ ។ គាត់ឆ្លាតណាស់ ក្នុងការមករកព្រះយេស៊ូដោយខ្លួនគាត់ ដើម្បីទទួលចំលើយសំរាប់សំនួររបស់គាត់ ។ ប៉ុន្តែអ្វីដែលគួរអោយសោកស្តាយគឺគាត់បដិសេធន៍នូវ ដំណោះស្រាយរបស់ព្រះអង្គ ។ នៅត្រង់នេះ គឺយើងចង់សង្កត់ទៅលើការពិភាក្សាដែលបង្កអោយមានការសង្ស័យ -- បញ្ហារបស់គាត់គឺលុយ ។ គាត់អាចបដិសេធន៍នូវដំណោះស្រាយរបស់ព្រះយេស៊ូ ដែលរួមបញ្ចូលការត្រាស់ហៅអោយមានជីវិតថ្មីក្នុងភាពក្រីក្រ ។

អ្វីដែលយើងចង់បង្ហាញអោយច្បាស់ត្រង់នេះគឺថា ការសង្ស័យមិនមែនជាបញ្ហាទេ--វាជាលទ្ធផល ឬជាសញ្ញានៃបញ្ហា ។ ពេលដែលមនុស្សមានការសង្ស័យ មានអ្វីម្យ៉ាងដែលបណ្តាលអោយកើតឡើងហើយ ។ បញ្ហាខុសគ្នាគ្រប់ប្រភេទ អាចបង្កអោយមានការសង្ស័យនៅក្នុងជីវិតគ្រីស្តបរិស័ទ ។ ការសង្ស័យរបស់អ្នកមានវ័យក្មេងនេះត្រូវបានបង្កមកពីលុយប៉ុណ្ណោះ ប៉ុន្តែមកពីអាកប្បកិរិយាដែលគាត់មានចំពោះលុយរបស់គាត់ ។

## ៩. បញ្ហាដែលធ្វើអោយមានការសង្ស័យ (៥-១០នាទី)

អោយសិស្សសរសេរនូវបញ្ហាខុសៗគ្នា ដែលបង្កអោយពួកគេមានការសង្ស័យចំពោះភាពជាគ្រីស្តបរិស័ទ ។ បញ្ហា ឬក៏ សំនួរខ្លះៗដែលពួកគេបង្ហាញនោះប្រហែលជាមិនចងភ្ជាប់ដោយផ្ទាល់ទៅនឹងមន្ទិលសង្ស័យ ។ ការនោះមិនមានបញ្ហានោះទេ ។ បន្តអោយមានការពិភាក្សាដំណើរការទៅមុន ។ បញ្ហារបស់ពួកគេខ្លះ អ្នកអាចអោយសិស្សធ្វើការបកស្រាយដោយសង្ខេបថាតើការសង្ស័យប្រភេទអ្វីដែលបង្កអោយមានបញ្ហា ។

បើសិនពួកគេមានការលំបាកក្នុងការគិតពីបញ្ហាដែលបណ្តាលអោយមានការសង្ស័យ ចូរត្រឡប់ទៅការសង្ស័យ និង សំនួរដែលពួកគេបានផ្តល់អោយមុននៅក្នុងមេរៀននេះ ។ (មើលគំរោងមេរៀន សកម្មភាពទី៧)

អ្នកក៏អាចបង្ហាញបញ្ហាដែលត្រូវបានផ្តល់អោយនៅក្នុងសៀវភៅណែនាំរបស់សិស្ស ទំព័រ ទី ៤១-៤៥ ផងដែរ ។ ប្រសិនបើអ្នកមានបញ្ជីសំនួរល្អហើយ ចូរទុកវាសិនរហូតដល់វគ្គរៀនលើកក្រោយ ពេលដែលអ្នកពិភាក្សាដំណោះស្រាយមន្ទិលសង្ស័យ ។

គោលដៅរបស់យើងនៅទីនេះគឺចង់បង្ហាញពីបញ្ហាខុសគ្នាដែលបណ្តាលឱ្យមានការសង្ស័យ ។ កុំទាន់ពន្យល់អោយល្អិតល្អន់ពេលនេះពីរបៀបត្រូវដោះស្រាយ ។ យើងនឹងពិភាក្សាវានៅវគ្គសិក្សាពេលក្រោយ ។

## ១០. តើនរណានាំការសង្ស័យទាំងនេះមកក្នុងគំនិតរបស់អ្នក? (១០-១៥នាទី)

ត្រង់ចំនុចនេះអាចបង្កអោយមានការច្រឡំយ៉ាងងាយស្រួល ចូរប្រយត្ន័ត្រូវបកស្រាយអោយច្បាស់លាស់ហើយពន្យល់ បង្ហាញពីចំនុចនិមួយៗ ។ ទំព័រ ៣៨-៤០ នៅក្នុងសៀភៅណែនាំរបស់សិស្ស ផ្តល់អោយចំនុចចាប់ផ្តើមល្អសំរាប់ប្រភពបួន យ៉ាងដែលបង្កអោយមានការសង្ស័យ ។

**សាតាំង :**

ប្រភពដែលងាយស្រួលបំផុតនៃការសង្ស័យគឺសាតាំង ។ ចូរចង្អុលបង្ហាញនូវខគម្ពីរខ្លះ ដែលបង្ហាញថាសាតាំងជាអ្នកកុហក ហើយអ្នកបោកប្រាស់ ។ ប្រាកដណាស់វានឹងធ្វើអ្វីៗក្នុងអំណាចរបស់វាដើម្បីធ្វើអោយគ្រីស្តបរិស័ទថ្មីបាក់ទឹកចិត្ត ។ ចូរមើលបញ្ជីនៃបញ្ហាឡើងវិញ ហើយពន្យល់បង្ហាញពីរបៀបដែលសាតាំងអាចប្រើអំណាចវា ដើម្បីនាំអោយ មានការសង្ស័យនៅក្នុងចិត្តគំនិតរបស់អ្នក ។

**មនុស្សដទៃ :**

សៀវភៅណែនាំសំរាប់សិស្ស នៅទំព័រ ទី ៣៨-៣៩ បង្ហាញពីផ្លូវខុសគ្នាខ្លះៗ ដែលអ្នកដទៃអាចនាំនូវការសង្ស័យដាក់ទៅក្នុងចិត្តគំនិតរបស់អ្នក ។ អោយសិស្សខ្លះផ្តល់នូវឧទាហរណ៍មកពីជីវិតរបស់គេផ្ទាល់នៃការសង្ស័យដែលកើតឡើងដោយ សារអ្នកដទៃ ។

**ខ្លួនឯង :**

ចង្អុលបង្ហាញថា ការសង្ស័យគឺជាការគិតនៅក្នុងគំនិតរបស់អ្នក ។ ពេលខ្លះគំនិតនេះមកពីអ្នកដទៃ ។ ប៉ុន្តែមនុស្សខ្លះ បង្កើតការសង្ស័យដោយខ្លួនឯង ។ គេឆ្ងល់ចំពោះព្រះជាម្ចាស់ និង ផ្លូវរបស់ព្រះអង្គ ។ សួរសិស្សអោយចែកចាយនូវឧទាហរណ៍ផ្ទាល់ខ្លួនអំពីរឿងនេះ ។

មនុស្សខ្លះនឹងនិយាយថាការសង្ស័យទាំងនេះប្រាកដមកពីសាតាំងហើយ ។ ប្រហែលមានពេលខ្លះត្រឹមត្រូវ ។ ប៉ុន្តែមានពេលខ្លះមនុស្សបានបដិសេធន៍ជឿព្រះ និង ព្រះបន្ទូលរបស់ទ្រង់ដោយខ្លួនឯង ។ គេធ្វើការសំរេចចិត្តដោយខ្លួនឯង ។ ការនេះចេញពីរឿងរបស់ជនជាតិអ៊ីស្រាអែល បន្ទាប់ពីពួកគេចាកចេញពីប្រទេសអេស៊ីប ហើយកំពុងតែធ្វើដំណើរទៅកាន់ទឹកដីសន្យា ។

**<u>ទំនុកតម្កើង ៩៥:៨-១០</u>**

(៨) មិនត្រូវមានចិត្តរឹងរូសដូចកាលបះបោរនៅមេរីបា ដូចថ្ងៃល្បងលនៅម៉ាសាក្នុងវាលរហោស្ថាននោះឡើយ

(៩)គឺបុព្វបុរសរបស់អ្នករាល់គ្នាបានល្បងលយើង គេសាកមើលយើង ទោះបីគេបានឃើញកិច្ចការដែលយើងធ្វើក៏ដោយ។ (១០) ក្នុងអំឡុងពេលសែសិបឆ្នាំ មនុស្សនៅជំនាន់នោះបានធ្វើអោយយើងឆ្អែតយ៉ាងខ្លាំង ហើយយើងពោលថាៈ ពួកនេះជាប្រជាជនដែលមានចិត្តវង្វេង គេពុំស្គាល់មាគ៌ារបស់យើងឡើយ។

## ១១. តើព្រះជាម្ចាស់ដាក់ការសង្ស័យក្នុងចិត្តគំនិតរបស់អ្នកទេ? (៥-១៥នាទី)

មានគ្រីស្ទបរិស័ទជាច្រើនពិបាកនឹងជឿថា ព្រះជាម្ចាស់អាចដាក់ការសង្ស័យក្នុងចិត្តគំនិតរបស់គេ ។ ការបង្ហាញខាងព្រះគម្ពីរនៃអ្នកមានវ័យក្មេង ដែលបានមករកព្រះយេស៊ូ ដែលហាក់ដូចជាត្រូវទៅនឹងចំនុចនេះ ។ ទោះបីជាព្រះគម្ពីរមិនបានបង្ហាញយ៉ាងច្បាស់ថា នេះជារឿងនៃការសង្ស័យក៏ដោយ ។

នៅក្នុងសៀវភៅណែនាំរបស់សិស្ស ពិភាក្សារឿងនេះ និង ផ្តល់ការពន្យល់ ពីរបៀបដែលព្រះជាម្ចាស់អាចនាំយកការសង្ស័យ មកក្នុងចិត្តរបស់មនុស្ស។ ចូរមើលទំព័រទី ៣៩-៤០ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។

ជារឿយៗព្រះយេស៊ូបានមានព្រះបន្ទូលយ៉ាងខ្លាំងទៅលើពួកមេដឹកនាំសាសនា កាលពីជំនាន់ព្រះអង្គគង់នៅលើផែនដីនៅឡើយ។ វាហាក់ដូចជាត្រឹមត្រូវដែលគិតថា ផលប្រយោជន៍នៃព្រះបន្ទូលដ៏ខ្លាំងរបស់ទ្រង់គឺដើម្បីនាំនូវការសង្ស័យនៅក្នុងចិត្តគំនិតរបស់ពួកគេ ។ ព្រះអង្គព្យាយាមធ្វើអោយគេភ្ញាក់ខ្លួនពីការបោកប្រាស់របស់ពួកគេ។ ព្រះយេស៊ូបាន បង្ហាញផ្លូវដែលដាច់គ្នាស្រឡះក្នុងការរស់រវែងពីវិញ្ញាណពិត ។ ខ្ញុំជឿជាក់ថាទ្រង់បានសង្ឃឹមថា ពួកគេនឹងចាប់ផ្តើម មានការសង្ស័យអំពីផ្លូវគំនិតសព្វថ្ងៃរបស់ពួកគេ ។

មនុស្សខ្លះមានអារម្មណ៍ថា អ្វីដែលព្រះយេស៊ូកំពុងតែធ្វើនេះហៅថា " ជាការដាស់តឿនរបស់ព្រះវិញ្ញាណបរិសុទ្ធ " ។ ពិតណាស់ ព្រះអង្គដាស់តឿនយើងចំពោះបាបរបស់យើង។ ចូរអ្នកបង្ហាញអោយច្បាស់ពីប្រភេទនៃការសង្ស័យបែបណា ដែលព្រះជាម្ចាស់នឹងដាក់ទៅក្នុងចិត្តរបស់មនុស្ស ។ ព្រះជាម្ចាស់មិនដាក់នូវការសង្ស័យអំពីវត្តមានរបស់ទ្រង់ផ្ទាល់ក្នុងគំនិតរបស់ពួកគេទេ ។ ទ្រង់អាចនឹងនាំយកការសង្ស័យថាតើអ្នកប្រាកដជាគ្រីស្ទបរិស័ទឬអត់ ។ វាហាក់ដូចជាព្រះមិនដាក់នូវការសង្ស័យនេះ ទៅលើគ្រីស្ទបរិស័ទដែលមានចិត្តស្មោះឡើយ ។ ប៉ុន្តែបើសិនជាមនុស្សម្នាក់បោកប្រាស់ខ្លួនឯងថាជា " គ្រីស្ទបរិស័ទដ៏ល្អ " ហើយមិនមានបញ្ហាអ្វីសោះ តែទ្រង់ដឹងថាគាត់កុហក នោះព្រះអង្គប្រាកដជាធ្វើអោយគេមានការសង្ស័យជាក់ជាមិនខាន ។ បើសិនជាព្រះជាម្ចាស់ឃើញថា មនុស្សនោះដើរផ្លូវខុសដែលនាំមករកការបំផ្លាញខាងព្រលឹងវិញ្ញាណ ទ្រង់នឹងព្យាយាមជួយអោយមនុស្សនោះដឹងពីផ្លូវខុស ។

ចូរប្រយត្ន័កុំធ្វើអោយចូលជ្រៅទៅក្នុងការពិភាក្សាខាងសាសនាវិទ្យាខ្លាំងពេកនៅចំនុចនេះ ។ ចំនុចសំខាន់ត្រូវដឹង នោះគឺសាតាំងមិនមែនប្រភពនៃការសង្ស័យទាំងអស់ដែលគ្របបាំងផ្លូវរបស់អ្នកទេ ។ នៅពេលដែលយើងរកមើលផ្លូវដើម្បី បំបាត់នូវការសង្ស័យ យើងត្រូវសំគាល់ថា អ្នកណាដែលបង្កអោយមានការសង្ស័យមកកាន់ចិត្តរបស់យើង ។ វានឹងមានប្រយោជន៍ក្នុងការរកដំណោះស្រាយបំបាត់ចោលនូវការសង្ស័យ ។

## ១២. បញ្ហាបីប្រភេទដែលបង្កអោយមានការសង្ស័យ (១០-១៥នាទី)

ឥឡូវយើងចង់មើលអោយជ្រៅទៅលើបញ្ហាដែលធ្វើអោយមានការសង្ស័យ ។ បញ្ហានេះអាចដាក់ជាបីក្រុម ។

កង្វះចំណេះដឹង

កង្វះការយល់ដឹង

កង្វះការប្រព្រឹត្ត

នៅទំព័រទី ៤១-៤២ ក្នុងសៀវភៅណែនាំរបស់សិស្ស នឹងផ្តល់នូវពត៌មានបន្ថែមក្នុងក្រុមទាំងបីនេះ ។ ចូរអានបញ្ជី បញ្ហាដែលបានរៀបរាប់ពីវគ្គសិក្សាមុន ហើយពិភាក្សាពីរបៀបនៃការសង្ស័យដែលបង្កឡើងដោយកង្វះមួយក្នុងចំណោម កង្វះទាំងបីនេះ ។ ចំពោះបញ្ហាខ្លះអាចទាក់ទងទៅនឹងកង្វះទាំងបី ។ អោយឧទាហរណ៍ពីអ្នកមានទ្រព្យក្មេងនៅក្នុងព្រះគម្ពីរ ។ ការសង្ស័យរបស់គាត់កើតឡើងដោយសារការកង្វះនៃចំណេះដឹង ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីព្រះយេស៊ូផ្តល់ដំណោះស្រាយគាត់បានយល់យ៉ាងច្បាស់តែគាត់បានជ្រើសរើសមិនធ្វើតាម ។

បញ្ហាសាមញ្ញមួយដែលបង្កអោយមានការសង្ស័យទាក់ទងទៅនឹងការល្បួង ។ ពេលដែលមនុស្សទទួលយកការល្បួង ដែលនាំអោយប្រព្រឹត្តអំពើបាប សាតាំងតែងតែនាំមកនូវកំហុស និង ការដាក់ទោសយ៉ាងច្រើន ។ ពេលនោះក៏ចាប់ផ្តើម មានការសង្ស័យ ។ បន្ទាប់ពីមនុស្សធ្វើបាប ការសង្ស័យកើតមានធំជាងអ្វីដែលបានកើតឡើង ពេលដែលគេគ្រាន់តែគិត អំពីការល្បួង ។

បើសិនជាសិស្សរបស់អ្នកអាចចាប់ផ្តើមគិតទំនាក់ទងទាំងបីក្រុមនេះ វានឹងជួយពួកគេនៅក្នុងវគ្គសិក្សាក្រោយទៀត នៅពេលដែលយើងពិភាក្សារកដំណោះស្រាយពីបញ្ហាដែលបង្កអោយមានការសង្ស័យ ។ បើសិនជាពួកគេជួបបញ្ហាតែមួយ ដែលត្រូវនឹងការកង្វះនៃចំណេះដឹង ត្រូវផ្តល់ពត៌មានត្រឹមត្រូវដែលអាចដោះស្រាយបញ្ហាបាន ។ ទោះជាយ៉ាងនេះក៏ដោយបើសិនជាវាទាក់ទងនឹងកង្វះការប្រព្រឹត ទោះជាមានពត៌មានច្រើនក៏ដោយក៏នឹងមិនផ្លាស់ប្តូរស្ថានភាពនេះដោយស្វ័យប្រវត្តបានដែរ ។

## ១៣. តើអ្នកអាចរកឃើញអ្វីកំពុងតែបង្កមន្ទិលសង្ស័យរបស់អ្នកដោយរបៀបណា? (៥-១០ នាទី)

នៅក្នុងសៀវភៅណែនាំរបស់សិស្សផ្តល់នូវគំរូនេះបួន ដែលស្តីពីរបៀបដែលអ្នកអាចរកឃើញអ្វីដែលបង្កអោយអ្នកមានការសង្ស័យ ។ សូមមើលទំព័រទី ៤៥-៤៦ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។ បើសិនជាអ្នកមានពេលនៅក្នុងម៉ោងរៀននេះ សូមមើលនូវគំនិតទាំងបួននេះ ។ នេះជាផ្នែកល្អមួយក្នុងការបំបាត់ចោលនូវការសង្ស័យរបស់អ្នក ។ បើសិនជាអ្នកចង់ឈ្នះការសង្ស័យរបស់អ្នក អ្នកត្រូវតែស្គាល់នូវអ្វីដែលបង្កអោយមានការសង្ស័យ ។

## ១៤. ដើរតួសំដែងមន្ទិលសង្ស័យរបស់យ៉ូសែប

រំលឹកដល់សិស្សថា គ្រីស្ទបរិស័ទជាញឹកញាប់នឹងជួបប្រទះនូវការសង្ស័យនៅក្នុងជីវិត ក៏ដូចជាពេលដែលពួកគេទើបក្លាយជាគ្រីស្ទបរិស័ទដំបូងដែរ ។ ជីវិតរបស់លោកយ៉ូសែបនៅក្នុងសម្ពន្ធមេត្រីចាស់បានផ្តល់នូវស្ថានភាពដ៏លំបាកជាច្រើនដែលធ្វើអោយគាត់ងាយស្រួលនឹងមានការសង្ស័យចំពោះព្រះជាម្ចាស់ ។

ចូរពិពណ៌នាសង្ខេបពីព្រឹត្តិការណ៍នៅក្នុងជីវិតរបស់លោកយ៉ូសែប និង ពន្យល់ថាហេតុអ្វីបានជាលោកប៉ូទីផា ដាក់គាត់នៅក្នុងគុក ។ (សូមមើល កំណើតពិភពលោក ៣៧ និង ៣៩) ។ អោយសិស្សពីរនាក់ធ្វើការសំដែងដូចខាងក្រោម ។

<u>**ស្ថានភាព :**</u>

លោកយ៉ូសែបត្រូវបានចោទប្រកាន់យ៉ាងអយុត្តិធម៌ ហើយត្រូវបោះទៅក្នុងគុក ។ វគ្គសំដែងនៃពិភាក្សារហូតទាល់តែ កើតឡើងនៅក្នុងគំនិតរបស់លោកយ៉ូសែប អំឡុងជាច្រើនឆ្នាំដែលលោកនៅក្នុងគុក ។ សិស្សម្នាក់លេងវគ្គនៃការសង្ស័យ របស់លោកយ៉ូសែបលើខ្លួនឯង ហើយម្នាក់ទៀត ការទុកចិត្តរបស់លោកយ៉ូសែបលើខ្លួនឯង (ទៅកាន់ព្រះ) ។ ការសំដែងអាចចាប់ផ្តើមលេងដូចនេះ:

**ការសង្ស័យខ្លួនឯង:** ព្រះជាម្ចាស់អើយ! ទូលបង្គំដើរតាមព្រះអង្គ។ តើផ្លូវនេះឬដែលទ្រង់ផ្តល់ជារង្វាន់ដល់ទូលបង្គំ? ទូលបង្គំមិនយល់ទេ ។

**ការទុកចិត្តខ្លួនឯង :** ទេ! ទូលបង្គំមិនយល់ទេ ប៉ុន្តែទូលបង្គំចាំហើយឮ អំពីរបៀបដែលទ្រង់បានដឹកនាំជីវិតលោក អាប្រាហាំឆ្លងកាត់នូវការលំបាក ។ ច្បាស់ណាស់ថាព្រះអង្គនឹងធ្វើដូចនេះមកកាន់ទូលបង្គំដែរ ។

## ១៥. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥ នាទី)

សង្កត់ធ្ងន់ទៅការអនុវត្តន៍ផ្ទាល់ខ្លួនដោយអោយសិស្សនិមួយៗសំគាល់ពីបញ្ហានៅក្នុងជីវិតរបស់គេដែលអាចបង្កអោយ គេមានការសង្ស័យ ។ ពួកគេអាចកត់ត្រានូវបញ្ហាដែលបង្កអោយគេមានការអារម្មណ៍ថាស្ថិតនៅឆ្ងាយពីព្រះជាម្ចាស់ ។ បើសិនជាអ្នកមានពេល សុំអោយសិស្សរបស់អ្នកដាក់បញ្ហារបស់គេទៅក្នុងក្រុមទាំងបី ។

កង្វះចំណេះដឹង

កង្វះការយល់ដឹង

កង្វះការប្រព្រឹត្ត

## ១៦. កិច្ចការដែលត្រូវធ្វើ

១. នៅក្នុងចុងម៉ោងរៀន ផ្តល់សំនួរខ្លីៗពី យ៉ាកុប ១:៥-៦។

២. ដាក់ពិន្ទុគំរោង ទី៩, ១០ និង ទី ១១ នៅថ្ងៃនេះ ឬនៅចុងបញ្ចប់នៃម៉ោងរៀនវគ្គលើកក្រោយ។

៣. សុំអោយសិស្សអានទំព័រ ៣៧-៤៦ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ដើម្បីទទួលបាននូវរឿងដែលយើងបានពិភាក្សានៅថ្ងៃនេះ និង រៀបចំសំរាប់វគ្គរៀនបន្ទាប់ទៀត ។

## ១៧. ការវាយតំលៃនិងគំនិតរបស់ខ្ញុំសំរាប់ការបង្រៀនមេរៀននេះនៅពេលក្រោយ

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក ។

**អោយពិន្ទុចំពោះការសង្ស័យនិងសំនួររបស់ខ្ញុំ**

សកម្មភាពនេះត្រូវបានរៀបឡើងដើម្បីប្រើ ដូចសកម្មភាពមេរៀនដែលនាំអោយមានការពិភាក្សា សំរាប់មេរៀនទី៧ ស្តីពីការសង្ស័យ ។ សូមធ្វើការថតចំលងហើយចែកជូនដល់សិស្សម្នាក់ៗ ។ សំរាប់ពតិមានបន្ថែមក្នុងការប្រើសំនួរខ្លីៗនេះ សូមមើលសកម្មភាពទី ៥ នៅលើគំរោងមេរៀនទី៧ ទំព័រ ទី ៧៣។

**អោយពិន្ទុចំពោះការសង្ស័យនិងសំនួររបស់ខ្ញុំ**

នេះគឺជាក្រដាសស្ទាបស្ទង់ដើម្បីវាយតម្លៃខ្លួនឯង ។ សំនួរនិមួយៗសួរសំរាប់ចំលើយផ្ទាល់ខ្លួន ។ គឺគ្មានចំលើយ " ខុស ឬ ត្រូវ " ទេ ។ អ្នកមិនចំបាច់អោយត្រឡប់ទៅគ្រូរបស់អ្នកវិញទេ ។

សូមអានទូវប្រយោគនិមួយៗហើយបន្ទាប់មកវាយតម្លៃខ្លួនឯងជាមួយប្រយោគនេះ ។ " នៅក្នុងជីវិតរបស់ខ្ញុំ ធ្លាប់មាន ការសង្ស័យ សំនួរ ឬភាពមិនច្បាស់លាស់នៅក្នុងកន្លែងទាំងនេះឬទេ "។
សូមគូសនៅក្នុងប្រអប់ដែលនិយាយចំបទពិសោធន៏របស់អ្នក ។

| | ច្រើន | ខ្លះៗ | ស្ទើរតែគ្មាន |
|---|---|---|---|
| ១. ពិតជាមានព្រះជាម្ចាស់ | | | |
| ២. ព្រះយេស៊ូជាព្រះ | | | |
| ៣. ស្ថាននរកមានពិត | | | |
| ៤. ខ្ញុំនឹងទៅស្ថានសួគ៌ពេលខ្ញុំស្លាប់ | | | |
| ៥. នៅក្នុងក្រុមជំនុំរបស់យើងមានចំលើយទាំងអស់ដែលទាក់ទងនឹងសំនួរខាងព្រលឹងវិញ្ញាណ និង បញ្ហារបស់ខ្ញុំ | | | |
| ៦. គ្រីស្តសាសនាពិតជាជួយដោះស្រាយនៅតំរូវការរបស់ក្មេងជំទង់ និង មនុស្សពេញវ័យ សព្វថ្ងៃនេះយ៉ាងប្រាកដ ។ | | | |
| ៧. ព្រះជាម្ចាស់ប្រាកដជាដឹងថា អ្នកណាជាមនុស្សល្អសំរាប់ខ្ញុំ ដើម្បីរៀការជាមួយហើយទ្រង់នឹងបង្ហាញពីមនុស្សម្នាក់នោះ។ | | | |
| ៨. ខ្ញុំជាគ្រីស្តបរិស័ទដ៏ពិតម្នាក់ | | | |
| ៩. ខ្ញុំអាចស្តាប់បង្គាប់វិន័យរបស់ព្រះជាម្ចាស់ និង នៅតែមានជ័យជំនះនៅក្នុងជីវិត | | | |
| ១០. ព្រះជាម្ចាស់ពិតជាយកចិត្តទុកដាក់ជាមួយខ្ញុំហើយនឹងតំរូវការរបស់ខ្ញុំ | | | |
| ១១. ព្រះជាម្ចាស់នឹងឆ្លើយតបចំពោះការអធិស្ឋានរបស់ខ្ញុំ | | | |
| ១២. អ្នកផ្សេងទៀតនៅក្នុងក្រុមជំនុំរបស់យើងជាគ្រីស្តបរិស័ទពិត | | | |
| ១៣. ព្រះជាម្ចាស់ទ្រង់សព្វព្រះទ័យជាមួយផ្លូវដែលខ្ញុំរស់នៅសព្វថ្ងៃ | | | |

# មេរៀនទី ៨

# ការបំបាត់ចោលមន្ទិលសង្ស័យ

## ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំអាចបំបាត់ចោលមន្ទិលសង្ស័យរបស់ខ្ញុំអំពីការក្លាយជាគ្រីស្តបរិស័ទ នៅពេលដែលខ្ញុំ បង្កើតគំរូសំរាប់យកឈ្នះលើបញ្ហាដែលបណ្តាលអោយមានមន្ទិលសង្ស័យទាំងនេះ ។

## ២. ខគម្ពីរសំខាន់ : ភីលីព ១ : ៦

ខ្ញុំជឿជាក់ថាព្រះជាម្ចាស់ដែលបានចាប់ផ្តើមកិច្ចការល្អនៅក្នុងអ្នកនឹងបន្តធ្វើការនៅក្នុងអ្នករហូតទាល់តែព្រះគ្រីស្តយាងត្រឡប់មកវិញ។

## ៣. យោងតាមឯកសាររបស់សិស្ស

នៅទំព័រទី ៤០ ដល់ ៤៧ នៅក្នុសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។

## ៤. ការរៀបចំរបស់គ្រូ

រៀបចំចំណាយពេលវេលាមេរៀននៅក្នុងថ្នាក់ ថ្ងៃនេះអោយបានច្រើនទៅលើការពិភាក្សាខ្លះៗនៃគំរូរបស់ព្រះគម្ពីរសំរាប់មនុស្សដែលមានមន្ទិលសង្ស័យ ។ កុំមានអារម្មណ៍ថា បង្ខិតបង្ខំក្នុងការពិភាក្សាករណីលំអិតទាំងបីនេះ ។ អ្នកអាចចំណាយពេលវេលា ដ៏ច្រើនរបស់អ្នកនៅលើរឿងរបស់លោក ថូម៉ាស និង និយាយសង្ខេបអំពីរឿងអ្នកដទៃទៀត ឬក៏ ប្រើរឿងនោះនៅក្នុងម៉ោងសិក្សាបន្ទាប់ ។ ករណីទាំងបីដែលត្រូវប្រើនៅក្នុងមេរៀននេះគឺ :

- លោក ថូម៉ាសមានមន្ទិលសង្ស័យអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ យ៉ូហាន ២០: ១៩-៣១
- មន្ទិលសង្ស័យរបស់ លោក ពេត្រុសគឺពេលដែលគាត់ដើរលើទឹក ម៉ាថាយ ១៤ : ២២-៣៣
- លោក យ៉ូសែបមានមន្ទិលសង្ស័យអំពីការពន្យល់របស់នាងម៉ារីពេលនាងមានគភ៌ម៉ាថាយ ១ : ១៨-២១

## ៥. ការចាប់ផ្តើមមេរៀន : ករណីសិក្សា (៥-១០ នាទី)

លោក ធីមបានក្លាយជាគ្រីស្តបរិស័ទអស់រយៈពេលជិតពីរខែមកហើយ ។ គាត់ក្លាយជាគ្រីស្តបរិស័ទដោយសារលោក ប៊ិត ជាមិត្ត ចាស់កាលនៅរៀនជាមួយគ្នា ។ លោក ធីម និង លោក ប៊ិត ចូលរួមប្រកបជាមួយគ្នានៅក្នុងក្រុមជំនុំដូចគ្នា ។ លោក ប៊ិតពេញចិត្តនឹង ក្រុមជំនុំនេះណាស់ ហើយរំភើបចិត្តអំពីការរីកចំរើនក្នុងជីវិតជាគ្រីស្តបរិស័ទរបស់គាត់ ។

ប៉ុន្តែលោក ធីមវិញមិនរំភើបចិត្តក្នុង ជីវិតជាគ្រីស្ទបរិស័ទដូចកាលពី ពីរខែមុនសោះ ។ ការរៀនព្រះគម្ពីរ និង ការអធិស្ឋានហាក់ដូចជាស៊ីពេលច្រើនណាស់ និង អំពើចាស់ដែល គាត់បានបោះបង់ចោលពេលគាត់ថ្វាយជីវិតរបស់គាត់ទៅព្រះគ្រីស្ទនៅតែកើតមានឡើងមកទៀត ។ ចំនុចនេះធ្វើអោយលោក ធីម មានមន្ទិលសង្ស័យថា គាត់ជាគ្រីស្ទបរិស័ទពិតប្រាកដឬអត់ ។ គាត់មិនបានប្រាប់ក្រុមគ្រួសារ ឬ មិត្តភក្តិរបស់គាត់អំពីការផ្លាស់ប្តូរជីវិតរបស់គាត់ទេ ។គាត់ជឿជាក់ថាការលាក់បាំងរបស់គាត់គ្មានអ្នកណាដឹងទេ ពីព្រោះគ្មាននរណាម្នាក់នៅក្នុងផ្ទះរបស់គាត់និយាយប្រាប់គាត់ អំពីការផ្លាស់ប្តូរដែលពួកគេបានឃើញនៅក្នុងជីវិតរបស់គាត់សោះ ។

ការទាំងអស់នេះធ្វើ អោយលោក ធីម បាក់ទឹកចិត្ត ។ គ្រីស្ទបរិស័ទដទៃទៀតទាំងអស់នៅក្នុងព្រះវិហារដឹងអំពីការស៊ូប្តូររបស់គាត់ចំពោះព្រះគ្រីស្ទ។ គាត់មានអារម្មណ៍ថា អន់ជាងពួកគេ ។ គាត់មិនសូវចេះដឹងព្រះគម្ពីរ មិនអាចអធិស្ឋាន និង មិនអាចនិយាយអំពីព្រះជាម្ចាស់បានល្អដូចពួកគេទេ។ លោក ធីម មានមន្ទិលសង្ស័យយ៉ាងខ្លាំងថា តើគាត់ជាគ្រីស្ទបរិស័ទឬអត់?

**<u>សំនួរពិភាក្សា</u>**

១. តើអ្នកគិតថា លោក ធីមគួរតែពិភាក្សាជាមួយ ប៊ិត ដែរឬទេ?
២. តើលោក ប៊ិត គួរនិយាយយ៉ាងដូចម្តេច ប្រសិនបើលោក ធីមមកប្រាប់គាត់អំពីមន្ទិលសង្ស័យនេះ?
៣. តើអ្នកគិតថាអ្វីជាការបង្កយ៉ាងសំខាន់នៃមន្ទិលសង្ស័យរបស់ធីម?
៤. តើអ្នកគិតថា មានរឿងអ្វីនឹងកើតឡើង ប្រសិនបើលោកធីមមិនបានដឹងពីដើមហេតុនៃមន្ទិលសង្ស័យរបស់គាត់ហើយព្យាយាមយកឈ្នះវានោះ?

អ្នកអាចធ្វើការថតចំលងនៅករណីនេះជាមួយនឹងសំនួរពិភាក្សាទាំងបួន ។ សូមចែកជូនកិច្ចការនេះដល់សិស្សពេលពួកគេចូលរៀនដំបូង ។ សូមអោយគេសរសេរនូវចំលើយរបស់ពួកគេ មុនពេលដែលអ្នកចាប់ផ្តើមពិភាក្សាអំពីករណីសិក្សានេះ ។

## ៦. រំលឹកមេរៀនខ្លីៗពីម៉ោងសិក្សាមុន (៥នាទី)

សូមរំលឹកយ៉ាងខ្លីអំពីចំនុចគន្លឹះខ្លះៗដែលបានពិភាក្សាកាលពីម៉ោងរៀនលើកមុន ។

- តើមន្ទិលសង្ស័យជាអ្វី?
- តើអ្នកណាយកមន្ទិលសង្ស័យមកដាក់ចូលក្នុងគំនិតរបស់អ្នក?
- មន្ទិលសង្ស័យមិនមែនជាបញ្ហាទេ ប៉ុន្តែជាសញ្ញា ឬជាលទ្ធផលនៃបញ្ហា

បញ្ហាបីប្រភេទដែលអាចបណ្ដាលអោយមានមន្ទិលសង្ស័យ

- ខ្វះចំណេះដឹង
- ខ្វះការយល់ដឹង
- បញ្ហាខាងការប្រព្រឹត្ត

យើងនឹងប្រើគន្លឹះនៃសេចក្ដីពិតទាំងនេះដើម្បីធ្វើការវាយតំលៃករណីសិក្សាក្នុងព្រះគម្ពីរដែលយើងនឹងពិភាក្សានៅម៉ោង រៀនថ្ងៃនេះ ។

## ៧. ណែនាំករណីរបស់លោក ថូម៉ាសនៅក្នុងព្រះគម្ពីរ (៥-១០នាទី)

សូមអោយសិស្សអានខ្លាំងៗពីរឿងមន្ទិលសង្ស័យរបស់លោក ថូម៉ាស នៅក្នុងគម្ពីរ យ៉ូហាន ២០ : ១៩-៣០ ។ មុនពេលដែលអ្នក អោយគេអានរឿងនេះ សូមប្រាប់គេអោយសង្កេតពីរបៀបដែលលោក ថូម៉ាសដោះស្រាយមន្ទិលសង្ស័យរបស់គាត់ ។

បន្ទាប់ពីពួកគេអាននូវគម្ពីរ សូមសួរសំនួរនេះ ។

- តើអ្វីដែលអ្នកចាប់អារម្មណ៍អំពីព្រឹត្តិការណ៍នេះ?

សូមអោយសិស្សចែកចាយអំពីចំណាប់អារម្មណ៍ក្នុងរឿងនេះ ។ តើគេអាចសំគាល់អំពីលោក ថូម៉ាស និង មន្ទិលសង្ស័យរបស់គាត់បាន ឬទេ?

## ៨. តើអ្វីដែលបង្កអោយលោក ថូម៉ាសមានមន្ទិលសង្ស័យ? (៥-១០នាទី)

សូមសួរសិស្សអ្វីដែលពួកគេគិត ដែលធ្វើអោយលោក ថូម៉ាសមានមន្ទិលសង្ស័យ ។ សូមព្យាយាមអោយការពិភាក្សាទូលាយអំពីផ្លូវ ផ្សេងទៀតនៅក្នុងចំនុចនេះ ។ សូមអោយសិស្សខិតខំរិះគិតអោយបានស៊ីជំរៅ ។ លោក ថូម៉ាសនិយាយថា ប្រសិនបើគាត់មិនបាន ឃើញព្រះយេស៊ូដោយផ្ទាល់ភ្នែកទេ គាត់នៅតែសង្ស័យអំពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ ប៉ុន្តែ តើនោះជាបញ្ហាពិតប្រាកដ ឬទេ? តើលោក ថូម៉ាសមានបញ្ហាដែលជ្រៅជាងនេះឬទេ? ខ្ញុំគិតថាលោក ថូម៉ាសបានបង្ហាញអំពីបញ្ហាដែលមិនទុកចិត្តមនុស្សដទៃ ហើយនឹងអ្វីដែលគេនិយាយ ។

សូមសួរសិស្សរបស់អ្នក ប្រភេទបញ្ហាណាមួយដែលពួកគេគិតថា លោក ថូម៉ាសមាន ។ តើវាជាការ :

- ខ្វះចំណេះដឹង?
- ខ្វះការយល់ដឹង?
- ខ្វះការប្រព្រឹត្ត?

សូមអោយគេពន្យល់ថាតើមូលហេតុអ្វីដែលពួកគេគិតថា

វាជាប្រភេទបញ្ហានោះនៅក្នុងជីវិតរបស់គាត់ ។ ខ្ញុំគិតថា ជាបញ្ហាចំណេះដឹងជាចំបង ។ គាត់ត្រូវការចំណេះ

ដឹងដោយឡែកមួយ ដើម្បីដកយកមន្ទិលសង្ស័យរបស់គាត់ចេញ - ទីមួយគឺចំណេះដឹង ។ ពេលដែលគាត់ឃើញស្នាមដែកគោលនៅលើព្រះហស្ថរបស់ព្រះយេស៊ូហើយឃើញស្នាមនៅឆ្អឹងជំនីរបស់ទ្រង់បន្ទាប់មកទើបគាត់ជឿ ។

ចំនុចដែលជ្រៅជាងនេះនៅក្នុងបញ្ហានោះគឺខ្វះការទុកចិត្ត ។នេះគឺជាបញ្ហានៃការប្រព្រឹត្តច្រើនជាង ។ អ្នកបង្ហាញថាអ្នកទុកចិត្តដល់អ្នក ណាម្នាក់ដោយសារការប្រព្រឹត្តរបស់អ្នក ។ លោក ថូម៉ាសគួរតែជឿតាមពតិមានដែលសាវ៏កដទៃទៀតបានឃើញព្រះយេស៊ូរួចហើយ ។

## ៩. តើដំណោះស្រាយនៃមន្ទិលសង្ស័យរបស់លោក ថូម៉ាសជាអ្វី? (១០-១៥នាទី)

សូមសួរសិស្សឱ្យសំគាល់អ្វីដែលលោកថូម៉ាសបាននិយាយ ដែលអាចបំបាត់ចោលនូវមន្ទិលសង្ស័យរបស់គាត់ ។ បន្ទាប់ពីអ្នកបានពិភាក្សាអំពីដំណោះស្រាយ សូមយកពេលដើម្បីណែនាំអំពីគំរោងជំហានទាំង ៥ ពីរបៀបបំបាត់ចោលមន្ទិលសង្ស័យ ។ សូមមើលទំព័រ ទី៤៦-៤៧នៅ លើសៀវភៅណែនាំរបស់សិស្ស ។

បន្ទាប់ពីបានរៀនអំពីជំហាន ទាំង ៥ នៃការបំបាត់ចោលមន្ទិលសង្ស័យរួចហើយ សូមវាយតំលៃសកម្មភាព របស់លោក ថូម៉ាសដើម្បីឱ្យឃើញពីជំហានដែលគាត់ប្រើ ។ វាច្បាស់ណាស់ថា គាត់ប្រើជំហានទី ១ ។ នៅក្នុងព្រះគម្ពីរមិនបាន និយាយថា គាត់ប្រើជំហាន ទី ២/៣ឬក៏ ទី ៤ នោះទេ ។ គាត់មានគំរោងការជាក់ច្បាស់សំរាប់បំបាត់ចោលមន្ទិលសង្ស័យរបស់គាត់ (ជំហាន ទី៥) តើនេះគឺជាផ្លូវរបស់ព្រះជាម្ចាស់ក្នុងការបំបាត់ចោលនៅមន្ទិលសង្ស័យរបស់គាត់ឬ? យើងនឹងឃើញចំលើយទៅនឹងបញ្ហានេះពេលដែលយើងពិភាក្សារឿងនេះដែលបានលើកឡើងនៅសកម្មភាពគំរោងមេរៀន ទី ១០ និង ១១ ។

វាជាការល្អ ត្រូវចាំថាលោក ថូម៉ាសកំពុងតែរកមើលព្រះយេស៊ូដើម្បីជាជំនួយក្នុងការដោះស្រាយការសង្ស័យរបស់គាត់ ។ យើងត្រូវធ្វើដូច្នេះដែរ ។ សូមត្រឡប់ទៅបញ្ហាបីប្រភេទដែលបង្កអោយមានមន្ទិលសង្ស័យ. ដំណោះស្រាយរបស់លោក ថូម៉ាសគឺជាការល្អមួយ ក្នុងការទទួលបាននូវពតិមានដែលគាត់ចង់បាន ។ ទោះបីជាយ៉ាងណា ក៏ដោយក៏ដំណោះស្រាយនេះមិនអាចដោះស្រាយបញ្ហាដ៏ជ្រៅ ក្នុងការទុកចិត្តមនុស្សដោយស្វ័យប្រវត្តិបានដែរ ។

លោក ថូម៉ាសមិនបានទទួលស្គាល់ថា គាត់មានបញ្ហាក្នុងការទុកចិត្តមនុស្សដទៃទេ ។ បើសិនជាគាត់បដិសេធន៏ក្នុងការទទួល ស្គាល់ថា គាត់មិនមានបញ្ហានេះ អ្នកអាចដឹងច្បាស់ថាគាត់នឹងមានបញ្ហានេះទៅអនាគតក្នុងការទុកចិត្តអ្នកដទៃ ។ សូមពិភាក្សាថា ការផ្លាស់ប្តូរប្រភេទណាខ្លះ ដែលលោក ថូម៉ាសគួរមានបើសិនជាគាត់ចង់អភិវឌ្ឍខ្លួនគាត់ដើម្បីមានការទុកចិត្តទៅលើគ្រីស្ទបរិស័ទដទៃ ទៀតកាន់តែច្រើន ។ តើដំណោះស្រាយនៃមន្ទិលសង្ស័យរបស់លោក ថូម៉ាសជាអ្វី?

## ១០. តើព្រះយេស៊ូជួយលោក ថូម៉ាសដើម្បីបំបាត់ចោលមន្ទិលសង្ស័យរបស់គាត់ដោយរបៀបណា? (៥-១០នាទី)

សូមសួរសិស្សដើម្បីពិភាក្សានៅចំលើយរបស់ពួកគេចំពោះសំនួរទាំងនេះ ។ អោយពួកគេយកចំលើយរបស់គេពីក្នុងព្រះគម្ពីរទៅតាម ការដែលអាចធ្វើទៅបាន ។

១. តើព្រះយេស៊ូជួយលោក ថូម៉ាសអោយលះបង់មន្ទិលសង្ស័យរបស់គាត់ដោយរបៀបណា?

២. តើព្រះយេស៊ូយកតាមគំរោងការរបស់លោក ថូម៉ាសសំរាប់លះបង់មន្ទិលសង្ស័យរបស់គាត់ឬទេ?

៣. តើលោក ថូម៉ាសមានប្រតិកម្មជាមួយព្រះយេស៊ូដោយរបៀបណា?

៤. តើប្រតិកម្មរបស់លោក ថូម៉ាសប្រាប់យើងអំពីរបៀបស្មោះត្រង់អ្វីខ្លះក្នុងការលះបង់មន្ទិលសង្ស័យរបស់គាត់ ?

លោកថូម៉ាសគឺជាមនុស្សមុនដំបូងគេក្នុងសម្ពន្ធមេត្រីថ្មី ដែលហៅព្រះយេស៊ូចំៗថា" ព្រះជាម្ចាស់ " ។ លោក ថូម៉ាសបានហៅទ្រង់ដោយផ្ទាល់ថា " ព្រះអង្គពិតជាព្រះអង្គម្ចាស់និង ជាព្រះរបស់ទូលបង្គំមែន " ។ គាត់មិនមានការរេរាក្នុងការបំរើព្រះជាម្ចាស់ឬអត់នោះទេ ។ មន្ទិលសង្ស័យរបស់គាត់គឺនៅលើថាតើព្រះគ្រីស្ទមានព្រះជន្មឬអត់ ។

## ១១. តើព្រះយេស៊ូមានព្រះបន្ទូលអំពីអ្វីដែលបង្កអោយលោក ថូម៉ាសមានមន្ទិលសង្ស័យ? (៥-១០នាទី)

យើងឃើញថាព្រះយេស៊ូមានឆន្ទះចង់ជួយ លោក ថូម៉ាសដើម្បីដោះស្រាយមន្ទិលសង្ស័យរបស់គាត់ ។ សូមយើងមើលអំពីអ្វីដែលព្រះ យេស៊ូមានព្រះបន្ទូលដែលបង្កអោយគាត់មានមន្ទិលសង្ស័យ។ សូមចាំថាព្រះយេស៊ូមិនមានការស្តីបន្ទោសធ្ងន់ធ្ងរចំពោះ លោក ថូម៉ាសអំពីមន្ទិលសង្ស័យរបស់គាត់ទេ ។ ប៉ុន្តែនៅក្នុង ខ ២៩ ព្រះយេស៊ូបានពិនិត្យទៅលើបញ្ហាធំនៅក្នុងជីវិតរបស់លោក ថូម៉ាស ។ ក្នុងវិធី វិជ្ជមានមួយដែលព្រះយេស៊ូបង្ហាញថា ជាវិធីល្អប្រសើរគឺជឿដោយមិនបានឃើញភស្តុតាងគ្រប់ពេល ។ ព្រះយេស៊ូមិនមានព្រះបន្ទូលថា លោក ថូម៉ាសមាន កំហុសក្នុងការទាមទារការមើលឃើញភស្តុតាងផ្ទាល់នោះទេ ។ ព្រះយេស៊ូមានព្រះហឫទ័យ និង មានបំណងរួចជាស្រេចផ្តល់នៅភស្តុតាងនោះ ។

ប៉ុន្តែជីវិតនៃជំនឿរបស់គ្រីស្ទបរិស័ម្នាក់ៗគឺជាជំនឿដែលមិនទាក់ទងជាមួយនឹងភស្តុតាងខាងសាច់ឈាមទេ ។ ចុះបើសព្វថ្ងៃនេះគ្រប់ គ្រីស្ទបរិស័ទទាមទារភស្តុតាងដូចគ្នាទៅនឹងថូម៉ាសទាមទារដែរនោះតើព្រះយេស៊ូនឹងបង្ហាញព្រះកាយរបស់ព្រះអង្គ ទៅគ្រប់គ្រីស្តបរិស័ទថ្មីគ្រប់គ្នា ដើម្បីអោយគេអាចឃើញពីស្លាក់ស្នាមនៅលើព្រះហស្តរបស់ទ្រង់ ហើយនិងកន្លែងដែលដាច់ដោយលំពែងនៅលើឆ្អឹងជំនីរបស់ទ្រង់ឬ ?

ជីវិតជាគ្រីស្ទបរិស័ទទាមទារអោយរៀនទុកចិត្តលើព្រះជាម្ចាស់ហើយទុកចិត្តលើគ្រីស្តបរិស័ទដទៃទៀត ។ ការខ្វះការទុកចិត្តរបស់ លោកថូម៉ាសជាបញ្ហាធំដែលព្រះយេស៊ូចង់អោយគាត់ដោះស្រាយ ។

វាជាការល្អដោយកត់សំគាល់ថា លោក ថូម៉ាសមិនមែនជាសាវ័ក តែមួយគត់ដែលមានមន្ទិលសង្ស័យអំពីអ្វីដែលអ្នកដទៃបានប្រាប់គាត់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូទេ ។

សូមមើល លូកា ២៤:៩-១២ គ្រប់សាវ័កទាំងអស់មុនដំបូងមានមន្ទិលសង្ស័យ ។ ទោះបីជាមានបុរសពីរនាក់មកពីភូមិ អេម៉ាអ៊ូស បាន ប្រាប់សាវ័ក ថាពួកគេបានជួបព្រះយេស៊ូក៏ដោយ ក៏ពួកសាវ័ក នៅតែមានមន្ទិលសង្ស័យដែរ ។ ទាល់តែព្រះយេស៊ូបានបង្ហាញព្រះកាយទ្រង់ក្នុងចំណោម ពួកគេហើយធ្វើអោយគេឈប់ខ្លាច ទើបគេជឿថា ទ្រង់មានព្រះជន្មរស់ ។ សូមមើល លូកា ២៤ : ៣៦-៤៣ ។

## ១២. ករណីសិក្សាអំពីព្រះយេស៊ូ និង លោក ពេត្រុសដើរនៅលើទឹក (៥_២០នាទី)

យើងនឹងប្រើសំនួរដូចគ្នាដែលយើងធ្លាប់ប្រើជាមួយនឹងលោកថូម៉ាសដើម្បីពិភាក្សាអំពីមន្ទិលសង្ស័យរបស់លោកពេត្រុស ។សូមអោយ សិស្សធ្វើការកត់សំគាល់ថាអ្វីជាបញ្ហាដែលបង្កអោយមានមន្ទិលសង្ស័យ, ផលវិបាកនៃមន្ទិលសង្ស័យ, ហើយរបៀបដែលព្រះយេស៊ូជួយលោក ពេត្រុសលះបង់មន្ទិលសង្ស័យរបស់គាត់ ។

១. សូមអាន ម៉ាថាយ ១៤ : ២២-៣៣

២. តើអ្វីដែលធ្វើអោយអ្នកចាប់អារម្មណ៍នៅក្នុងរឿងនេះ?

៣. តើអ្វីដែលបង្កអោយលោក ពេត្រុស មានមន្ទិលសង្ស័យ?

៤. តើអ្នកណាដែលនាំយកមន្ទិលសង្ស័យនេះចូលទៅក្នុងជីវិតរបស់គាត់?

៥. តើអ្វីជាលទ្ធផលនៃមន្ទិលសង្ស័យរបស់លោក ពេត្រុស?

- លទ្ធផលភ្លាមៗ
- តើអ្នកគិតយ៉ាងដូចម្តេចអំពីអារម្មណ៍របស់លោក ពេត្រុស បន្ទាប់ពីត្រឡប់មកលើទូកវិញ ហើយត្រូវជួបមុខ ជាមួយសាវ័កដទៃទៀតនោះ?

៦. តើលោក ពេត្រុស ធ្វើយ៉ាងដូចម្តេចដើម្បីលះបង់មន្ទិលសង្ស័យរបស់គាត់? (បញ្ហារបស់គាត់ដំបូងគឺដោះស្រាយនៅវិផលវិបាកនៃមន្ទិលសង្ស័យ-គាត់ជិតលង់ទឹក ទើបព្រះយេស៊ូបានជួយគាត់ ។ បន្ទាប់មកគាត់មានពេលវេលាដើម្បីដោះស្រាយមួយបញ្ហា ដែលបង្កអោយមានមន្ទិលសង្ស័យគាត់ -ការភ័យខ្លាច, គ្មានជំនឿ, និងខ្វះសេចក្តីជំនឿ ។

៧. តើព្រះយេស៊ូធ្វើអ្វីដើម្បីជួយលោក ពេត្រុស?

តើការនេះជួយលោក ពេត្រុសលះបង់មន្ទិលសង្ស័យ ឬការជួយនេះគ្រាន់តែដោះស្រាយជាមួយនឹងផលវិបាកនៃការសង្ស័យ របស់គាត់ ។ នៅក្នុងវិធីដូចគ្នានេះដែរ ដែលទ្រង់បាននិយាយទៅកាន់លោក ថូម៉ាស ព្រះយេស៊ូបានផ្តល់ដល់លោក ពេត្រុសនូវឱវាទយ៉ាងច្បាស់ម៉ត់ ចត់ ។ ទ្រង់មិនស្តីបន្ទោសអោយគាត់នោះទេគ្រាន់តែទ្រង់ប្រាប់ជាប្រយោគខ្លីមួយនៃវិធីដ៏ល្អដើម្បីប្រឈមមុខជាមួយនឹងស្ថានភាពដ៏លំបាក ។

## ១៣. មន្ទិលសង្ស័យរបស់លោក យ៉ូសែប អំពីការមានគភ៌របស់នាង ម៉ារី (៥-១៥នាទី)

ដំណើររឿងនៅក្នុង ម៉ាថាយ ១ : ១៨-២៥ មិនបានបង្ហាញចំៗថាលោក យ៉ូសែបមានមន្ទិលសង្ស័យ អំពីអ្វីដែលកើតឡើងចំពោះនាង ម៉ារីទេ ។ ប៉ុន្តែសកម្មភាពរបស់គាត់ហាក់ដូចជាបញ្ជាក់ច្បាស់ថា គាត់មិនជឿរឿងរបស់ ម៉ារី បើសិនជានាងបានប្រាប់គាត់ពីការដែលធ្វើអោយនាង មានផ្ទៃពោះ ។លោក យ៉ូសែបមានគំរោងមិនដោះស្រាយរឿងរៀបការ ឬក៏ ភ្ជាប់ពាក្យទេ ពីព្រោះគាត់ដឹងថា មិនមែនជាការទទួលខុសត្រូវរបស់គាត់ ចំពោះការមានគភ៌របស់នាងទេ ។

នៅក្នុងព្រះគម្ពីរមិននិយាយថា គាត់មានមន្ទិលសង្ស័យទេ ។ ប៉ុន្តែព្រះជាម្ចាស់បានផ្តល់ដំណោះស្រាយចំពោះការសង្ស័យរបស់គាត់ ហើយបានប្រាប់គាត់យ៉ាងច្បាស់អ្វីត្រូវធ្វើ ។ លោក យ៉ូសែបពិតជាអាចរកឃើញហេតុផលឆ្លងអំពីសុបិន្ត តែគាត់មិនបានធ្វើនោះទេ ។ នៅក្នុងស្ថានភាពដូចគ្នានេះដែរ មានទេវទូតបានបង្ហាញខ្លួនទៅលោក សាការី ប្រាប់ថា ប្រពន្ធរបស់គាត់នឹងបង្កើតបានកូនប្រុសមួយ ដែលគេអោយឈ្មោះថា យ៉ូហាន ។ សាការីបានសង្ស័យអំពីសំដីរបស់ទេវទូត ហើយបានផ្តល់ជា " សញ្ញា " ថាការនេះពិតជាមកពីព្រះជាម្ចាស់ ។ គាត់មិនអាចនិយាយរហូត ដល់ក្រោយពេលកំណើតរបស់លោក យ៉ូហានបាទីស្ត ។

លោក យ៉ូសែបមានបញ្ហាខាងចំណេះដឹង ។ បើសិនជានាងម៉ារីពន្យល់ពីហេតុដែលនាងមានផ្ទៃពោះ វាងាយស្រួលដឹងពីហេតុដែល លោកយ៉ូសែបពិបាកនឹងជឿនាង ។ ព្រះជាម្ចាស់បានផ្តល់ពតិមានដល់លោកយ៉ូសែបនៅក្នុងសុបិន្ត ។ លោក យ៉ូសែបយល់ព្រមទទួល ពតិមានមកពីព្រះជាម្ចាស់ ហើយបង្ហាញតាមរយៈសកម្មភាពរបស់គាត់ទៀតថាគាត់ព្រមទទួល ។ បញ្ហាគឺធម្មតា-ខ្វះចំណេះដឹង ។ ដំណោះស្រាយក៏ ធម្មតាដែរគឺព្រះជាម្ចាស់បានផ្តល់ពតិមានដែលចាំបាច់ដល់គាត់ ។ ការប្រព្រឹត្តរបស់លោក យ៉ូសែបបានឆ្លើយតបនូវពតិមាននេះយ៉ាងលឿន ។

នេះគឺជាសំនួរខ្លះដែលអ្នកអាចប្រើ ដើម្បីពិភាក្សាព្រឹត្តិការណ៏នេះនៅក្នុងជីវិតរបស់
លោក យ៉ូសែប និង នាង ម៉ារី ។

១. តើអ្វីដែលធ្វើអោយអ្នកចាប់អារម្មណ៏អំពីព្រឹត្តិការណ៏នេះ?
២. តើអ្វីដែលបង្កអោយ លោក យ៉ូសែបមានមន្ទិលសង្ស័យចំពោះការពន្យល់របស់នាងម៉ារី?
សូមចាត់ទុកខ្លួនអ្នកជាលោក យ៉ូសែប ។ អ្នកជឿលើគូរដណ្តឹងរបស់អ្នកទេ បើសិនជានាងប្រាប់ថាព្រះជាម្ចាស់បានធ្វើអោយនាងមានផ្ទៃពោះ?
៣. តើសកម្មភាពអ្វីដែលលោក យ៉ូសែបបានសំរេចចិត្តធ្វើដែលបង្ហាញថាគាត់មិនជឿការពន្យល់របស់នាងម៉ារីចំពោះការមាន ផ្ទៃពោះនេះ?
៤. តើព្រះជាម្ចាស់ជួយលោកយ៉ូសែបដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច?

៥. តើអ្វីជាចំលើយរបស់លោក យ៉ូសែបចំពោះសុបិន្ត? តើចំលើយរបស់គាត់បង្ហាញថាគាត់នៅមានការសង្ស័យទៀតឬទេ?

## ១៤. តើព្រះជាម្ចាស់ប្រព្រឹត្តយ៉ាងណាចំពោះអ្នកមានមន្ទិលសង្ស័យ? (៥-១០នាទី)

រូបភាពទាំងបីបង្ហាញនៅក្នុងព្រះគម្ពីរនេះ ផ្តល់នូវភាពច្បាស់លាស់អំពីរបៀបដែលព្រះជាម្ចាស់ដោះស្រាយជាមួយអ្នកដែលមានមន្ទិល សង្ស័យដោយស្មោះ ។ ព្រះជាម្ចាស់មិនប្រងើយកន្តើយចំពោះមន្ទិលសង្ស័យនោះទេ ។ ព្រះអង្គដោះស្រាយដោយផ្ទាល់ចំពោះបុគ្គល ម្នាក់ៗ ។ ព្រះអង្គមិនបានរិះគន់ឬដាក់ទោសពួកគេដោយការខ្វះជំនឿនោះទេ ។ ការសង្ស័យដោយស្មោះមិនមែនជាអំពើបាបដែល អាក្រក់ដែលអ្នកអាចធ្វើខុសនោះទេ ។ ក្នុងករណីទាំងបីនេះ ពួកគេបានជ្រើសរើសដោយបោះបង់មន្ទិលសង្ស័យចោល ហើយទទួលជំនួយពីព្រះជាម្ចាស់ ។ ពួកគេមិនមានការចចេសនោះទេ បន្ទាប់ពីព្រះជាម្ចាស់បានផ្តល់ចំលើយដល់គេហើយនោះ ។

ប៉ុន្តែយើងត្រូវតែមានការប្រុងប្រយត្ន័ផងដែរ យើងមិនត្រូវបដិសេធន៍ជំនួយមកពីព្រះជាម្ចាស់នោះទេ ។ សេចក្តីក្រោធរបស់ទ្រង់មានចំពោះអ្នកណាដែលបានបដិសេធន៍ក្នុងការជឿជាក់លើទ្រង់ ហើយនិងអស់អ្នកណាដែលបានបន្តចោទសួរលើសេចក្តីសុចរិតរបស់ទ្រង់នោះ ។ ការធ្វើដំណើររបស់ជនជាតិអ៊ីស្រាអែលចេញពីស្រុកអេស៊ីបដើម្បីទៅកាន់ទឹកដីសន្យានោះ គឺប្រជាជនអ៊ីស្រាអែលមានទោសកំហុសដោយការមិនជឿបែបនេះ ។ ទំនុកតម្កើង ៩៥:៨-១០

## ១៥. ការអនុវត្តផ្ទាល់ខ្លួន

ចូរអោយសិស្សសរសេរមួយឬក៏ ច្រើននៃមន្ទិលសង្ស័យដែលពួកគេមាន ។ មុនពេលចាប់ផ្តើមការសិក្សាបន្ទាប់ ចូរអោយពួកគេសាក ល្បងគំរោងផែនការទាំង ៥ ជំហាននៅទំព័រទី ៤៦ - ៤៧ នៅក្នុងសៀវភៅណែនាំរបស់សិស្ស ។ ពួកគេគួរសរសេរនូវចំលើយទាំងអស់ របស់ពួកគេនៅក្នុងជំហាននិមួយៗ ជាពិសេសជំហានទី ៣ និង ទី ៥ ។ សូមអោយពួកគេយកកិច្ចការទាំងនេះមក នៅម៉ោង សិក្សាបន្ទាប់សំរាប់ជាការពិភាក្សាបន្ថែមពីរបៀបលះបង់មន្ទិលសង្ស័យ ។

ប្រសិនបើគ្មានមន្ទិលសង្ស័យនៅក្នុងពេលបច្ចុប្បន្ននេះ ចូរអោយពួកគេសរសេរអំពីមន្ទិលសង្ស័យមួយដែលពួកគេមាននៅក្នុងពេលអតីតកាល ។ តើអ្វីដែលបានបង្កអោយមានមន្ទិលសង្ស័យនោះ? តើពួកគេបានដោះស្រាយវាដោយរបៀបណា?

## ១៦. កិច្ចការដែលត្រូវធ្វើ

១. ដាក់ពិន្ទុគំរោង ទី ៨ និង ទី ៩ថ្ងៃនេះ ប្រសិនបើអ្នកមិនបានបំពេញវានៅម៉ោងសិក្សាពីថ្ងៃមុន ។

២. ដាក់ពិន្ទុគំរោង ទី ៥ " សរសេររឿងរបស់អ្នក " ។

## ១៧. គំនិត និង ការវាយតំលៃរបស់ខ្ញុំសំរាប់ការបង្រៀននៃមេរៀននេះនៅពេលក្រោយ

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៍ដល់សិស្សរបស់អ្នក ។

# មេរៀន ទី ៩

## ការបំបាត់ចោលមន្ទិលសង្ស័យ

### ១. សេចក្តីពិតនៃព្រះគម្ពីរសំខាន់ៗ

ខ្ញុំអាចបំបាត់ចោលមន្ទិលសង្ស័យរបស់ខ្ញុំ អំពីការក្លាយជាគ្រីស្តបរិស័ទ នៅពេលដែលខ្ញុំបង្កើតគំរូសំរាប់ យកឈ្នះលើបញ្ហាដែលបណ្តាលអោយមានមន្ទិលសង្ស័យទាំងនេះ ។

### ២. ខ គម្ពីរសំខាន់ : ទំនុកតម្កើង ៩៤ : ១៩

ពេលណាមានទុក្ខកង្វល់ញាំញីក្នុងចិត្តទូលបង្គំ ព្រះអង្គសំរាលទុក្ខទូលបង្គំ ដោយប្រទានអោយទូលបង្គំមានអំណរសប្បាយ ។

### ៣. យោងតាមឯកសាររបស់សិស្ស

ទំព័រ ៤០-៤៧នៅក្នុងសៀវភៅណែនាំរបស់សិស្សស៊ីគ្នាជាមួយនឹងមេរៀននេះ ។ គំរោងទី ១២ " ការដោះស្រាយមន្ទិលសង្ស័យ " ពីការណែនាំសិក្សានឹងត្រូវបានប្រើជាមួយមេរៀននេះ ។ ប្រសិនបើពេលវេលាអនុញ្ញាតអោយ យើងប្រហែលជាប្រើផងដែរនៅ គំរោងទី ៥ " សរសេររឿងរបស់អ្នក " ។

### ៤. ការចាប់ផ្តើមមេរៀន " ប្រសិនបើខ្ញុំស្លាប់យប់នេះ "

ចាប់ផ្តើមថ្នាក់រៀនដោយសួរសំនួរដល់សិស្សម្នាក់អោយឆ្លើយនៅសំនួរដូចខាងក្រោម ។ សូមកុំអោយពួកគេឆ្លើយខ្លាំងៗនៅខាងមុខ ថ្នាក់ ។ អ្នកអាចថតចំលងសំនួរនេះហើយអោយពួកគេបំពេញដោយឡែកៗពីគ្នា ។ ប្រាប់គេមុនប្រសិនបើអ្នកមានផែនការប្រមូលកិច្ចការទាំងនេះមកវិញឬក៏ អត់នោះ ។

ប្រសិនបើអ្នកស្លាប់នៅយប់នេះ តើអ្នកមានទំនុកចិត្តថាអ្នកនឹងទៅឋានសួគ៌ឬទេ? សូមពន្យល់ដោយសង្ខេបថាតើហេតុអ្វីបានជាអ្នក ជ្រើសរើសសំនួរនេះ ។

១. មែនហើយ ខ្ញុំមានទំនុកចិត្តថា ខ្ញុំនឹងទៅឋានសួគ៌ ខ្ញុំមានអារម្មណ៍ថាទំនាក់ទំនងរបស់ខ្ញុំជាមួយព្រះជាម្ចាស់ល្អណាស់ ។

២. ជួនកាលខ្ញុំមានមន្ទិលសង្ស័យថាតើខ្ញុំអាចទៅឋានសួគ៌ឬក៏ អត់ ។

៣. ខ្ញុំមិនច្បាស់ទាល់តែសោះថា ប្រសិនបើខ្ញុំស្លាប់នៅយប់នេះ ខ្ញុំអាចទៅឋានសួគ៌ឬអត់នោះទេ ។

៤. ខ្ញុំមិនចង់គិតអំពីរឿងនេះទេ ។

ជាធម្មតា យើងចង់មានសកម្មភាពមួយដើម្បីជួយអោយសិស្សមានការបើកចំហរចិត្ត និង មានការចូលរួមពិភាក្សាគ្នានៅក្នុងថ្នាក់ ។ នេះអាចជាសំនួរមួយ ដែលបំភ័យដល់អ្នកខ្លះ ដែលមិនទាន់មានការទំនាក់ទំនងច្បាស់លាស់ជាមួយនឹងព្រះយេស៊ូ ។ វិធីមួយដែលអាចជួយអ្នកអោយកាត់បន្ថយភាពតានតឹងគឺពិពណ៌នាពីរបៀបដែលអ្នកបានឆ្លើយសំនួរនេះទៅលើចំនុចខុសប្លែកគ្នានៅក្នុងជីវិតរបស់អ្នក ។

សូមពន្យល់នៅពេលដែលអ្នកបានជ្រើសរើសចំលើយនិមួយៗខុសៗគ្នា ហើយសូមប្រាប់ថា តើអ្នកផ្លាស់ប្តូរពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតដោយរបៀបណា? ហេតុអ្វី?

បើអ្នកគិតថាវាអាចជួយដល់សិស្សក្នុងថ្នាក់បាន អ្នកអាចសួរថា តើនរណាអាចចែកចាយចំលើយរបស់ពួកគេអំពីសកម្មភាពទាំងនោះដល់សិស្សនៅក្នុងថ្នាក់បាន? សូមអោយពួកគេពន្យល់ថាតើហេតុអ្វីបានពួកគេជ្រើសរើសចំលើយនោះ ។

## ៥. រំលឹកឡើងវិញជំហានទាំង ៥ ដែលមានជ័យជំនះលើមន្ទិលសង្ស័យ (៥-១០នាទី)

សូមមើលឡើងវិញនៅជំហានផែនការទាំង៥ ពីរបៀបលះបង់មន្ទិលសង្ស័យដែលត្រូវបានផ្តល់ឱ្យនៅលើទំព័រ ទី ៤៦-៤៧ នៅក្នុង សេចក្តីណែនាំរបស់សិស្ស ។ សូមផ្តល់ឧទាហរណ៍ មួយ ឬក៏ ពីរអំពីជីវិតរបស់ខ្លួនអ្នកផ្ទាល់ តើអ្នកធ្វើតាមគំរូនេះដោយរបៀបណា? សូមធ្វើអោយប្រាកដថា ត្រូវចែកចាយលទ្ធផលទាំងអស់អោយបានច្បាស់លាស់-តើដំណោះស្រាយរបស់អ្នកពិតជាអាចប្រើបានឬទេ? តើប្រើរយៈពេលយ៉ូរប៉ុណ្ណា? សូមកុំខ្លាចក្នុងការចែកចាយពីការបរាជ័យដូចដែលបានចែកចាយពីជោគជ័យនោះដែរ ។

## ៦. ពិភាក្សាការបង្កនៃមន្ទិលសង្ស័យ នៅក្នុងករណី ទី ១ នៅលើគំរោង ទី ១២ (១០-១៥នាទី)

សូមអោយសិស្សផ្សេងៗគ្នាចែកចាយចំលើយរបស់ពួកគេចំពោះសំនួរ មួយក្នុងករណីទី ១ នៅលើគំរោងទី ១២ ។ សូមព្យាយាមអោយ ការពិភាក្សាមានការបើកចំហររហូតដល់ចប់ធ្វើដូច្នេះចំលើយផ្សេងៗដែលអាចកើតមានឡើងត្រូវបានចែកចាយដោយសេរី ។ បន្ទាប់ពីអ្នកបានពិភាក្សាចំលើយរបស់ពួកគេរួចហើយយកពេលវេលាពីរ ឬក៏បីនាទីដើម្បីមើលឡើងវិញនៅគំរោងជំហានទី៤ ពីរបៀបរកអោយឃើញអ្វីដែល បង្កអោយមានការសង្ស័យរបស់អ្នក ។ ផែនការនោះត្រូវបានផ្តល់នៅលើទំព័រទី ៤៥-៤៦ នៅក្នុងសេចក្តីណែនាំរបស់សិស្ស ។ អោយសិស្សរបស់អ្នកពិភាក្សាពីរបៀប ផាត អាចរកឃើញធាតុបង្កនៃមន្ទិលសង្ស័យរបស់គាត់ដោយប្រើផែនការនេះ ។

នៅពេលដែលអ្នកបានកំណត់អ្វី ដែលអ្នកគិតថាវាជាការបង្កខ្លាំងបំផុតនៃមន្ទិលសង្ស័យរបស់ផាតបន្ទាប់មកសំរេចចិត្តថា តើបញ្ហានោះឋិតនៅក្នុងបញ្ហាមួយណា នៅក្នុងចំណោមបញ្ហាទាំងបីនេះ ។

- បញ្ហាចំណេះដឹង
- បញ្ហាការយល់ដឹង
- បញ្ហាការប្រព្រឹត្ត

អោយសិស្សគាំទ្រចំលើយរបស់ពួកគេជាមួយនឹងការពន្យល់ថាតើហេតុអ្វីបានជាគេជ្រើសរើសនោះ។ ប្រសិនបើពួកគេយល់ដឹងច្បាស់ពី ការបង្កមន្ទិលសង្ស័យរបស់ ផាត វានឹងមានការងាយស្រួលសំរាប់ពួកគេនាំមកជាមួយនឹងវិធីដ៏មានប្រសិទ្ធភាពសំរាប់គាត់ដើម្បីលះបង់ មន្ទិលសង្ស័យទាំងអស់នេះ ។

## ៧. ពិភាក្សាដំណោះស្រាយសំរាប់មន្ទិលសង្ស័យនៅក្នុងករណី ទី ១ នៅលើ គំរោងទី ១២ (១០-១៥នាទី)

សូមអោយសិស្សចែកចាយគំនិតរបស់ពួកគេដើម្បីដោះស្រាយចំងល់របស់ ផាត នៅក្នុងករណីទី ១ នៅលើ គំរោង ទី ១២ ។ ចំលើយ របស់ពួកគេនឹងប្រហែលទាក់ទងទៅនឹងបញ្ហាដែលពួកគេបានសរសេរសំរាប់សំនួរទី ១ នៅក្នុងករណីសិក្សានោះ ។ ដំណោះស្រាយរបស់ ពួកគេជាច្រើនប្រហែលជាគោលបំណងយ៉ូរអង្វែង ។ ប្រសិនបើកិច្ចការនេះជាការពិត សូមអោយពួកគេផ្ដល់អោយអ្នកនៅគោលបំណង ជាក់លាក់ដែលផាត អាចបង្កើតឡើងនៅពីរបីថ្ងៃខាងមុខដើម្បីចាប់ផ្ដើមលះបង់នៅបញ្ហាទាំងអស់នេះ ។ ព្យាយាមអោយពួកគេគិត អោយបានម៉ត់ចត់នូវផលវិបាកនៃគោលដៅផ្សេងៗគ្នាដែលពួកគេលើកឡើង ។តើគោលដៅទាំងនោះពិតប្រាកដឬទេ?

អ្នកអាចកត់ចំណាំដោយប្រុងប្រយ័ត្ននៃចំលើយផ្សេងៗគ្នាដែលសិស្សរបស់អ្នកផ្ដល់អោយនៅផ្នែកមេរៀននេះ ។ គំនិតរបស់ពួកគេ នៅលើករណីសិក្សាទាំងពីរនេះប្រហែលជាមានប្រយោជន៍នៅពេលដែលអ្នកបង្រៀនមេរៀននេះពេលក្រោយទៀត ។

## ៨. ពិភាក្សាការបង្កនៃមន្ទិលសង្ស័យនៅក្នុងករណី ទី ២ នៅលើ គំរោងទី ១២ (១០-១៥នាទី)

សូមអោយសិស្សផ្សេងៗចែកចាយចំលើយរបស់ពួកគេចំពោះសំនួរមួយនៃ ករណីទី ២ នៅលើគំរោងទី ១២ ។សូមព្យាយាមអោយ ការពិភាក្សាមានការបើកចំហររហូតដល់ចប់ ធ្វើដូច្នេះចំលើយផ្សេងៗដែលអាចកើតមានឡើងត្រូវបានចែកចាយដោយសេរី ។ អោយពួកគេពិភាក្សាពីរបៀប ខេវ អាចរកឃើញនៅការបង្កនៃការសង្ស័យរបស់គាត់ដោយប្រើគំរោងជំហានទី ៤ ដែលផែនការនោះត្រូវបានផ្ដល់នៅលើទំព័រ ទី ៤៥-៤៦ នៅក្នុងសេចក្ដីណែនាំរបស់សិស្ស ។

នៅពេលដែលអ្នកបានកំណត់អ្វី ដែលអ្នកគិតថាវាជាការបង្កខ្លាំងបំផុតនៃមន្ទិលសង្ស័យរបស់ ខេវ បន្ទាប់មកសំរេចចិត្តថា តើបញ្ហានោះឋិតនៅក្នុងបញ្ហាមួយណានៅក្នុងចំណោមបញ្ហាទាំងបីនេះ ។

- បញ្ហាចំណេះដឹង
- បញ្ហាការយល់ដឹង
- បញ្ហាការប្រព្រឹត្ត

អោយសិស្សគាំទ្រចំលើយរបស់ពួកគេជាមួយនឹងការពន្យល់ថាតើហេតុអ្វីបានជាគេជ្រើសរើសនោះ ។ ប្រសិនបើពួកគេយល់ដឹងច្បាស់ពី ការបង្កមន្ទិលសង្ស័យរបស់ ខេវ វានឹងមានការងាយស្រួលសំរាប់ពួកគេនាំមកជាមួយនឹងវិធីដ៏មានប្រសិទ្ធភាពសំរាប់គាត់ដើម្បីបំបាត់ចោលមន្ទិលសង្ស័យទាំងអស់នេះ ។

## ៩. ពិភាក្សាដំណោះស្រាយសំរាប់មន្ទិលសង្ស័យនៅក្នុងករណី ទី ២ នៅលើ គំរោងទី ១២ (១០-១៥នាទី)

សូមអោយសិស្សចែកចាយគំនិតរបស់ពួកគេដើម្បីដោះស្រាយចំងល់របស់ ខេវ នៅក្នុងករណីទី ២ នៅលើ គំរោង ទី ១២ ។ ចំលើយ របស់ពួកគេនឹងប្រហែលទាក់ទងទៅនឹងបញ្ហាដែលពួកគេបានសរសេរសំរាប់សំនួរទី១ នៅក្នុងករណីសិក្សានោះ ។ សូមប្រើកិច្ចការដូចគ្នា ដែលត្រូវបានផ្តល់អោយជាមួយនឹងករណីសិក្សារបស់ផាត នៅក្នុងការវាយតំលៃដំណោះស្រាយដែលពួកគេផ្តល់ដល់មន្ទិលសង្ស័យរបស់ ខេវ ។

## ១០. ពិភាក្សាមន្ទិលសង្ស័យដែលសិស្សរបស់អ្នកមាន (១០-១៥នាទី)

សកម្មភាពអនុវត្តផ្ទាល់ខ្លួន សំរាប់ថ្នាក់រៀនមុនបានសុំអោយសិស្ស សរសេរការវាយតំលៃនៃមន្ទិលសង្ស័យដែលអ្នកពួកគេកំពុងតែ ប្រឈមមុខនៅក្នុងជីវិតរបស់ពួកគេ ។ ពួកគេបានសរសេរបញ្ហាដែលបង្កមន្ទិលសង្ស័យ និង ដំណោះស្រាយដែលយកជាបានការសំរាប់ លះបង់មន្ទិលសង្ស័យនេះ ។ សុំសិស្សដែលស្ម័គ្រចិត្តអោយអានបញ្ហារបស់ពួកគេ និង ដំណោះស្រាយដែលគេបានលើកឡើងដល់ថ្នាក់ រៀនទាំងមូល ។ ហើយសូមអោយសិស្សនៅក្នុងថ្នាក់ទាំងមូលវាយតំលៃឧទាហរណ៍ដែលផ្តល់ដោយសិស្សស្ម័គ្រចិត្តនោះ ។

- តើអ្នកគិតថាសិស្សបានកំណត់ជាក់ច្បាស់បញ្ហាដែលបង្កមន្ទិលសង្ស័យឬទេ?
- តើមានធាតុបង្កអ្វីផ្សេងទៀតឬទេដែលអាចកើតមានឡើង?
- តើសិស្សបានបង្កើតអោយមានជំហានច្បាស់លាស់ដើម្បីដោះស្រាយមន្ទិលសង្ស័យឬទេ?
- តើមានគោលបំណងគ្រប់គ្រាន់ និង ប្រាកដប្រជាដែលគាត់អាចចាប់ផ្តើមសប្តាហ៍នេះហើយឬនៅ?
- តើគោលបំណងនេះអាចវាស់វែងបានដែរឬទេ?
- តើព្រះជាម្ចាស់មានតួនាទីអ្វីក្នុងដំណើរការដោះស្រាយនេះ?
- តើសិស្សកំពុងតែពឹងផ្អែកយ៉ាងខ្លាំងមកពីព្រះជាម្ចាស់ឬក៏គេទុកព្រះជាម្ចាស់មួយអន្លើក្នុងការដោះស្រាយបញ្ហានេះ?

ប្រសិនបើអ្នកមានពេលវេលាសូមអនុញ្ញាតអោយសិស្សជាច្រើនចែកចាយមន្ទិលសង្ស័យរបស់ពួកគេ និង ធ្វើឡើងវិញនៅដំណើរការវាយ តំលៃដូចមុន ។ រំលឹកដល់សិស្សអោយធ្វើតាមដំបូន្មាននៃ ព្រះគម្ពីរ យូដាស ខ ទី ២២ " ត្រូវមេត្តាករុណាដល់បងប្អូនដែលមានចិត្តស្ទាក់ស្ទើរ " ។ សូមធ្វើអោយប្រាកដថាសិស្សរក្សានូវគំនិតរបស់ពួកគេវិជ្ជមាន និង មានប្រយោជន៍ ។

## ១១. រំលឹកឡើងវិញនៅបញ្ហា ដែលបង្កអោយមានមន្ទិលសង្ស័យ ( ៥-១០នាទី)

វាប្រហែលជាមានប្រយោជន៏ក្នុងការរំលឹកឡើងវិញនៅបញ្ហាទាំង១០ ដែលត្រូវបានផ្តល់អោយនៅលើទំព័រ ទី ៤០-៤៤នៅក្នុង សៀវភៅណែនាំរបស់សិស្ស ។ ទាំងនេះគឺជាបញ្ហាទូទៅដែលជារឿយៗ បង្កអោយគ្រីស្តបរិស័ទមានមន្ទិលសង្ស័យ ។ សូមពិភាក្សា ថាតើ បញ្ហាទាំងនេះបង្កអោយមានមន្ទិលសង្ស័យ ដោយរបៀបណា និង ពួកគេអាចដោះស្រាយកិច្ចការនេះដោយរបៀបណាបាន?

អ្នកប្រហែលជាចង់ចែកចាយនៅឧទាហរណ៏នៃសិស្សដទៃទៀតដែលបានរៀនថ្នាក់នេះពីមុនមក និងពីរបៀបដែលពួកគេឆ្លើយតបទៅ នឹងមន្ទិលសង្ស័យនេះ ។ កិច្ចការនេះនឹងមានប្រយោជន៏ជាពិសេសប្រសិនបើអ្នកមានសិស្សដែលមានអារម្មណ៏មិនស្រណុកក្នុងការចែកចាយឧទាហរណ៏ជាមួយនឹងថ្នាក់ទាំងមូល ។

នៅក្នុងករណីទាំងអស់ដែលអ្នកបានពិភាក្សា គឺសង្កត់ធ្ងន់ទៅលើតំលៃនៃការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនជាផ្នែកមួយយ៉ាងសំខាន់ដើម្បីលះ បង់មន្ទិលសង្ស័យចោល ។ គន្លឹះដ៏សំខាន់គឺរកអោយឃើញផ្លូវរបស់ព្រះជាម្ចាស់ដើម្បីលះបង់មន្ទិលសង្ស័យនោះចោល-ផ្លូវរបស់ព្រះអង្គ គឺប្រសើរជាងផ្លូវដែលយើងបានគិតឃើញឆ្ងាយណាស់ ។ លើកទឹកចិត្តពួកគេអោយស្វែងរកអោយឃើញនៅអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីបញ្ហាដែលកំពុងតែបង្កអោយមានមន្ទិលសង្ស័យរបស់ពួកគេ ។ បង្ហាញពួកគេពីរបៀបដែលគេអាចធ្វើកិច្ចការនេះបាន ។

## ១២. មនុស្សដទៃទៀតដែលមានមន្ទិលសង្ស័យ (៥-១០នាទី)

លើកទឹកចិត្តដល់សិស្សអោយជួយអ្នកដទៃដែលកំពុងតែជួបនៅមន្ទិលសង្ស័យនេះ ។ ជាច្រើនពេលគ្រីស្តបរិស័ទថ្មីអាចចំណាំបានយ៉ាងងាយស្រួលជាមួយនឹងបញ្ហាដែលអ្នកជឿថ្មីដទៃទៀតកំពុងតែមាន ។ ប្រសិនបើអ្នកមានពេលវេលា អ្នកអាចរំលើកឡើងវិញ នៅវិធី របស់ព្រះយេស៊ូដែលបានដោះស្រាយជាមួយអស់អ្នកដែលមករកទ្រង់ដោយជាប់មកជាមួយនឹងមន្ទិលសង្ស័យនោះ ។

- អ្នកដឹកនាំវ័យក្មេងដែលជាអ្នកមានទ្រព្យសម្បត្តិ លូកា ១៨:១៨-៣០
- ពេត្រុសដើរលើទឹក ម៉ាថាយ ១២:២២-៣៣
- ថូម៉ាសសង្ស័យពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ត យ៉ូហាន ២០:១៩-៣១

អ្នកប្រហែលជាចង់ចែកថ្នាក់រៀនជាបីក្រុមនិង អោយពួកគេមើលឡើងវិញម្តងទៀតនៅឧទាហរណ៏នៅក្នុងព្រះគម្ពីរ ។ អោយពួកគេ ធ្វើបញ្ជីនៃគំនិតដែលមានប្រយោជន៏ដែលយើងអាចរៀនពីផ្លូវរបស់ព្រះគ្រីស្តបានជួយអស់អ្នកដែលមានមន្ទិលសង្ស័យ ។ពួកគេអាចធ្វើ បញ្ជីពីរ ។

១. កិច្ចការមានប្រយោជន៏ដែលត្រូវធ្វើសំរាប់អស់អ្នកដែលមានមន្ទិលសង្ស័យ

២. កិច្ចការដែលមិនត្រូវធ្វើសំរាប់អស់អ្នកដែលមានមន្ទិលសង្ស័យ

នៅក្នុងករណីទាំងបីនេះយើងឃើញថាព្រះយេស៊ូឆ្លើយតបនៅក្នុងផ្លូវដូចៗគ្នា ។ ព្រះអង្គមិនបានផាត់ចោលនៅមន្ទិលសង្ស័យរបស់ ពួកគេថា ល្ងីល្ងើ ឬក៏ មិនសំខាន់នោះឡើយ ។ ទ្រង់មានព្រះបន្ទូលទៅកាន់មនុស្សនោះយ៉ាងសុភាព ។ ព្រះគ្រីស្ទបង្ហាញនៅឥរិយាបថ ដែលមិនគិតថាខ្ពស់ជាងនោះទេគឺមានភាពស្មើគ្នា ។ ព្រះគ្រីស្ទមិនបានអធិប្បាយវែងឆ្ងាយអំពីមន្ទិលសង្ស័យនោះទេ ។ ព្រះគ្រីស្ទបានផ្តល់នៅដំបូន្មាន ត្រង់ៗនិងងាយស្រួលពីរបៀបដោះស្រាយមន្ទិលសង្ស័យនោះ ។

សូមអោយសិស្សរបស់អ្នកយល់ដឹងថា ពួកគេគ្មានកាតព្វកិច្ចដើម្បីដោះស្រាយមន្ទិលសង្ស័យរបស់អ្នកផ្សេងទេ ។ ទោះបីជាពួកគេមិន មានដំណោះស្រាយចំពោះបញ្ហាក៏ដោយ ក៏ពួកគេអាចធ្វើកិច្ចការសំខាន់ពីរផងដែរ ។ ទីមួយ ពួកគេអាចជាអ្នកស្តាប់ដែលមានចិត្តមេត្តា។ ជាច្រើនដង មនុស្សដែលមានបញ្ហាជាមួយមន្ទិលសង្ស័យ ចាំបាច់ត្រូវមានការធានាដែលថាអ្វីដែលគាត់កំពុងតែមាននោះមិនមែនជាការបញ្ចប់នៃពិភពលោកនោះទេ ។ ទីពីរ ពួកគេអាចផ្តល់ជាការលើកទឹកចិត្ត ។ ប្រាប់ពួកគេអោយសារភាព " សូមមើលខ្ញុំមិនមាន ដំណោះស្រាយចំពោះបញ្ហារបស់អ្នកទេ ប៉ុន្តែខ្ញុំចង់អោយអ្នកដឹងថា ខ្ញុំបារម្ភពីអ្នក ។ ខ្ញុំនឹងអធិស្ឋានអោយអ្នក ។ ខ្ញុំដឹងថា អ្នកអាច ពឹង ផ្អែកទៅលើព្រះជាម្ចាស់ដើម្បីអោយទ្រង់ជួយអ្នក ហើយខ្ញុំនឹងធ្វើអ្វីៗទាំងអស់ដែលខ្ញុំអាចធ្វើទៅបានដើម្បីជួយអ្នកផងដែរ " ។

លើកទឹកចិត្តពួកគេអោយមានការប្រុងប្រយ័ត្នអំពីការព្យាយាមដោះស្រាយមន្ទិលសង្ស័យដែលគ្រីស្ទបរិស័ទដទៃទៀតមាន ។ សូមកុំ លើកទឹកចិត្តពួកគេ គ្រាន់តែផ្តល់នៅចំលើយដ៏សាមញ្ញដូចជា " អធិស្ឋានអំពីកិច្ចការនេះ នោះមន្ទិលសង្ស័យរបស់អ្នកនឹងរសាត់ បាត់ទៅ " ។ ការអធិស្ឋានគឺជាផ្នែកមួយសំខាន់ណាស់នៃដំណើរការនៃទទួលការធានានៃទំនាក់ទំនងរបស់អ្នកជាមួយព្រះគ្រីស្ទ ។ ប៉ុន្តែការផ្តល់ចំលើយប្រភេទបែបនោះជួនកាលមានផលអាក្រក់ច្រើនជាងល្អ ។ ប្រសិនបើពួកគេស្តាប់ដោយប្រុងប្រយ័ត្ន និង ផ្តល់នូវការ លើកទឹកចិត្តដោយស្មោះ ពួកគេអាចមានទំនុកចិត្តថា ការជួយប្រភេទនេះនឹងពិតជាផ្តល់អត្ថប្រយោជន៏ដល់អស់អ្នកដែលមាន មន្ទិលសង្ស័យនេះ ។

## ១៣. សន្និដ្ឋាន (៥-១០នាទី)

សូមសួរប្រសិនបើពួកគេមានសំនួរដទៃទៀតអំពីមុខវិជ្ជានេះទាំងមូល ។ ប្រសិនបើអ្នកមានពេលវេលាបន្ថែម អ្នកប្រហែលជាចង់ អោយសិស្សម្នាក់ ឬក៏ ពីរនាក់អោយអានដល់ថ្នាក់ទាំងមូលអំពីកិច្ចការដែលពួកគេបានធ្វើនៅលើគំរោងការ ទី ៥ " សរសេររឿងរបស់អ្នក " ប្រសិនបើគំរោងទាំងនេះត្រូវបានធ្វើដោយត្រឹមត្រូវ សិស្សគួរតែអាចពន្យល់បានយ៉ាងច្បាស់ដល់មនុស្សដទៃទៀតពីរបៀបក្លាយទៅជាគ្រីស្ទបរិស័ទ ។

## ១៤. ការអនុវត្តន៍ផ្ទាល់ខ្លួន (៥នាទី)

១. ជំរុញអោយពួកគេបន្តធ្វើកិច្ចការនៅលើគោលដៅជាក់លាក់ដើម្បីយកជ័យជំនះលើបញ្ហាដែលបង្កអោយមានមន្ទិលសង្ស័យនៅក្នុង ជីវិតរបស់ពួកគេ ។

២. អោយសិស្សចាប់គូរមួយគូរៗដើម្បីចែកចាយជាមួយគ្នាទៅវិញទៅមក យ៉ាងហោចណាស់ក៏មានផ្លូវមួយដែលមុខវិជ្ជានេះបានជួយ ពួកគេអោយដឹងថាពួកគេគឺជាគ្រីស្ទបរិស័ទដែរ ។ អោយពួកគេអធិស្ឋានជាមួយគ្នាទៅវិញទៅមក ។

## ១៥. កិច្ចការត្រូវធ្វើ

១. ដាក់ពិន្ទុគំរោង ទី ១២ " ការដោះស្រាយមន្ទិលសង្ស័យ " និង គំរោងផ្សេងដទៃទៀតដែលអ្នកមិនទាន់បានដាក់ពិន្ទុនៅឡើយ ។

## ១៦. ការវាយតំលៃ និង គំនិតរបស់ខ្ញុំសំរាប់ការបង្រៀនមេរៀននេះពេលក្រោយ

សូមបង្ហាញគំនិតរបស់អ្នកសំរាប់ធ្វើអោយមេរៀននេះកាន់តែប្រសើរឡើង ។ តើផ្នែកណាដែលល្អបំផុត? តើចំនុចណាដែលពិបាកបំផុតសំរាប់សិស្សយល់ដឹង? តើចំនុចមួយណាមើលទៅវាមានប្រយោជន៏ដល់សិស្សរបស់អ្នក ។

# មេរៀន ទី ១០

## ការប្រលង

១. សេចក្ដីណែនាំទៅនឹងមុខវិជ្ជាក្រោយទៀតសំរាប់ការសិក្សា

ក. ចែកសៀវភៅណែនាំសិក្សា ឬ កិច្ចការណាដែលត្រូវបំពេញមុននឹងចាប់ផ្ដើមរៀនមុខវិជ្ជាដែលអ្នកនឹងបង្រៀន។

ខ. អោយសិស្សបើកទៅទំព័រចុងក្រោយនៃសៀវភៅណែនាំការសិក្សា ។ គេគួរតែឃើញទំព័រនៃបញ្ជីកិច្ចការដែលត្រូវធ្វើ ។ បើសិនជាសៀវភៅណែនាំការសិក្សារបស់ពួកគេមិនមានទំព័រនេះទេ ចូរអោយគេនូវទំព័រនេះ ។ ដាក់ថ្ងៃខែកំណត់យកទៅនឹងចំណោទសួរកិច្ចការ និង ការប្រលងនិមួយៗ ។

២. អោយវិញ្ញាសារប្រលងទៅនឹងមុខវិជ្ជានេះ

៣. ចូរអោយសិស្សគ្រប់ទាំងសំនួរខ្លីៗ និង គំរោងទាំងអស់ដែលអ្នកបានដាក់ពិន្ទុ ប្រសិនបើអ្នកមិនទាន់បានអោយពួកគេនៅឡើយ ។

# ១

# មុខវិជ្ជា
# តើខ្ញុំអាចដឹងថា
# ខ្ញុំជាគ្រីស្ទបរិស័ទដោយរបៀបណា?

*ការបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់*

**សៀវភៅណែនាំរបស់សិស្ស**

**ការសិក្សាជាក្រុមសំរាប់គ្រីស្ទបរិស័ទថ្មី**